អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-Oct-2012, 15:23
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី១១៥**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ាត់

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក អេនឌ្រូ អ៊ីនូហ្ស៊ី
*(Mr. Andrew IANUZZI)*

លោក សុន អរុណ

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

លោក គ្រីស្ទីន ម៉ាទីណូ

*(Mr. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក មាស វឿន (TCW-428) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក មាស វឿន** (TCW-428)
សួរបន្តដោយលោក ថារីក អាប់ឌុលឡាក់ ផ្តើមពី៖.......................................................ទំព័រ ២
សួរដោយលោក ពេជ អង្គ ផ្តើមពី៖ ...........................................................................ទំព័រ ៧៣

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:១៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសនៅក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី ជាបន្ត។

សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

អរុណសួស្តីអង្គចៅក្រមជាទីគោរព! អរុណសួស្តីភាគីទាំងអស់! អរុណសួស្តីលោក មាស វឿន!

លោកប្រធាន ខ្ញុំសូមបញ្ជាក់អំពីពេលវេលា យើងទទួលបាន១ថ្ងៃកន្លះ តាមការបញ្ជាក់ពីអង្គជំនុំជម្រះកាលពីម្សិលមិញ។ យើងបានផ្ទៀងម៉ោងរបស់យើង មកដល់ពេលនេះ គឺយើងបានចំណាយពេល១ម៉ោង៣០នាទីរួមកហើយ។ ដូច្នេះ យើងនៅសល់ប្រហែលជា៥ម៉ោង៤០នាទីទៀត។ ដូច្នេះ រវាងយើងខ្ញុំ គឺយើងបន្តស្តាប់សក្ខីកម្មនៅថ្ងៃនេះ ពេញ១ថ្ងៃ និង១ម៉ោង សល់១ម៉ោងទៀត នៅថ្ងៃចន្ទ។

ដូច្នេះ ខ្ញុំគ្រាន់តែជូនដំណឹងទៅដល់លោកប្រធាន ឲ្យបានជ្រាបទៅលើចំណុចនេះ។

[០៩:០៣:០៣]

**ប្រធានអង្គជំនុំ៖**

ទំនងមិនដូច្នេះទេ លោកមានពេលវេលាទាំងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផង មានពេលពេញ១ថ្ងៃនេះ ប៉ុណ្ណោះ។ លើកលែងភាពចាំបាច់នៃសំណួរសក្តានុពលដែលត្រូវតាំងសំណួរប៉ុណ្ណោះ ដែលអង្គជំនុំជម្រះនឹងពិចារណាលទ្ធភាពនេះ ដែលពេលវេលាបានបាត់បង់បន្តិចបន្តួចដោយសារកិច្ចដំណើរការនីតិវិធី ដែលអង្គជំនុំជម្រះត្រូវដោះស្រាយបញ្ហាខ្លះៗ នៅក្នុងកិច្ចដំណើរការ។ មិនមែនមានន័យថា លោកយកថ្ងៃ ១ថ្ងៃកន្លះ យកម៉ោងមកគិតនោះទេ។ គឺម្សិលមិញមួយរសៀល ហើយនៅថ្ងៃនេះ ១ថ្ងៃពេញ។ លើកលែងតែស្ថានភាពចាំបាច់នៃសំណួរសក្តានុពល ដែលត្រូវសួរដេញដោល ដែលមានប្រយោជន៍ក្នុងការស្វែងរកការពិតប៉ុណ្ណោះ។ ការកំណត់បែបនេះ ជៀសវាងការប្រើពេលវេលា ដោយសួរនូវសំណួរឯណាដែលមិនភាពចាំបាច់ ជាបន្ទាប់បន្សំ សំណួរច្រំដែល សំណួរដែល

មិនពាក់ព័ន្ធជាដើម ដែលនាំឲ្យបាត់បង់ពេលវេលា។

[០៩:០៤:១៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំកត់សម្គាល់ទៅលើសេចក្តីណែនាំរបស់អង្គជំនុំជម្រះ។ ខ្ញុំគ្រាន់តែបញ្ជាក់នេះ ដោយសារតែម្សិលមិញ យើងចាប់ផ្តើមស្តាប់សាក្សីនេះ យឺតពេលបន្តិច។ ដូច្នេះហើយខ្ញុំគ្រាន់តែបញ្ជាក់ទេ តែមិនជាមិនអ្វីទេ លោកប្រធាន។ ខ្ញុំគោរពតាមការណែនាំ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក វឿន កាលពីម្សិលមិញ នៅពេលដែលយើងឈប់សម្រាក។ ចំណុចមួយ ដែលយើងបានជជែកពិភាក្សានោះ គឺពាក់ព័ន្ធទៅនឹងសមរភូមិនៅក្បែរឧដុង្គ នៅម្តុំឧដុង្គ ហើយនិងសមរភូមិដែលលោកបានចូលរួមវាយប្រយុទ្ធក្នុងនោះ ក្នុងទីនោះផងដែរ គឺតាមផ្លូវជាតិលេខ៥។ ខ្ញុំគ្រាន់តែសូមលើកឡើងចំណុចនេះដោយខ្លី ហើយយកមកពិភាក្សាជាមួយនឹងលោក អំពីសមរភូមិមួយចំនួន ដែលទំនងជាធ្វើការវាយប្រយុទ្ធនៅក្នុងឆ្នាំ១៩៧៣។ ហើយខ្ញុំនឹងលើកឡើងឯកសារមួយចំនួន ដើម្បីឲ្យលោកបញ្ជាក់ថាតើត្រូវនឹងអ្វីដែលលោកចងចាំដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកចៅក្រមជាទីគោរព! ខ្ញុំមានឯកសារមួយគឺលេខ E3/637។ ឯកសារនេះបានយោងរួចមកហើយក្នុងតុលាការយើងនេះកាលពីមុន គឺការស្តាប់ចម្លើយសេចក្តីប្រកាសរបស់លោក ខៀវ សំផន និង ហ៊ូ យន់ និង ហ៊ូ នឹម ដែលក្នុងនោះ គឺនិយាយអំពីការចូលមកសមរភូមិ ចូលវាយសមរភូមិតាមផ្លូវជាតិលេខ៥។ ដូច្នេះហើយគឺខ្ញុំសូមអានជូនសាក្សីស្តាប់ ដើម្បីឲ្យយើងដឹងអំពីអ្វីដែលគេសរសេរអំពីសមរភូមិនេះ។ សូមអនុញ្ញាតពីលោកប្រធាន។

[០៩:០៦:១៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ERN ជាភាសាខ្មែរពាក់ព័ន្ធគឺ 00442239 -- 329, បារាំងគឺ 00752171, អង់គ្លេស

00470933 រហូតទៅដល់ 934។ លោក វឿន មន្ត្រីតុលាការគឺបានបង្ហាញទំព័រដែលពាក់ព័ន្ធជូនលោក ហើយនៅក្នុងចំណុចទី៣ គឺខ្ញុំសូមអានចំណុចមួយចំនួននៅក្នុងនោះ។ ដូច្នេះហើយសូមឲ្យលោកធ្វើការស្តាប់ការបកប្រែតាមកាសនេះ ហើយផ្ទៀងផ្ទាត់ទៅនឹងអ្វីដែលខ្ញុំអាន។ ដកស្រង់សម្តី "ចំពោះសមរភូមិតាមផ្លូវជាតិលេខ៥ កងកម្លាំងរំដោះប្រជាជនកម្ពុជា គឺបន្តកម្ទេចខ្មាំងពីខាងត្បូងកំពង់ឆ្នាំង ហើយនិងពីទិវ្លមខេត្តកំពង់ឆ្នាំងរហូតទៅដល់សាលាលេខ៥"។ ខ្ញុំរំលងប្រយោគមួយចំនួន ដើម្បីឲ្យយើងអាចចូលទៅបានឲ្យលឿនបន្តិចទៅលើចំណុចនេះ។ ប៉ុន្មានជួរខាងក្រោម គឺលោកឃើញហើយ គឺបានលើកឡើងថា "យោងតាមស្ថិតិគឺយើងបានធ្វើការកម្ទេច និងធ្វើឲ្យមានរបួសឈ្លើយសឹក ១.០៥០ នៅសមរភូមិបន្ទាយមាស កំពង់ឆ្នាំង និងព្រៃខ្មែរ តាមផ្លូវជាតិលេខ៥។ បន្ថែមពីនោះ ក្រុមទាហានរបស់យើងនៅសមរភូមិតាមផ្លូវជាតិលេខ៥ បានចូលរួមវាយប្រយុទ្ធខ្មាំងប្រហែលជាជាង៩០នាក់បន្ថែមទៀត"។

ខ្ញុំឈប់ត្រង់ចំណុចនេះបន្តិចលោក គឹម វឿន (ស៊ីក) តើលោកនឹកឃើញដែរឬទេ? លោកនៅចាំអំពីសរមភូមិនេះដែរឬទេ ដែលរៀបរាប់ដូចដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ?

[០៩:០៨:៥៧]

**លោក មាស វឿន៖**

**ឆ៖** បាទ ចាំបានខ្លះ។

**ស៖** តាមដែលលោកថាចាំខ្លះនេះ ការរៀបរាប់អំពីការវាយចូលអម្បាញ់មិញនេះ គឺត្រឹមត្រូវដែរឬទេ តាមអ្វីដែលខ្ញុំរៀបរាប់នេះ?

**ឆ៖** បាទ ត្រឹមត្រូវហើយ។

**ស៖** ដូចដែលខ្ញុំបញ្ជាក់ឯកសារនេះនៅចំណុចចុងក្រោយនោះ គឺយើងឃើញថានៅពេលនោះកើតឡើងក្នុងខែមករា ឆ្នាំ១៩៧៣។ តើលោកនឹកឃើញទេ នៅក្នុងអំឡុងពេលនោះ គឺឆ្នាំ៧៣ ខែមករា តើលោក ខៀវ សំផន កាន់តួនាអ្វីដែរ?

**ឆ៖** បាទ កាលនោះខ្ញុំអត់បានដឹងទេ។

[០៩:១០:១១]

**ស៖** សំណួរចុងក្រោយមួយទៀតពាក់ព័ន្ធនឹងឯកសារនេះ។ តើលោកដឹងទេ ព័ត៌មានដំណឹងនេះគេបញ្ជូនពីសមរភូមិដោយរបៀបណា បញ្ជូនទៅលោក ខៀវ សំផន នោះ?

**ឆ៖** បាទ បញ្ជូនស្អីគេ? ខ្ញុំស្តាប់អត់បាន។

**ស៖** ខ្ញុំរៀបចំសំណួររបស់ខ្ញុំឡើងវិញ។ លោកបញ្ជាក់រួចមកហើយ ព័ត៌មានអម្បាញ់មិញទាក់ទងនឹងសមរភូមិនេះ គឺជាការលើកឡើងត្រឹមត្រូវ។ ហើយដែលព័ត៌មានទាំងអស់នេះគឺថ្លែងការណ៍ដោយលោក ខៀវ សំផន។ ដូច្នេះ ខ្ញុំគ្រាន់តែចង់សួរលោក តើគេបញ្ជូនព័ត៌មានដំណឹងនេះពីសមរភូមិនោះ មកបុគ្គលមួយចំនួនដូចជាលោក ខៀវ សំផននេះ ដោយរបៀបណាដែរ?

**ផ៖** បាទ ការបញ្ជូនដំណឹងព័ត៌មាននេះ តាមវិទ្យុ ហើយតាមប្រដាប់ តាមលេខៗប្រដាប់ នែ៎! គេហៅអីខ្ញុំភ្លេច ទូរស័ព្ទ តេអូ បាទ តាមតេអូ។

[០៩:១២:០០]

**ស៖** តាមដែលខ្ញុំយល់មិនខុសទេនោះ គឺថាពីសមរភូមិមក គេបញ្ជូនព័ត៌មានហ្នឹងទៅបុគ្គលផ្សេងទៀត ក៏ដូចជាលោក ខៀវ សំផន ដែលគេបញ្ជូនតាមតេអូហ្នឹង មែនដែរទេ?

**ផ៖** បាទ តាមតេអូហ្នឹងបាទ។

**ស៖** ចុះចំពោះលោក តើលោកបញ្ជូនព័ត៌មានេះទៅនរណាគេដែរ?

**ផ៖** បាទ ខ្ញុំបញ្ជូនពីសមរភូមិតាមរយៈកងពល តាសឿង។

**ស៖** យើងចូលទៅដល់ចំណុចៗមួយទៀត គឺការវាយចូលឧដុង្គ ដែលលោកបានរៀបរាប់កាលពីម្សិលមិញ គឺថានៅដើមឆ្នាំ៧៣ ឬក៏នៅក្នុងឆ្នាំ៧៤។ ហើយលោកបានរៀបរាប់កាលពីម្សិលមិញផងដែរ ថាប្រជាជនបានរត់ទៅតំបន់ៗរំដោះ ហើយគេចាត់ចែងរៀបចំឲ្យប្រជាជនទាំងអស់នេះទៅតំបន់រំដោះ ហើយរៀបចំកន្លែងសម្រាប់ពួកគេ។ ខ្ញុំមានសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងចំណុចនេះ ហើយមានឯកសារមួយចំនួនចង់ឲ្យលោកមើលផងដែរ។ ជាដំបូង នៅពេលដែលលោកចូលទៅដល់ឧដុង្គ តើនៅទីនោះគឺនៅសល់ នៅឃើញមានសល់ប្រជាជនស៊ីវិលដែរឬទេ នៅក្នុងឧដុង្គ?

**ផ៖** បាទ ក្នុងពេលដែលរំដោះឧដុង្គបានរួចហើយនោះ ប្រជាជនគ្មាននៅសល់ទេ គាត់ចេញមកតំបន់រំដោះទាំងអស់។

**ស៖** តើលោកនឹកឃើញ នៅចាំដែរឬទេ មុនពេលដែលលោកចូលទៅដល់ឧដុង្គនោះ តើរយៈពេលប៉ុន្មានដែរ ដែលប្រជាជនត្រូវចំណាយពេលធ្វើដំណើរទៅតំបន់រំដោះនោះ?

**ផ៖** បាទ ប្រជាជនទៅតំបន់រំដោះមិនឆ្ងាយប៉ុន្មានទេ ប្រហែល៨គីឡូពីឧដុង្គទៅ។

**ស៖** តើលោកចាំដែរឬទេ តើទីតាំងណាភូមិភាគណាដែលគេឲ្យប្រជាជនទៅនៅនោះ?

[០៩:១៥:១៩]

**ឆ៖** បាទ ទីនោះមិនទាន់មានភូមិភាគនៅឡើយទេ មានតែកងពលនៅតាមជួរផ្លូវលេខ៥ ហើយខាងក្រោយមានតែភូមិ ៗនៅក្នុងពី -- ក្នុងតំបន់រំដោះ។

**ស៖** សូមអរគុណ។ នៅពេលដែលយើងកំពុងតែជជែកពិភាក្សាគ្នាអំពីឧដុង្គ ហើយក្នុងខណៈដែលយើងនិយាយអំពីស្ថានភាពនៅតំបន់នោះ។ តើនៅឧដុង្គនោះមាន នៅពេលដែលចូលទៅដល់នេះមានការចាប់ខ្លួនអ្នករាជការ អ្នករដ្ឋការ លន់ នល់ ឬក៏មន្ត្រីយោធា លន់ នល់ ដែរឬទេនៅពេលដែលកងពលចូល វាយចូលទៅដល់នោះ?

[០៩:១៦:២៥]

**ឆ៖** បាទ ខាងមុខសញ្ញាខ្ញុំអត់មានបានចាប់បានទាហានទេ នៅពីខាងលិច ក៏ប៉ុន្តែផ្នែកខាងកើតខ្ញុំមិនបានដឹង។

**ស៖** ខ្ញុំគ្រាន់តែចង់ជជីកសួរលើចំណុចនេះឲ្យបានច្រើនបន្តិច។ លោកប្រធាន ឯកសារដែលនិយាយអំពីការបែកឧដុង្គនោះ គឺថាការវាយបែកឧដុង្គនោះ គឺឯកសារលេខ E3/167 គឺជាសេចក្តីប្រកាសព័ត៌មានពីការិយាល័យព័ត៌មានរបស់រណសិរ្សសង្គ្រោះជាតិកម្ពុជា គឺចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៤។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមអនុញ្ញាតយកឯកសារជាក្រដាសមួយសន្លឹកជូនទៅដល់សាក្សី។ ហើយខ្ញុំសូមអនុញ្ញាតអានផងដែរ ដើម្បីរៀបរាប់អំពីការវាយបែកឧដុង្គនៅពេលនោះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ គឺយើងខ្ញុំមិនសុំអនុញ្ញាតបញ្ចាំងលើអេក្រង់នោះទេ ដោយសារតែយើងចង់ឲ្យលឿនបន្តិច។ ខ្មែរគឺ 00596141 ជាភាសាខ្មែរ, បារាំង គឺ S.00000122, អង់គ្លេស គឺ 00280580 -- 586។ នេះគឺជាសុន្ទរកថាថ្លែងឡើងដោយលោក ខៀវ សំផន ក្នុងនាមជាឧបនាយករដ្ឋមន្ត្រីចុះថ្ងៃទី ១០ ខែមេសា ឆ្នាំ១៩៧៤។ ខ្ញុំសូមកែតម្រូវ គឺមិនមែនថ្ងៃ១០ ទេគឺនៅថ្ងៃ១០ នៅថ្ងៃ៥ ខែ៤ ឆ្នាំ៧៤។ គឺក្នុងពេលទទួលស្វាគមន៍ ក្នុងពិធីទទួលស្វាគមន៍។

[០៩:១៨:៥១]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ដូច្នេះខ្ញុំសូមអានជូនលោក មាស វឿន។ សូមដកស្រង់សម្តី "នៅក្នុងប្រទេស កងកម្លាំងរំដោះប្រជាជនកម្ពុជា គឺបានវាយកងកម្លាំងផ្សេង។ ហើយនៅពេលនេះ គឺបានវាយចូលទៅដល់ជិតច្រកចូលភ្នំពេញរួចទៅហើយ។ ភ្នំពេញគឺកន្លែងដែលជនក្បត់លាក់ខ្លួន ហើយវាជាសមរភូមិមួយយ៉ាងក្តៅគគុក និងមានការតស៊ូយ៉ាងខ្លាំងពីកងរំដោះប្រជាជនកម្ពុជារបស់យើង។ នៅថ្ងៃទី១៨ ខែមីនា កងកម្លាំងរួបរួមជាតិរបស់យើងបានដោះ -- បានរំដោះឧដុង្គដោយធ្វើការកម្ទេចទាហានសាធារណរដ្ឋនៅទីនោះ។ បានន័យថា គឺខ្មាំងជាង៥.០០០នាក់ត្រូវបានបំផ្លិចបំផ្លាញ ហើយយើងចាប់បាន១.៥០០នាក់"។ លោក វឿន តើការរៀបរាប់នៅក្នុងឯកសារនេះ ឲ្យលោកចាំ នឹកឃើញឡើងវិញដែរឬទេពាក់ព័ន្ធទៅនឹងការចាប់ខ្លួនខ្មាំង នៅពេលដែលដណ្តើមបានឧដុង្គនោះ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងចំនួនទេ ក៏ប៉ុន្តែស្លាប់ឃើញមាននៅកន្លែងនោះ ហើយខ្ញុំមិនបានរៀបរាប់ថាស្លាប់ប៉ុន្មាន ហើយចាប់បានប៉ុន្មាន ខ្ញុំអត់បានដឹងដែរ។

**ស៖** តើលោកដឹងទេអំពីការចាប់ខ្លួនរបស់អ្នកទាំងអស់នោះ ហើយចាប់នៅទីណា ហើយមានអ្វីកើតឡើងចំពោះពួកគេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ កន្លែងត្រង់នោះ។

**ស៖** ឯកសារចុងក្រោយមួយទៀតពាក់ព័ន្ធនឹងឧដុង្គ មុនពេលដែលយើងចូលទៅដល់បញ្ហាសមរភូមិនៅក្នុងទីក្រុងភ្នំពេញ។ ឯកសារនេះគឺដើម្បីស្វែងយល់អំពីស្ថានភាពរបស់ប្រជាជនស៊ីវិលនៅកន្លែងឧដុង្គនោះ។

[០៩:២១:២៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកចៅក្រមឯកសារមួយទៀតនោះគឺ E3/194។ វា -- ឯកសារនេះគឺជាឯកសារព័ត៌មានរបស់អង្គការសហប្រជាជាតិស្តីអំពីបទ -- ការប្រកាសព័ត៌មានសង្ខេបរបស់សហរដ្ឋអាមេរិកគឺចុះខែកក្កដា ឆ្នាំ១៩៧៤។ ខ្ញុំមានឯកសារនេះជាក្រដាសជូនសាក្សី។ ដូច្នេះហើយខ្ញុំសូមអនុញ្ញាតពីលោកប្រធានផ្តល់ឯកសារក្រដាសជូនសាក្សី ហើយខ្ញុំសូមអនុញ្ញាតអានចេញពីឯកសារនេះផងដែរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**លោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ERN ពាក់ព័ន្ធគឺខ្មែរ 00709524, បារាំង ERN គឺ 00726584, អង់គ្លេសគឺ 00412834។ អត្ថបទនេះគឺចាប់ផ្ដើមពីចំណុចលេខ២ ដែលខ្ញុំត្រូវអាននេះ។ នេះគឺអ្វីដែលបានលើកឡើងនៅក្នុងនោះ។ សូមដកស្រង់សម្ដី “ជី.ខេ.អា ប្រហែលជាសំដៅទៅលើរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ។ ជី.ខេ.អា ប្រកាសអំពីការដណ្ដើមយកឧដុង្គពីក្រុង តែត្រូវបានវាយបំផ្លាញនេះ គឺដែលក្នុងនេះ មានវត្ត១០០ ត្រូវបានបំផ្លិចបំផ្លាញ។ ប្រជាជន ៣០.០០០នាក់ត្រូវបានគេបណ្ដើរទៅតំបន់រំដោះ”។ ហើយនៅក្រោមនេះបន្តិចគេសរសេរថា “ប្រភពយោធាកងទ័ពបានលើកឡើងថា ទាហានខ្មាំង ១.៣០០នាក់ និងទាហាន ជី.ខេ.អេ គឺបានចំណាយពេលវាយប្រយុទ្ធគ្នា២ខែ ដើម្បីអាចឲ្យខាងខ្មាំងនោះចាប់យកឧដុង្គ”។ តើលោក មាស វឿន អាចនឹកឃើញដែរឬទេ គឺថានៅពេលនោះគឺមានការវាយចាប់យកឧដុង្គដណ្ដើមយកឧដុង្គនេះពីទាហានសាធារណរដ្ឋវិញ នៅពេលនោះ? តើលោកនឹកឃើញដែរឬទេ នឹកឃើញទេចំណុចហ្នឹង?

[០៩:២៤:១៦]

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំគ្រាន់ថានឹកឃើញអំពីរំដោះឧដុង្គមែន ក៏ប៉ុន្តែចំនួនដែលចាប់បាននោះ ខ្ញុំអត់ដឹង។

**ស៖** ឯកសារនេះទំនងជាបង្ហាញឲ្យយើងឃើញថាប្រជាជនស៊ីវិល ៣០.០០០នាក់ ត្រូវបានគេបណ្ដើរចេញទៅតំបន់ផ្សេង នៅពេលដែលកងកម្លាំងទាហាររបស់ខ្មែរក្រហមវាយដណ្ដើមយកក្រុងឧដុង្គនោះ។ តើចំណុចនេះ គឺត្រឹមត្រូវ និងធ្វើឲ្យលោកនឹកឃើញទេ?

**ឆ៖** បាទ ខ្ញុំនឹកឃើញខ្លះដែរ។ ប្រជាជនគាត់ចេញទៅមែន ក៏ប៉ុន្តែចំនួនរាប់ម៉ឺននាក់នោះ ខ្ញុំមិនបានដឹងចំនួនទេ។

[០៩:២៥:២៥]

**ស៖** ខ្ញុំនៅមានសំណួរមួយទៀតពាក់ព័ន្ធចំណុចនេះ។ តាមលោកយល់ និង ដឹង តើប្រជាជនស៊ីវិលទាំងអស់នេះ បានចាកចេញទៅតំបន់រំដោះនោះដោយស្ម័គ្រចិត្តតាមអ្វីដែលគេចង់ទៅ ឬក៏មិនមែនទេ?

**ឆ៖** បាទ តាមខ្ញុំដឹងថា ប្រជាជនមិនស្ម័គ្រចិត្តទេ ក៏ប៉ុន្តែក្នុងនោះត្រូវតែបង្ខំចិត្តឲ្យគាត់ចេញដោយសារតែការប្រយុទ្ធគ្នាខ្លាំងដោយកាំភ្លើងបាទ។

**ស៖** តើលោកបានទទួលបញ្ជាដែរឬទេ លើបញ្ជានេះ គឺបានទទួលបញ្ជាបង្ខំឲ្យប្រជាជនចាកចេញពីកន្លែងខដុង្គនោះ?

[០៩:២៦:៣២]

**ឆ៖** បាទ អត់មានបញ្ជាទេ គាត់ទៅដោយខ្លួនឯង។

**ស៖** សូមអរគុណ។ ដោយសារពេលវេលា ខ្ញុំបន្តទៅមុខទៀត។ យើងសូមចូលត្រឡប់ពិភាក្សាគ្នាអំពីសមរភូមិនៅក្នុងទីក្រុងភ្នំពេញដែលមានការវាយប្រយុទ្ធនៅថ្ងៃ មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥វិញម្តង។ លោកបានរៀបរាប់ជូនសហព្រះរាជអាជ្ញាជាតិ លោកបានលើកឡើងអំពីការប្រជុំរបស់សេនាធិការ -- អគ្គសេនាធិការជាមួយនឹងមេបញ្ជាការមកពីភូមិភាគ មានការប្រជុំគ្នា។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់សហចៅក្រមស៊ើបអង្កេតនៅក្នុងឯកសារ E3/424 សំណួរទី៣ លោកបាននិយាយថា "មេបញ្ជាការរបស់យោធា ពីខាងបូព៌ា និងខាងនិរតី គឺបានចូលរួមប្រជុំជាមួយនឹងសេនាធិការ គឺ សុន សេន -- តា សុន សេន និង តា នួន ជា ដែលអ្នកទាំងពីនេះធ្វើការប្រជុំជាមួយនឹងមេភូមិភាគទាំងអស់"។ ហើយលោកបានរៀបរាប់ថា "មេបញ្ជាការក្រោយមកគឺបានប្រជុំដើម្បីផ្សព្វផ្សាយព័ត៌មាននេះទៅដល់មេបញ្ជាការកងវរសេនាធំ"។ ខ្ញុំសូមសួរលោកទៅលើចំណុចនេះ តើអ្វីទៅជាអគ្គសេនាធិការនោះ?

[០៩:២៨:៣២]

**ឆ៖** បាទ អង្កាល់ក្នុងពេលដែលប្រជុំនោះ ខ្ញុំមិនដឹងថា មិនស្គាល់ថា អគ្គសេនាធិការទេ ក៏ប៉ុន្តែតាមរយៈប្រធានកងពលគាត់ប្រាប់យើងខ្ញុំ។ គាត់បានទៅប្រជុំ ប៉ុន្តែប្រជុំកន្លែងណានោះខ្ញុំមិនបានដឹងទេ។

**ស៖** ខ្ញុំយល់។ សំណួររបស់ខ្ញុំគឺចង់សួរចំណុចមួយផ្សេងពីនេះ។ តើអគ្គសេនាធិការនេះមានតួនាទីធ្វើអ្វីដែរ?

**ឆ៖** បាទ តាមខ្ញុំយល់ដឹងថា អគ្គសេនាធិការបញ្ជាលើគ្រប់កងពលទាំងអស់នៅក្នុងសមរភូមិ។

**ស៖** ក្រៅពី តា សុន សេន និង តា នួន ជា តើមាននរណាទៀតដែលជាអ្នកនៅក្នុងអគ្គសេនាធិការនេះ?

**ឆ៖** បាទ មាន តាម៉ុក។

[០៩:៣០:០៥]

**ស៖** តើប្រធានកងពល ដូចជាប្រធានកងពលពីខាងលោកនេះ ទទួលបញ្ជាការណែនាំញឹកញាប់ប៉ុនណាដែរ ពីខាងអគ្គសេនាធិការនេះ?

**ឆ៖** បាទ ក្នុងពេលសមរភូមិ ខ្ញុំអត់បានទទួលពីអគ្គសេនាធិការទេ។ ខ្ញុំបានទទួលត្រឹមកងពល និងភូមិភាគ តាស៊ី អ៎! តាម៉ុក។

**ស៖** តើ តាស៊ី ហ្នឹង គឺជាបុគ្គលដែលមានឈ្មោះ ជូ ជេត ហ្នឹងគឺជាមនុស្សតែមួយទេ តើអីចឹងដែរឬទេ?

**ឆ៖** បាទ។ ពីដើម ខ្ញុំហៅតែ តាស៊ី ទេ ប៉ុន្តែឈ្មោះ ជូ ជេត ខ្ញុំទើបតែ ក្នុង ដូចក្នុងសម័យ៣ឆ្នាំនេះឯង។

[០៩:៣១:២៧]

**ស៖** សូមអរគុណ។ លោកបានរៀបរាប់ ថាតើពេលប្រជុំនោះ គេប្រជុំយ៉ាងម៉េច ដើម្បីចែកជូនចែកផ្សាយព័ត៌មាន ក្រោយពីការប្រជុំជាមួយនឹងខាងអគ្គសេនាធិការនោះ? តើនៅពេលដែលលោកចូលប្រជុំជាមួយប្រធានកងពលនោះ លោកបានទទួលបញ្ជាអ្វីខ្លះ ពីកងពល?

**ឆ៖** បាទ ក្នុងការប្រជុំរៀបចំបញ្ជារនោះ កងពលបានទទួលពីអគ្គសេនាធិការ ហើយតមក គឺកងពលបានមកផ្សព្វផ្សាយនៅក្នុងសមរភូមិ មិនមានកន្លែងត្រឹមត្រូវទេ ក្រោមដើមត្នោត ដើមឈើ ពេលយប់។ ពីព្រោះក្នុងពេលនោះ ថ្ងៃប្រជុំអត់បាន បាទ។

**ស៖** សូមអរគុណ។ ដោយសារខ្ញុំពេលខ្លី ខ្ញុំនឹងបន្តទៅដោយឆាប់រហ័ស។ នៅក្នុងចម្លើយនោះ លោកបាននិយាយពីចំណុចដែលយើងបានពិភាក្សាខាងដើមនេះ គឺថាមានឈ្មោះ គឺថាដើម្បីវាយប្រហារ ហើយនិងរំដោះនៅថ្ងៃទី១៨ ខែមេសា។ តើកាលបរិច្ឆេទនេះ តើជាការបរិច្ឆេទ ដែលកំណត់ដោយអគ្គសេនាធិការដែរឬទេ?

[០៩:៣៣:១១]

**ឆ៖** បាទ ក្នុងការដែលកំណត់ថាឲ្យវ៉ៃឈ្នះក្នុងថ្ងៃ១៧ មេសា នោះ គឺជាកំណត់របស់អគ្គសេនាធិការ។ តែដល់វ៉ៃទៅ គឺបានត្រឹម អ៉! ដប់ អ៉! ហ្នឹងហើយបាទ ១៨ វ៉ៃឲ្យ វ៉ៃឈ្នះក្នុង ១៨ មេសា ក៏ប៉ុន្តែដល់ពេលឈ្នះមុនថ្ងៃ១៨ មេសា គឺឈ្នះ ១៧ វិញ។

**ស៖** នៅក្នុងផ្នែកដដែលនេះ លោកបានរៀបរាប់អំពីរបៀប ដែលថាកងទ័ពត្រូវបានគេដាក់បញ្ជាឲ្យធ្វើការវាយប្រហារទីក្រុងភ្នំពេញ ប៉ុន្តែថ្នាក់លើបានបញ្ជាដាច់ខាតថា គឺមិនមែនវាយប្រឆាំងនឹងខ្មាំងដែលលើកទង់ជ័យសទេ។ ថាតើអ្នកណាជាថ្នាក់លើនោះ ដែលលោកនិយាយថា ថ្នាក់លើនៅកន្លែងនេះ តើលោកសំដៅទៅលើអ្នកណា?

**ឆ៖** បាទ សំដៅលើអ្នកដឹកនាំជាន់ខ្ពស់។ ដូចជា តា ម៉ុក, តា សុន សេន ឡើងទៅ។

[០៩:៣៤:៥៨]

**ស៖** តើលោកដឹងដែរឬទេ ថាតើអ្នកណាដែលជាមេដឹកនាំនៅពីលើ តាម៉ុក និង សុន សេន ដែលអគ្គសេនាធិការនោះ?

**ឆ៖** កាលនោះខ្ញុំបាទដឹងតែឈ្មោះ សុន សេន, តាម៉ុក ហើយលោក ខៀវ សំផន ប៉ុណ្ណោះ។

**ស៖** តាមអ្វីដែលលោកយល់ ថាតើលោក ខៀវ សំផន មានតួនាទីអ្វីដែរនៅពេលនោះ?

**ឆ៖** បាទ នៅពេលនោះគាត់ បើខ្ញុំអត់បានជួបគាត់គេ ក៏ប៉ុន្តែខ្ញុំស្តាប់តាមវិទ្យុគាត់ប្រធាន គាត់ជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជាប្រជាធិបតេយ្យ។

**ស៖** ឥឡូវនេះយើងចូលទៅដល់ ការចូលវាយចូលភ្នំពេញដោយជាក់ស្តែងនោះ តើលោកអាចប្រាប់ខ្ញុំបានទេ ថាមានកងពលប៉ុន្មាននាក់ ដែលមកពីភូមិភាគបូព៌ា ក្រៅពីកងពលរបស់លោកនោះ មានកងពលណាទៀត?

**ឆ៖** បាទ ខ្ញុំដឹងថា កងពល មិនស្គាល់លេខអស់ទេ ប៉ុន្តែកាលនោះដឹងថាកងពលរបស់និរតីរបស់បូព៌ា ឧត្តរ ដឹងតែចំណុចបីបួនទិស ប៉ុន្តែកងលេខប៉ុន្មានៗនោះ ខ្ញុំមិនបានចាំទេ បាទ។

[០៩:៣៧:១៧]

**ស៖** ថាតើកងពលទាំងអស់នោះទទួលបញ្ជាដោយអគ្គសេនាធិការដែរឬទេ តាមអ្វីដែលលោកដឹងនោះ?

**ឆ៖** បាទ កាលដែលៗកងពលបានទទួលបញ្ជា គឺទទួលពីតា សុន សេន និង តាម៉ុក។

**ស៖** សូមអរគុណ។ ថាតើកងវរសេនាធំរបស់លោកនោះមានទំហំប៉ុន្មាន នៅថ្ងៃទី១៧ ខែ

មេសា ឆ្នាំ១៩៧៥ នៅពេលដែលលោកវាយចូលភ្នំពេញនោះ?

**ឆ៖** បាទ កងវរសេនាធំខ្ញុំ មានតែមុខសញ្ញាពីពោធិ៍ចិនតុងទៅអូរបែកក្អម និងស្ទឹងមានជ័យ។

**ស៖** សូមអរគុណ។ ចង់សួរថាតើមានកងទ័ពជាយោធាហ្នឹងប៉ុន្មាននាក់ នៅក្នុងវរសេនាធំរបស់លោកនោះ?

**ឆ៖** មាន ៦០០នាក់។

**ស៖** នៅពេលដែលលោក ដែលថាកងទ័ពរបស់លោកចូលមកភ្នំពេញ នៅពេលចូលហ្នឹងដែលថាលោកមាន ៦០០នាក់នោះ?

[០៩:៣៩:១៦]

**ឆ៖** បាទ។

**ស៖** ខ្ញុំនឹងសួរសំណួរឡើងវិញ។ ថាតើនៅពេលណាដោយជាក់ស្តែង តើថ្ងៃណាដែលកងទ័ពរបស់លោកវាយចូលដល់ភ្នំពេញនោះ?

**ឆ៖** បាទ ថ្ងៃ១៧ មេសា ៧៥។

**ស៖** ថាតើលោកចាំដែរឬទេនៅពេលព្រឹក ឬក៏ពេលថ្ងៃ ម៉ោងប៉ុន្មាន នៅក្នុងថ្ងៃ១៧ មេសានោះ?

**ឆ៖** បាទ ខ្ញុំចាំមិនច្បាស់ ក៏ប៉ុន្តែប្រហែលជាម៉ោង៩ព្រឹក ទៅ១០ ព្រឹក។

**ស៖** នៅពេលដែលលោកចូលដល់នោះ តើយោធារបស់លោក និងយោធារបស់កងពលផ្សេងទៀតចូលក្នុងពេលដំណាលគ្នា ឬក៏មុន ឬក៏ក្រោយគ្នាយ៉ាងដូចម្តេច ការចូលដល់ទីក្រុងភ្នំពេញនេះ?

**ឆ៖** បាទ ខាងកងពល ខាងខ្ញុំរួមគ្នា គឺចូលក្រោយខាងកងពលឧត្តរ -- អ៊ូ! ក្រោយបូព៌ា។

**ស៖** តើលោកបានទទួលបញ្ជាថាតើត្រូវចូលទៅកន្លែងណា? ទីតាំងណាត្រូវវាយដណ្តើម? ថាតើត្រូវចូលទីតាំងណាដែរទេ នៅពេលដែលចូលដល់ភ្នំពេញភ្លាមៗនោះ?

**ឆ៖** បាទ តាមទិសដែលត្រូវចូល គឺចូលទៅសំដៅអគ្គសេនាធិការរបស់លន់ នល់។

[០៩:៤២:១៤]

**ស៖** តើលោកបានចូលទៅដល់អគ្គសេនាធិការរបស់ទាហានលន់ នល់ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំចូលអត់ដល់ទេ។ ខាងបូព៌ាចូលទៅដល់មុន ហើយនិងឧត្តរ។

**ស៖** តើលោកចូលទៅដល់កន្លែងណា នៅថ្ងៃទី១៧ ខែមេសានោះ? តើផ្នែកណាមួយនៃទីក្រុង

ដែលកងទ័ពរបស់លោកចូលទៅដល់?

**ឆ៖** បាទ ខាងខ្ញុំចូលដល់ត្រឹមតែបុរីកីឡា មកលិចប៉ុណ្ណឹង។

**ស៖** នៅកន្លែងនោះ តើលោកឈរជើងនៅកន្លែងនោះអស់រយៈពេលប៉ុនណា ដែលថានៅខាងបុរីកីឡានោះ ពីបុរីកីឡាមកខាងលិចនោះ?

**ឆ៖** បាទ បានមួយយប់មួយថ្ងៃ។

**ស៖** ម្សិលមិញលោកបានឆ្លើយទៅសហព្រះរាជអាជ្ញាជាតិថា លោកបានចូលដល់ទីក្រុង។ ទីក្រុងអង្កាល់នោះគឺនៅស្ងាត់ជ្រងំ តើមានន័យថា មិនមានៗការវាយប្រយុទ្ធតទៅទៀតទេ រវាងកងទ័ពរបស់លោក ហើយនិងកងទ័ពរបស់សាធារណរដ្ឋខ្មែរនោះ របស់លន់ នល់នោះ?

[០៩:៤៤:១២]

**ឆ៖** សូមលោកមានប្រសាសន៍ម្តងទៀត!

**ស៖** បាទ ខ្ញុំនឹងសួរឡើងវិញ។ កាលម្សិលមិញលោកបានឆ្លើយតំណាងសហព្រះរាជអាជ្ញាជាតិថា ទីក្រុងពេលចូលមកដល់ គឺស្ងាត់ នៅពេលដែលលោកចូលមកដល់នោះ។ សំណួររបស់ខ្ញុំគឺសួរថា តើនៅមានការវាយប្រយុទ្ធគ្នាទៀតដែរឬទេ នៅថ្ងៃទី១៧ ខែមេសា នៅពេលដែលលោកចូលដល់ទីក្រុងនោះ? ថាតើកងទាហានរបស់លន់ នល់ នៅតស៊ូច្បាំងតបវិញទេ?

**ឆ៖** បាទ អត់មានទេ។ អត់មានច្បាំងតទៀតទេ មិនមានផ្ទុះកាំភ្លើងតទៀត។ ប្រជាជននៅក្នុងក្រុងក៏នៅតែលើផ្ទះស្ងាត់ស្ងៀមទាំងអស់។

**ស៖** លោកនិយាយថា លោកបានឈរជើងនៅក្នុងទីក្រុងនៅថ្ងៃទី១៧ ខែមេសា នោះ។ តើលោកបានឃើញជនស៊ីវិលណាម្នាក់ដែរឬទេ ដែលកំពុងចាកចេញពីផ្ទះរបស់គេ ឬក៏បានឃើញប្រជាជនស៊ីវិលនៅតាមផ្លូវដែរឬទេនៅថ្ងៃនោះ?

**ឆ៖** បាទ គ្មានទេ អត់មានដើរឆ្វេចឆ្វាចទេ នៅតែតាមផ្ទះ។

[០៩:៤៦:០២]

**ស៖** ម្សិលមិញលោកបានឆ្លើយសហព្រះរាជអាជ្ញាជាតិថា លោកបានឮថា គេតម្រូវឲ្យប្រជាជនចាកចេញពីទីក្រុង ហើយលោកបានអនុញ្ញាតឲ្យពួកគេចេញនៅក្នុងពេលដែលពួកគេត្រូវជម្លៀសចេញនោះ។ តើលោកបានឃើញប្រជាជនចាកចេញពីទីក្រុងទេនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥នោះ?

**ឆ៖** បាទ ខ្ញុំឃើញគាត់ចេញ ពីព្រោះខ្ញុំនៅក្នុងក្រុងនោះបាន១យប់១ថ្ងៃ តាម៉ុកឲ្យខ្ញុំដកមកនៅ

ស្ទឹងមានជ័យនេះទាំងអស់វិញ។ ១ថ្ងៃក្រោយមកបានឃើញប្រជាជនគាត់ចេញមកតាមផ្លូវ មកផ្លូវលេខ ៣ ផ្លូវលេខ៤ អ៊ីចឹងមក។

**ស៖** សូមអរគុណ។ តើអ្នកណាជាអ្នកប្រាប់លោកដែលថា គេតម្រូវឱ្យប្រជាជនចេញពីទីក្រុងនោះ?

**ឆ៖** បាទ ខ្ញុំអត់មានឮអ្នកណាប្រាប់ទេ។ ប្រជាជនគាត់ប្រាប់ ខ្ញុំនៅហ្នឹងផ្លូវហ្នឹង គឺថាឱ្យគាត់ចេញមកតាមផ្លូវហ្នឹងទាំងអស់។ ប្រជាជនគាត់ប្រាប់ខ្ញុំ។

[០៩:៤៧:៣៦]

**ស៖** តើលោកបានសួរអ្នកណាម្នាក់ទាក់ទងទៅនឹងមូលហេតុដែលគេចាកចេញពីទីក្រុងដែរឬទេ?

**ឆ៖** ខ្ញុំអត់បានសួរទេ គាត់ប្រាប់ខ្ញុំថា គេឱ្យចេញ កងទ័ពថាឱ្យចេញតាមផ្លូវ តៗគ្នាអ៊ីចឹងមក។

**ស៖** តើមានជនស៊ីវិលណាម្នាក់ដែលគេអនុញ្ញាតឱ្យរស់នៅក្នុងទីក្រុងដែរឬទេនៅពេលនោះ?

**ឆ៖** ខ្ញុំមិនបានដឹងដែរ។

**ស៖** នៅថ្ងៃបន្ទាប់មកទៀត តើលោកធ្លាប់បានឃើញថា ប្រជាជននៅទីក្រុងភ្នំពេញនោះត្រូវបានគេតម្រូវឱ្យចាកចេញពីទីក្រុងដែរឬទេ?

**ឆ៖** ខ្ញុំអត់បានដឹងផែនការគេតម្រូវឱ្យប្រជាជនចេញទេ។

[០៩:៤៩:២០]

**ស៖** ខ្ញុំយល់ហើយគឺថាលោកមិនបានទទួលដឹងអំពីផែនការនោះ ប៉ុន្តែនៅក្នុងប៉ុន្មានថ្ងៃ ក្រោយពីថ្ងៃ១៧ មេសា មួយសប្តាហ៍ក្រោយ ឬក៏មួយខែក្រោយមក តើលោកបានចង់ដឹង ឬក៏មានពិភាក្សាអំពីការជម្លៀសដើម្បីរកមូលហេតុថា ហេតុអ្វីបានជាគេជម្លៀសហ្នឹងដែរឬទេ?

**ឆ៖** បាទ មានកងពលគាត់ប្រាប់ខ្លះ តែមិនបានប្រជុំទេ គាត់ថាប្រជាជនដែលចេញពីភ្នំពេញ ១អាទិត្យ ដើម្បីកុំឱ្យមានការច្របូលច្របល់ជាមួយនឹងកងទ័ពសាធារណរដ្ឋ លន់ នល់ ហើយកាលណារៀបចំស្រួលបួលបានឱ្យគាត់ចូលវិញ។

**ស៖** សូមអរគុណ។ ខ្ញុំមានសំណួរចុងក្រោយមួយទាក់ទងបញ្ហានេះ ថាតើមេបញ្ជាការកងពលប្រាប់លោកនៅពេលណា ដែលថាគេនឹងជម្លៀសប្រជាជនតែ១អាទិត្យទេ ក្រោយមកគេឱ្យចូលវិញនោះ គេប្រាប់លោកពេលណា?

**ឆ៖** ប្រាប់ ខ្ញុំមិនបានដឹងថ្ងៃទេ ខែទេ ក៏ប៉ុន្តែក្នុងពេលដែលៗឃើញប្រជាជនចេញហើយ ក្រោយមកប្រហែលជា១អាទិត្យបានគាត់ប្រាប់ខ្ញុំ។

**សៈ** សូមអរគុណ។ នៅពេលនោះ លោកបានទទួលបញ្ជាពី តាម៉ុក ឱ្យចាកចេញពីទីក្រុង បន្ទាប់មកតើលោកទៅឈរជើងនៅកន្លែងណា ទាំងកងទ័ពរបស់លោកនោះ? តើការទទួលខុសត្រូវរបស់លោកកាលនោះ គេឱ្យធ្វើអ្វីទៀត?

[០៩:៥១:៥៤]

**ឆ៖** បាទ ក្រោយពីរំដោះហើយ គេឱ្យខ្ញុំចេញពីៗក្រុងភ្នំពេញនោះ គឺ តាម៉ុក ឱ្យខ្ញុំមកធ្វើស្រែនៅកំបូល។

**សៈ** លោកបាននិយាយថា គេប្រាប់ឱ្យលោកចាកចេញក្នុងរយៈពេល១សប្ដាហ៍ ចុះក្រោយពី១សប្ដាហ៍នោះ គេបង្គាប់ ឬក៏បញ្ជាឱ្យលោកទៅកន្លែងណាទៀត ហើយធ្វើអ្វី ឱ្យទៅធ្វើអ្វី?

**ឆ៖** បាទ ក្រោយពីធ្វើស្រែនៅកំបូលមិនទាន់ចប់សព្វគ្រប់ មិនទាន់បានដកស្ទូងផង គាត់បញ្ជូនខ្ញុំទៅកំពង់ត្រាច។ មួយវរសេនាធំប្រហែលជា៦០០នាក់។

**សៈ** ឥឡូវនេះលោកបានជម្រាបទៅអ្នកស៊ើបអង្កេតនៅក្នុងចម្លើយទី១ របស់លោកគឺ E3/242 អ៊ំ! 424 នៅក្នុងសំណួរ និងចម្លើយទី៦ គឺថាក្រោយពីឈរជើងនៅកំពង់ត្រាច នៅខេត្តកំពត ថ្នាក់លើបានបញ្ជូនកងវរសេនាធំផ្លាស់លោកទៅកោះកុងអស់រយៈពេល៣ឆ្នាំ។ តើលោកនៅចាំដែរឬទេថា ខែឆ្នាំដែលគេផ្លាស់ទៅកោះកុងហ្នឹង ខែណា ឆ្នាំណា?

**ឆ៖** ផ្លាស់ខ្ញុំចេញទៅកំពង់ត្រាច ឆ្នាំ៧៥ ខ្ញុំអត់ចាំខែទេ។ ខ្ញុំអត់ចាំខែ។ ចេញពីកំពង់ត្រាចទៅទៀត ទៅកោះកុង ឆ្នាំ៧៧១បាទ។ ខែខ្ញុំអត់ចាំទេ។

[០៩:៥៤:៤៩]

**សៈ** ខ្ញុំចង់ឱ្យលោកពិនិត្យមើលថា តើរយៈពេលដែលថាលោកទៅកំពង់ត្រាចនៅក្នុងឆ្នាំ១៩៧៥ បន្ទាប់មកលោកនិយាយ "លោកទៅកោះកុងនៅឆ្នាំ១៩៧៧"។ ខ្ញុំពិនិត្យមើលចម្លើយទី២របស់ -- ចម្លើយទី២របស់លោកៗទៅការិយាល័យសហចៅក្រមស៊ើបអង្កេតគឺថា E3/80 លោកនិយាយថា "លោកទៅកោះកុងនៅខែធ្នូ ឆ្នាំ១៩៧៦"។ តើលោកអាចនឹកឃើញឱ្យច្បាស់អំពីឆ្នាំហ្នឹងដែរឬទេ? ថាតើៗលោកនៅកំពតអស់រយៈពេលប៉ុន្មានមុននឹងទៅកោះកុងនោះ?

**ឆ៖** បាទ ទៅកំពតជិត១ឆ្នាំ ប្រហែលជា១០ -- បីដណ្ដប់ខែនៅកំពត ហើយគាត់ផ្លាស់ខ្ញុំពីកំពត

ទៅទៀត ទៅកោះកុង បាទ ប្រាំមួយ -- ដើម -- ចុងឆ្នាំ៧០ -- ដើមឆ្នាំ៧៦។ ហ្នឹងហើយជិតចូល៧៧ ហើយបាទ។ ចាំមិនច្បាស់។

[០៩:៥៦:៤០]

**ស៖** សូមអរគុណដែលលោកសាក្សីបានព្យាយាមឆ្លើយមកខ្ញុំនេះ។ កាលពីម្សិលមិញលោកបានឆ្លើយទៅសហព្រះរាជអាជ្ញាជាតិថា នៅពេលដែលលោកបានទៅកោះកុងនោះ គេបានផ្លាស់លោកទៅជាមួយនិងកងវរសេនាធំ មួយកងវរសេនាធំកន្លះ ហើយនៅក្នុងចម្លើយទី១ របស់លោកទៅអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនោះ នៅក្នុងសំណួរ និងចម្លើយទី១ E3/80 នោះលោកបាននិយាយថា "ប្រហែលជាមានកងទ័ព ៗប្រហែលជា២.៧០០នាក់"។ តើត្រឹមត្រូវដែរឬទេនៅពេលដែលគេផ្លាស់លោកទៅកន្លែងនោះ គឺទៅទាំងកងទ័ព ២.៧០០នាក់ផង?

**ឆ៖** បាទ ២.៧០០នាក់ ហ្នឹងយកទៅជាប់ខ្ញុំមែន ប៉ុន្តែបានប្រហែលជា១ខែគ្រុនចាញ់ មកវិញអស់ នៅសល់តែប្រហែលជា ៧០០, ៨០០នាក់។

[០៩:៥៨:១២]

**ស៖** ចាតើទំហំកងទ័ពនុំងប៉ុនណាដែលលោកទទួលបញ្ជា ដែលលោកបញ្ជានៅកោះកុងចាប់ពីឆ្នាំ១៩៧៦ តទៅនោះ?

**ឆ៖** ២.៧០០នាក់។

**ស៖** សូមអរគុណ។ លោកក៏បានប្រាប់អ្នកស៊ើបអង្កេតផងដែរថា នៅក្នុងចម្លើយទី១ របស់លោកគឺ E3/424 នោះគឺសំណួរនិងចម្លើយទី៧ ថា "នៅពេលដែលធ្វើការនៅកោះកុង លោកបានក្លាយទៅជាអនុបញ្ជាការនៃកងពលទី១"។ តើអ្នកណាជាអ្នកចាត់តាំងរបស់លោក អ្នកណាជាអ្នកចាត់លោកឲ្យធ្វើជាអនុបញ្ជាការកងលេខ១ នេះ?

**ឆ៖** បាទ ការចាត់តាំងគឺ ប្រធានកងពល និងយុទ្ធភូមិភាគបស្ចិម។

[០៩:៥៩:៤០]

**ស៖** ឥឡូវនេះយើងដឹងថា សឿង ជាមេបញ្ជាការកងពល តាមអ្វីដែលលោកឆ្លើយពីម្សិលមិញនោះ ហើយនៅក្នុងចម្លើយរបស់លោកដែលខ្ញុំបានអានខាងដើមនេះ នៅក្នុងសំណួរចម្លើយទី៦ លោកនិយាយថា លេខាភូមិភាគបស្ចិមហ្នឹង គឺ ជូ ជេត ហៅ ស៊ី។ តើនេះជាបុគ្គល ជាលេខាតំបន់ ដែលជាអ្នកចាត់តាំងឲ្យលោកធ្វើមេបញ្ជាការ រួមទាំងចាត់តាំងលោក សឿង ផងនោះ?

**ឆ៖** បាទ។

**ស៖** សូមអរគុណ។ លោកបានចង្អុលបង្ហាញផងដែរថា នៅក្នុងចម្លើយដដែលនេះ នៅក្នុង E3/424 សំណួរចម្លើយទី៦ គឺ "តាសឿង ក្លាយទៅជាមេបញ្ជាការកងពលលេខ១ ហើយក៏ជាសមាជិកនៃគណៈតំបន់នោះ -- គណៈភូមិភាគផងដែរ"។ តើអ្នកណាជាចាត់តាំងគាត់ឲ្យគាត់ធ្វើជាសមាជិកនៃគណៈកម្មាធិការភូមិភាគនេះ?

[១០:០១:១២]

**ឆ៖** បាទ បើតាមខ្ញុំដឹងខ្លះៗ មាន តាម៉ុក។

**ស៖** សំណួរ និងចម្លើយបន្ទាប់នៅក្នុងចម្លើយរបស់លោក នៅក្នុងឯកសារ E3/424 នៅត្រង់សំណួរ និងចម្លើយទី៧ នៅកន្លែងនេះ លោកឆ្លើយថា "នៅក្នុងខេត្តកោះកុង កងទ័ពមានតួនាទីការពារព្រំដែនសមុទ្រ និងព្រំដែនគោក ហើយក៏មានការវាយប្រយុទ្ធជាមួយកងទ័ពថៃរយៈពេល១អាទិត្យជាប់គ្នា"។ តើការវាយប្រហារនេះ ជាការទទួលខុសត្រូវរបស់លោក ដើម្បីការពារព្រំដែនសមុទ្រ និងព្រំដែនគោកដែរឬទេ?

**ឆ៖** បាទ មែន។

**ស៖** ពាក់ព័ន្ធទៅនឹងការពារ ការការពារព្រំដែនសមុទ្រ តើលោកការពារដោយរបៀបណាដែរនៅព្រំដែនសមុទ្រនោះ គឺដោយមធ្យោបាយណាដែរ?

**ឆ៖** បាទ ក្នុងពេលដែលការពារព្រំដែនទឹក និងសមុទ្រនោះ មានកប៉ាល់ មានកម្លាំងថ្មើរជើងដាក់តាមកោះ តាមដីគោក ហើយនិងមានកប៉ាល់ទឹកចល័តយប់ថ្ងៃ។

[១០:០៣:៥៥]

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់សហចៅក្រមស៊ើបអង្កេត ឯកសារ E3/80 សំណួរចម្លើយទី១ នៅក្នុងនោះ លោកបានឆ្លើយថា "មានហេតុការណ៍មួយទៀត ដែលប្រជាជនខ្មែរនោះចង់រត់ទៅប្រទេសថៃ"។ តើលោកអាចរៀបរាប់បានដែរឬទេ ព្រឹត្តិការណ៍មួយហ្នឹង គឺព្រឹត្តិការណ៍អ្វីដែរដែលធ្វើឲ្យបងប្អូនខ្មែរយើងនោះ ចង់រត់ទៅប្រទេសថៃនោះ?

**ឆ៖** បាទ មុនពេលដែលខ្ញុំទៅកាន់កាប់សមរភូមិកោះកុងនោះ ប្រជាជនគេត្រូវជម្លៀសចេញពីក្រុង ពីក្នុងក្រុងខេត្ត កាលណោះ គេហៅ ក្រុងខេត្តខេមរភូមិន្ទ ចេញអស់ហើយ ពីត្រពាំងរូងចេញ គេជម្លៀសរួចអស់ហើយ តាមកោះ ដែលគាត់នៅតាមកោះ ក៏គេជម្លៀសចេញមកនៅខាងក្រោយអស់

ហើយ គឺពិសេសមកនៅឯព្រៃនប់ ស្រែអំបិលវិញទាំងអស់។ ខ្ញុំអត់មានប្រជាជននៅទីនោះទេ នៅសុទ្ធតែពួកកងទ័ពទាំងអស់។

**សៈ** តើលោកដឹងដោយរបៀបណាដែលថា ប្រជាជនខ្មែរនោះចង់រត់ទៅថៃនោះ? ដឹងដោយរបៀបណាដែរ?

[១០:០៥:៣៨]

**ឆៈ** បាទ ខ្ញុំអត់បានដឹងថា គាត់រត់ទៅរបៀបណាទេ ប៉ុន្តែយើងដើរទៅ ជួនកាលយើងជួបតាមព្រៃ តាមផ្សៃទៅ ខ្លះទៅក៏យកគាត់មកវិញមក។ ហើយក៏មិនមានផ្លូវសម្រាប់នឹងចេញ រត់នោះផង មានតែ -- បើអត់មានទូក អត់មានកាណូតឆ្លង អត់មានព្រំដែនគោកឆ្លង គាត់ក៏មិនសូវរត់ដែរតាមផ្លូវហ្នឹងនោះ បាទ។

**សៈ** តើស្ថានភាពនេះវាកើតឡើងញឹកញាប់ប៉ុនណាដែរ ដែលលោកថាលោកដើរទៅឃើញប្រជាជនដែលចង់រត់គេចទៅថៃនោះ ហើយបន្ទាប់មកលោកប្រមូលមកយកវិញនោះ? តើលោកឃើញញឹកញាប់ប៉ុនណាដែរ?

**ឆៈ** មិនសូវឃើញញឹកញាប់ទេ ជួនកាលឃើញមួយ តាមផ្លូវអ៊ីចឹងទៅ គាត់ដើរអត់បាយ យើងទៅយកគាត់មកវិញមក ហើយយកមកដាក់ឲ្យបាយគាត់ហូប នៅកន្លែងយោធាទៅ ហើយឲ្យគាត់បញ្ជូនគាត់មកតាម -- មកក្រោយវិញ មកតាមកន្លែងសហករណ៍គេវិញមក។

**សៈ** តើលោកបានទទួលបញ្ជា ថាឲ្យលោកធ្វើអ្វីខ្លះដែរឬទេ ប្រសិនបើជួបប្រជាជនដោយចៃដន្យដូច្នេះនោះ? តើមានទទួលបញ្ជាឲ្យចាត់ការយ៉ាងម៉េចលើពួកគាត់ដែរឬទេ?

[១០:០៧:៣៩]

**ឆៈ** បាទ អត់មានបញ្ជាពីណាទេ ខ្ញុំឃើញថាបើដើរជួបគាត់ទៅ ក៏យកមកគាត់ ហើយក៏រាយ-ការណ៍មកកងពលមក កងពលគាត់ថាឲ្យបញ្ជូនគាត់មកខាងក្រោយមក ក៏បញ្ជូនមក បាទ។

**សៈ** តើលោករាយការណ៍ទៅកងពលនេះដោយមធ្យោបាយណាដែរ? តើលោកប្រើឧបករណ៍អ្វី? ប្រើអ្វីរាយការណ៍ទៅកងពលនោះ?

**ឆៈ** បាទ គេប្រើ មានវិទ្យុ តេអូ ហើយនិងទូរលេខ ប្រើតាមលេខ សារទូរលេខ ដឹងគេហៅអីហ្នឹង។

**សៈ** ដូច្នេះតាមអ្វីដែលខ្ញុំយល់នោះ គឺលោកទាក់ទងជាមួយនឹង តាសឿង តាមវិទ្យុតេអូ និង

សារទូរលេខនៅកោះកុង តើអ៊ីចឹងដែរឬទេ?

**ឆៈ** បាទ អ៊ីចឹង។

[១០:០៩:៣០]

**សៈ** កាលពីម្សិលមិញ នៅពេលដែលតំណាងសហព្រះរាជអាជ្ញាជាតិបានសួរសំណួរទៅកាន់លោក លោកបានឆ្លើយថា "ក្នុងខណៈពេលដែលលោកធ្វើការការពារព្រំដែនសមុទ្រនៅពេលនោះ លោកទទួលបញ្ជាពីកងពល ហើយកងពលទទួលបញ្ជាមកពីអគ្គសេនាធិការ"។ តើអ្វីដែលខ្ញុំយល់តាមចម្លើយរបស់លោក គឺលោកបានឆ្លើយអ៊ីចឹងតើមែនដែរឬទេ?

**ឆៈ** បាទ អ៊ីចឹងមែន។

**សៈ** តើលោកដឹងទេ កងពលនោះទាក់ទងជាមួយនឹងអគ្គសេនាធិការនោះ ដោយមធ្យោបាយណា គឺគេប្រើសារទូរលេខដែរ ឬក៏គេមានមធ្យោបាយទាក់ទងផ្សេង?

**ឆៈ** បាទ គេប្រើសារទូរលេខផង ហើយគេមានមធ្យោបាយដោយឡាន អាចជួប គាត់ទៅជួបអគ្គសេនាធិការបាន។

**សៈ** តើលោកចាំទេថា តើនរណាគេដែរដែលទទួលបន្ទុកខាងសេនាធិការនោះ?

**ឆៈ** បាទ ខាងសេនាធិការដែលទទួលបន្ទុកគឺលោកសុន សេន និងតាម៉ុក។

[១០:១១:៣៤]

**សៈ** តើលោកធ្លាប់ទទួលបញ្ជាពីអគ្គសេនាធិការដែរឬទេ?

**ឆៈ** បាទ ខ្ញុំអត់បានទទួលបញ្ជាផ្ទាល់ទេ។ ទទួលផ្ទាល់ត្រឹមតែពីលេខាកងពល។

**សៈ** លោកបានជម្រាបជូនយើងខ្ញុំថា លោកទទួលភារៈការពារព្រំដែនសមុទ្រ ដូចដែលលោកបានរៀបរាប់ថាមានកងទ័ព ហើយនិងកប៉ាល់យាមកាមតាមកោះផងដែរ។ ក្រៅពីការងារនេះ ការពារកោះនេះ ថាតើលោកបានទទួលភារៈការពារកោះទាំងអស់ យាមកាមកោះទាំងអស់តែម្តងនៅខេត្តកោះកុង ឬក៏មានកងពលផ្សេងជាអ្នកទទួលបន្ទុកការពារកោះផ្សេងទៀតដោយឡែក?

**ឆៈ** បាទ មុខសញ្ញាខ្ញុំទទួលត្រឹមពីកោះស្តេច កោះកុង ទាល់គ្នានឹងកោះយ៉ និងព្រំដែនគោកថៃ។

[១០:១៣:២៥]

**សៈ** ចុះចំណែកកោះផ្សេងទៀតវិញ នៅខាងត្បូងៗឯណោះវិញ ពីកន្លែងរបស់លោក តើមាន

កងពល ឬក៏អង្គភាពណាមួយជាអ្នកទទួលការការពារ?

**ឆ៖** បាទ ចំណុចពីកោះស្ដេច មកកោះរុង មកត្បូង ទាល់គ្នាកំពង់សោម ទៅកោះតាំង ពូលូវៃ មានកងពលគេដទៃទៀត ប្រហែលជាកងពលលេខ៣ របស់ តាមុត។

**សៈ** តើលោកមានធ្វើការសម្របសម្រួលការងាររបស់លោកជាមួយនឹងកងពលលេខ៣ ដែរឬទេ ឬក៏លោកទាក់ទងគ្នាជាមួយនឹងកងពលលេខ៣ ដែរឬទេ?

**ឆ៖** បាទ មានការទាក់ទងភ្ជាប់គ្នាត្រឹមតែវរសេនាធំ ឯកងពល លេខាកងពលរបស់គេ គេអត់ដែលមកជួបយើងទេបាទ។

[១០:១៥:០២]

**សៈ** តើទាក់ទងជាមួយនឹងវរសេនាធំនោះ ទាក់ទងលើការងារអ្វីខ្លះដែរ?

**ឆ៖** ទាក់ទងសហការជាមួយកងពលលេខ៣ហ្នឹង មានវរសេនាធំ ខ្ញុំមិនចាំឈ្មោះទេ ក៏ប៉ុន្តែព្រំប្រទល់ដើម្បីសហការគ្នា ដើម្បីស្គាល់គ្នាតាមអង្គភាពនីមួយៗ ដើម្បីយល់កិច្ចការគ្នា កុំឲ្យមានប៉ះពាល់អ្វីណាមួយក្នុងអង្គភាពបាទ។

**សៈ** លោកបានរៀបរាប់ថា លោកទាក់ទងតាមសារទូរលេខជាមួយ តាសឿង ហើយលោកក៏បានឆ្លើយចំណុចហ្នឹងនៅក្នុងចម្លើយរបស់ចៅក្រមស៊ើបអង្កេត ឯកសារ E3/73 ត្រង់សំណួរចម្លើយលេខ៣ និងលេខ៦។ នៅក្នុងចម្លើយសំណួរលេខ៦ លោកបាននិយាយថា "ខ្ញុំច្រើនតែរាយការណ៍តាមសារទូរលេខជូនប្រធានកងពលក្នុងរយៈពេល៣ ឬ៤ខែ បើមានការប្រជុំនៅភូមិភាគទើបខ្ញុំមកចូលរួម។ ពីព្រោះនៅកោះកុងឆ្ងាយពេក ពិបាករកមធ្យោបាយធ្វើដំណើរទៅមក តាមផ្លូវសមុទ្រ"។ ហើយប្រយោគ ចុងក្រោយសរសេរថា "ការរាយការណ៍តាមសារទូរលេខ គឺរាយការណ៍ប្រចាំថ្ងៃ ប្រសិនបើមានសភាពការណ៍ព្រំដែនទាក់ទងជាមួយនឹងថៃ"។ ខ្ញុំសួរអំពីបញ្ហាសារទូរលេខសិន តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលថា លោករាយការណ៍ប្រចាំថ្ងៃទៅឲ្យ សឿង ប្រសិនបើមានសភាពការណ៍ព្រំដែនទាក់ទងជាមួយនឹងប្រទេសថៃនោះ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

[១០:១៧:៣៩]

**សៈ** តើលោកទាក់ទងតាមសារទូរលេខជាមួយនឹងកងវរសេនាធំនៅក្នុងកងពលលេខ៣ផងដែរ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** តើ តាសឿង ធ្លាប់មកកោះកុងចេញបញ្ជាដោយផ្ទាល់ ត្រួតពិនិត្យលើលោកដោយផ្ទាល់ ទៅដល់លោកដែរឬទេ?

**ឆ៖** បាទ តាំងពីខ្ញុំនៅអស់រយៈ៣ឆ្នាំមក គាត់ទៅតែម្ដង។

**ស៖** ពាក់ព័ន្ធទៅនឹងការងាររបស់លោក ការពារព្រំដែនសមុទ្រ និងការពារព្រំដែនគោក ព្រំដែនកោះ ថាតើធ្លាប់មានហេតុការណ៍ណាមួយដែលលោកធ្លាប់ចាប់ទូកនៅតាមសមុទ្រដែរឬទេ?

**ឆ៖** បាទ ចាប់បានខ្លះដែរ ទូករបស់ថៃ នេសាទត្រី។

**ស៖** តើហេតុអ្វី មានហេតុផលអ្វីដែរ ដែលចាប់ទូកនេសាទថៃនោះ?

**ឆ៖** បាទ មកពីថៃរំលោភអូសត្រី ចាប់ត្រីនៅក្នុងសមុទ្រយើងជ្រៅ។

[១០:២០:១៦]

**ស៖** តើគេមានចេញបញ្ជាឲ្យលោកធ្វើការចាប់ទូកនេសាទទាំងអស់នេះដែរឬទេ ប្រសិនបើបើកចូលមកជ្រៅក្នុងទឹកដីកម្ពុជានោះ?

**ឆ៖** បាទ គេបញ្ជា កងពលគេបញ្ជាមក។

**ស៖** តើគេឲ្យលោកធ្វើអ្វីទៀតនៅពេលដែលចាប់បានទូកនោះហើយនោះ?

**ឆ៖** បាទ បើចាប់បានទូកហើយ គេឲ្យខ្ញុំយកមកទុក ហើយបើមានមនុស្សនៅលើទូក គេឲ្យខ្ញុំបញ្ជូនមកកំពង់សោម។

**ស៖** បាទ ខ្ញុំសូមសួរថា តើបញ្ជូនទៅកំពង់សោមហ្នឹង បញ្ជូនទៅម្ដុំណាដែរ?

**ឆ៖** បាទ បញ្ជូនមកកន្លែង តាសឿង ប្រធានលេខាកងពល។

[១០:២១:៥៤]

**ស៖** តើ តាសឿង នេះក៏មានស្នាក់ការរបស់គាត់នៅកំពង់សោមផងដែរ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទទីស្នាក់ការគាត់នៅព្រៃនប់ទេ ក៏ប៉ុន្តែគាត់ចំណាំតែចេញចូលទៅកំពង់ផែកំពង់សោម។ យើងបញ្ជូនតាមមកកំពង់សោមមក។

**ស៖** តើលោកធ្លាប់ជជែកជាមួយនឹង សឿង និយាយគ្នាជាមួយនឹង សឿង ថាតើអ្នកជាអ្នកនេសាទនោះ មានអ្វីកើតឡើងចំពោះពួកគេ ក្រោយពីបញ្ជូនទៅដល់កំពង់សោមហើយនោះ?

**ឆ៖** បាទ ខ្ញុំអត់បានជជែកអ្វី ឬក៏ប្រាប់អ្វីជាមួយគាត់ទេ ប្រាប់គ្រាន់ថាមនុស្សដែលចាប់បាន

ជាតិថៃគឺបញ្ជូនមកគាត់តែប៉ុណ្ណឹង ហើយខ្ញុំនឹងទៅកន្លែងវិញ។

**ស៖** សូមអរគុណ។ តើលោកធ្លាប់ជួបប្រទះឃើញមានទូកវៀតណាមចូលមកដែរឬទេ?

**ឆ៖** បាទ យូរៗឃើញម្តងដែរនៅ -- ជួនកាល១ខែ ២ខែ អីឃើញមកម្តង ក៏ប៉ុន្តែជួនកាលចាប់បានទូកអីចឹងទៅ ជួនកាលគេទៅហួសទៅ។

**ស៖** អ្នកដែលលោកចាប់បាននោះ តើប្រជាជននៅក្នុងទូកហ្នឹង នៅលើទូកហ្នឹងជាប្រជាជនប្រភេទណាដែរ?

**ឆ៖** ប្រជាជនវៀតណាម មានស្រី មានកូន មានប្រុសប្តី-ប្រពន្ធគេមិនដឹង។ ប៉ុន្តែទូកតូចៗមិនជាធំប៉ុន្មាន។

[១០:២៤:៣៦]

**ស៖** តើលោកបានធ្វើអ្វីខ្លះទៅដល់អ្នកដែលជាជនជាតិវៀតណាមស្ត្រី បុរសនោះ តើលោកបានបំពេញការងារអ្វីខ្លះចំពោះពួកគាត់?

**ឆ៖** បាទ បញ្ជូនតាមរយៈមកកំពង់សោមដែរ។

**ស៖** តើលោកដឹងទេ អ្នកដែលនៅក្នុងទូកទាំងអស់នុ៎ង គាត់ធ្វើអីដែរ? គាត់ជាអ្នកនេសាទ ឬក៏គាត់ធ្វើសកម្មភាពផ្សេងៗ?

**ឆ៖** បាទ គាត់ទៅស្រុកថៃ គាត់តម្រង់ទៅស្រុកថៃ។ ហើយគាត់មិនសូវចេះខ្មែរផង ក៏ខ្ញុំមិនសូវចេះស្តាប់បានភាសាវៀតណាម បាទ។

**ស៖** សូមអរគុណដែលលោកបានឆ្លើយលម្អិតទៅលើចម្លើយរបស់លោកនេះ។ តើលោកដឹងទេ ហើយអ្វីបានជាចាប់ទូកទាំងអស់នេះ?

**ឆ៖** បាទ ការដែលយើងចាប់មកពីទូកមកតាមឆ្នេរចូលដែនសមុទ្រយើង យើងត្រូវតែមានការចាប់ដើម្បីសួរសាកដែរ។

[១០:២៦:៣៦]

**ស៖** នៅពេលដែលលោកសួរសាកពួកគាត់ទាំងអស់ហ្នឹង តើលោកមានបញ្ជូនរបាយការណ៍ទៅសឿង អំពីព័ត៌មានដែលលោកបានសាកសួរពីអ្នកទាំងអស់នោះដែរឬទេ?

**ឆ៖** បាទ នៅពេលដែលចាប់បានទាំងទូកនុ៎ង ខ្ញុំរាយការណ៍ទៅលេខាកងពល ហើយសួរពីព័ត៌មានគាត់។ ខ្ញុំស្តាប់មិនសូវបានទេ មិនដឹងថា ម៉េច? បើគាត់ថាទៅថៃហើយ ហើយក៏បញ្ជូនមកខាង

កំពង់សោមវិញមក។

**ស៖** សូមអរគុណ។ ខ្ញុំនៅមានសំណួរមួយទៀតលើចំណុចនេះ។ តាមអ្វីដែលលោកដឹងតើរបាយការណ៍ដែលបញ្ជូនពី សៀង ទៅអគ្គសេនាធិការអំពីការចាប់ទូកនេះ គឺមាន -- សៀង មានបានបញ្ជូនរបាយការណ៍ទៅអគ្គសេនាធិការទេអំពីហេតុការណ៍ចាប់ទូកទាំងអស់នេះ?

[១០:២៧:៥៨]

**ឆ៖** បាទ ក្នុងការចាប់បានខ្ញុំរាយការណ៍តែតាមសារទូរលេខទៅឯកងពល ហើយកងពលរាយការណ៍ទៅខាងណាទៀត ខ្ញុំមិនបានដឹងទេ។

**ស៖** សូមអរគុណ។ នៅពេលដែលលោកឆ្លើយជូនអ្នកស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតថា គេផ្លាស់លោកទៅកោះកុង។ ឯកសារនេះលេខ E3/80 សំណួរចម្លើយទី១ លោកបានឆ្លើយដូចតទៅថា "១ខែក្រោយពេលដែលខ្ញុំទៅដល់កោះកុង ញ៉ឹក លេខាតំបន់៣៧ ឈ្មោះ រ៉ន ឈ្មោះដើម អ៊ីវ អនុលេខាតំបន់ និងឈ្មោះ អេវ ជាសមាជិកតំបន់ទទួលបន្ទុកខាងយោធាតំបន់នោះត្រូវគេដកចេញ។ ក្រោយគេដកចេញពួកគេនោះ គេបានបញ្ជូនទៅភូមិភាគ តែខ្ញុំមិនដឹងហេតុផលអ្វីបានជាដកអ្នកទាំងបីនោះ ចេញនោះទេ"។ តើលោកដឹងថា គេដកអ្នកទាំងបីនេះ តាមរបៀបណាដែលថា មានលេខាតំបន់៣៧ នេះត្រូវបានគេដកចេញ? តើលោកដឹងដោយរបៀបណាអ្នកទាំងបីហ្នឹង?

[១០:៣០:០០]

**ឆ៖** បាទ ការដែលដក តាញ៉ឹក, តាអេវ, ដូចជា តាសារី ដែរ ខ្ញុំបានដឹងតាមកងទ័ពតំបន់ខ្លះដែលគាត់ប្រាប់ខ្ញុំ យុទ្ធជនកងទ័ពតំបន់ខ្លះប្រាប់ខ្ញុំ។

**ស៖** ខ្ញុំសូមបញ្ជាក់បន្តិចអំពីរចនាសម្ព័ន្ធនៅក្នុងភូមិភាគ និងក្នុងការឆ្លើយរបស់លោកលើកទី២ គឺឯកសារ E3/80 ដដែលនេះ ត្រង់សំណួរចម្លើយ២២ និង២៣ លោកបានរៀបរាប់អំពីរចនាសម្ព័ន្ធនៅភូមិភាគបស្ចិម។ លោកបានឆ្លើយថា៖ "មានតំបន់ចំនួន៣ នៅភូមិភាគ គឺមានតំបន់៣១ ខេត្តកំពង់ឆ្នាំង, តំបន់៣២ ខេត្តកំពង់ស្ពឺ និងតំបន់លេខ៣ (សហព្រះរាជអាជ្ញានិយាយដូច្នេះ) នៅក្នុងខេត្តកោះកុង"។ ហើយតាមពិតទៅ គឺជាតំបន់៣៧ ទេដែលជាខេត្តកោះកុង។ ដូច្នេះ ខ្ញុំគ្រាន់តែសួរបញ្ជាក់ឲ្យបានច្បាស់លាស់ថា តំបន់៣១, តំបន់៣២, តំបន់៣៧ ដែលជាតំបន់ស្ថិតនៅក្នុងភូមិភាគបស្ចិម តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

[១០:៣២:០៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សី និងមេធាវីប្រឹក្សាសាក្សីនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣២ នាទី ដល់ម៉ោង ១០:៥៣ នាទី)*

[១០:៥៣:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** យើងត្រឡប់មកដោយសង្ខេបទៅតំបន់៣៧ ដែលលោកនិយាយថា តំបន់នោះនៅក្នុងខេត្តកោះកុង។ តើលោកស្ថិតនៅក្នុងតំបន់៣៧ ដែរឬទេ កាលពីលោកនៅក្នុងកោះកុងនោះ?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំនៅស្ថិតក្នុងនុំងដែរ ក្នុងខេត្តនុំងដែរ។

[១០:៥៤:៣២]

**ស៖** នៅពេលដែលលោកនិយាយថា នៅក្នុងផ្នែកដែលសរសេរក្នុងកំណត់ហេតុនោះគឺថា លេខា គេបានបញ្ជូន ថាគេបានបញ្ជូនគាត់ទៅភូមិភាគ។ តើការបញ្ជូននោះមានអត្ថន័យដូចម្ដេច?

**ឆ៖** បាទ ត្រង់ហ្នឹងខ្ញុំមិនដឹងន័យយ៉ាងម៉េច អត់ដឹងដែរ។

**ស៖** ខ្ញុំសួរឱ្យច្បាស់ជាងនេះ។ តើទីកន្លែងទីតាំងណា ដែលលោកនិយាយថា បញ្ជូនទៅភូមិភាគនោះ គឺគេបញ្ជូនទៅកន្លែងណា? ទីតាំងអ្វី?

**ឆ៖** បាទ ទីតាំងកន្លែង តាស៊ី។

**ស៖** សូមអរគុណ។ ខ្ញុំចង់ត្រឡប់ទៅ ដោយសង្ខេបទៅបញ្ហាទាក់ទងទៅនឹងការប្រាស្រ័យទាក់ទងតាមសារទូរលេខ ព្រោះយើងមានឯកសារមួយចំនួនចង់បង្ហាញលោក ដើម្បីឱ្យលោកពិនិត្យមើលថា តើអាចជួយបំភ្លឺខ្ញុំបានដែរឬទេ ដើម្បីឱ្យយើងខ្ញុំយល់កាន់តែច្បាស់ទៅលើការប្រាស្រ័យទាក់ទងតាមសារទូរលេខនេះ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម ឯកសារទី១ ដែលខ្ញុំចង់បង្ហាញជូនសាក្សីនោះគឺ E3/1037 គឺជាសារទូរលេខចុះថ្ងៃទីដប់ -- ថ្ងៃទី៦ តុលា ឆ្នាំ១៩៧៧។ ខ្ញុំមានឯកសារលើក្រដាស ដើម្បីជូនទៅសាក្សី។ សូមអនុញ្ញាតតុលាការ ដើម្បីបញ្ជូនទៅសាក្សី ហើយនិងបង្ហាញលើអេក្រង់ផងដែរបាទ។

[១០:៥៦:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! មន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញាជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំឃើញថា សំណេរនោះគឺមានអក្សរតូចណាស់ក្នុងភាសាខ្មែរ។ ដូច្នេះ ខ្ញុំនឹងអានជាភាសាអង់គ្លេស គឺជាឯកសារមានតែមួយទំព័រទេ។ នេះគឺជាសារទូរលេខលេខ៤៥ ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៧។ នៅខាងឆ្វេងដៃខាងលើនេះ គឺចេញមក -- គឺយើងមាន គឺ "កងពលបស្ចិមផ្នែកនយោបាយ"។ ហើយនៅខាងក្រោមទំព័រ នៅខាងស្ដាំដៃនោះ ហើយយើងឃើញថា គឺ "រៀបចំឡើងដោយមន្ទីរ០៩" គេដាក់ថា "កោះកុង"។ តើនេះជាលេខសម្គាល់មន្ទីររបស់លោកនៅកោះកុង ឬក៏មន្ទីររបស់អ្នកណាផ្សេង

ដែលហៅថា ម-០៩ នេះ?

**លោក មាស វឿន៖**

**ឆ៖** បាទ ទាំងនេះខ្ញុំមិនបានដឹងទេ កន្លែងខ្ញុំអត់មានមន្ទីរទេ គឺកន្លែងនៅធម្មតាជាមួយនឹងកងទ័ព។

[១០:៥៨:៤៣]

**ស៖** សូមអរគុណ។ យើងសូមមើលខ្លឹមសារនៃឯកសារនេះ នៅចំណុចទី១និយាយថា "នៅយប់ថ្ងៃទី០៥ ខែ១០ កងការពាររបស់យើងនៅដែនសមុទ្របានចេញល្បាតការពារ ដោយមានទូករបស់ខ្មាំងចូលមកដល់ខាងលិចកោះកុងខាងក្រៅ"។ ហើយនៅក្នុងទី២ "មកដល់ម៉ោងបួនទៀបភ្លឺ ចាប់បានកាណូតខ្មាំងបានមួយគ្រឿងនៅខាងលិចកោះ កោះក្បូរស្រូវ" បាទ។ ហើយនៅលេខ៣ និយាយថា "កាណូតនោះ មុន ហើយគឺថា ទំហំប្រាំ-- ៥០០សេះ"។ តើខ្លឹមសារប៉ុណ្ណេះ អាចធ្វើឲ្យលោកនឹកឃើញ ឬក៏ចងចាំអ្វីដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានចាំទេ។ ប៉ុន្តែមិនមែនចេញពីកន្លែងខ្ញុំទេ។

[១១:០០:០៨]

**ស៖** លោកបានប្រាប់ខ្ញុំថា លោកបានបញ្ជូនសារទូរលេខ ចេញពីតំបន់របស់លោក ពីកន្លែងរបស់លោក តើលោកប្រើមន្ទីរ ឬប្រើការិយាល័យដែលមានផ្នែកខាងសារទូរលេខដើម្បីប្រើកត់ត្រា ដើម្បីបញ្ជូនដែរឬទេនៅទីនោះ?

**ឆ៖** បាទ ពេលនោះអត់មានកន្លែងការិយាល័យទេ មានតែជំរំ យើងធ្វើជាផ្ទះតូចៗសម្រាប់នៅតាមកោះ។

**ស៖** អ៊ីចឹងតាមពិនិត្យមើល តើមានម៉ាស៊ីនសារទូរលេខដើម្បីប្រើបញ្ជូនចេញ ឬក៏ទទួលដែរឬទេ ពីកន្លែងរបស់លោកនោះ?

**ឆ៖** បាទ មានមួយ។

**ស៖** មើលនៅខាងក្រោម ខាងឆ្វេងដៃ ថាតើលោកអាចពន្យល់បានដែរឬទេ? "ចម្លងជូនបង៨៩ មន្ទីរ ហើយនិងឯកសារ"។ តើលោកស្គាល់ទេ អ្នកណាជាបង៨៩ ដែលគេយោងនៅក្នុងឯកសារនេះ បង៨៩ ជាអ្នកណា?

[១១:០១:៥៤]

**ឆ៖** ខ្ញុំអត់ៗបានដឹងទេនេះ។

**ស៖** ទាក់ទងទៅនឹងទម្រង់នៃឯកសារនេះ រូបភាព សារទូរលេខដែលលោកបានបញ្ជូន ហើយនិងទទួល តើស្ថិតនៅក្នុងទម្រង់បែបនេះដែលលោកបានឃើញនេះដែរទេ?

**ឆ៖** បាទ មិនមែនជារបស់ខ្ញុំទេ។

**ស៖** ថាតើមានភាពខុសគ្នាដូចម្ដេច និយាយពីរូបភាព ឬក៏ទម្រង់ បើសិនជាសារទូរលេខរបស់លោកមានរូបភាពម៉េច? ទម្រង់ម៉េច ខុសពីនេះ ឬក៏យ៉ាងដូចម្ដេច?

**ឆ៖** បាទ កន្លែងខ្ញុំ បើខ្ញុំសរសេរ គឺលេខរបស់ខ្ញុំមាន០៧។

**ស៖** ខ្ញុំយល់ហើយ។ ដូច្នេះ គឺថាមន្ទីររបស់លោក០៧ អ៊ីចឹងគឺថាដែលថា ម-០៨នេះ -- ០៩នេះគឺជាមន្ទីរផ្សេង។

**ឆ៖** បាទ។

**ស៖** សូមអរគុណលោកសាក្សី។ ខ្ញុំចង់បង្ហាញជូនលោកនូវសារទូរលេខមួយចំនួនទៀត ប៉ុន្តែខ្ញុំមានកម្រិតណាស់។ ខ្ញុំចង់បង្ហាញជូនលោកនូវឯកសារមួយ គឺE3/1031។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន នេះជាសារទូរលេខមួយផ្សេងទៀតចេញមកពីកងពលភូមិភាគបស្ចិម ចុះថ្ងៃទី១២ សីហា ឆ្នាំ១៩៧៧ ចុះហត្ថលេខាដោយ សឿង។ សូមអនុញ្ញាតពីលោកប្រធាន ដើម្បីជូនឯកសារទៅសាក្សីដើម្បីពិនិត្យ ហើយនិងសុំអនុញ្ញាតបង្ហាញលើអេក្រង់ផងដែរបាទ។

[១១:០៤:៣១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឯកសារនេះគឺដូចគ្នា គឺវាខ្លីទេ ហើយមាន នៅលើឯកសារនេះមានចំណារជូនពីរជាភាសាខ្មែរ។ ឯកសារនេះខាងក្បាលទំព័រនេះ គឺខាងឆ្វេង គេដាក់ថាកងពលបស្ចិមផ្នែកនយោបាយ។ ឯកសារនេះសរសេរថា "នៅម៉ោង១០ ព្រឹកនាថ្ងៃ១១ ខែ៨ មានយន្តខ្លាំងប្រតិកម្មធុន F105 មួយគ្រឿងបាន

ហោះកាត់លើដែនកោះយើងនៅកោះកុងក្រៅ កាត់ពីជើងទៅត្បូង"។ អ្នកសរសេរសារទូរលេខនេះគឺឈ្មោះ សឿង។ ដូច្នេះ ខ្ញុំសួរលោកជាដំបូងសិនថា តើ សួង នេះគឺ សួង តែមួយទេដែលថាជាមេកងពលរបស់លោក លោកបានរៀបរាប់នោះ តើអ៊ីចឹងដែរឬទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** នៅក្នុងនេះគឺសរសេរថា យន្តហោះខ្មាំងប្រតិកម្មហោះកាត់លើដែនកោះនៅកោះកុងក្រៅ ដូច្នេះ កោះហ្នឹងហើយជាកោះដែលលោកទទួលកាន់កាប់ការពារហ្នឹង តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

[១១:០៦:៣១]

**ស៖** តើ សួង នេះបានព័ត៌មានហ្នឹងមកពីណាដែរ? គឺលោកជាអ្នកឲ្យព័ត៌មានទៅគាត់ បន្ទាប់មកគាត់សរសេរបញ្ចូលនៅក្នុងសារទូរលេខ ឬក៏យ៉ាងម៉េច? ឬក៏ សឿង នេះទទួលបានព័ត៌មាននេះមកពី -- ដោយមធ្យោបាយផ្សេង ពីអ្នកផ្សេងតែប៉ុណ្ណោះ?

**ឆ៖** បាទ ការដែល បងសឿង ទទួលពីសារទូរលេខនេះ ប្រហែលជាវរសេនាតូចរាយការណ៍ឲ្យគាត់ ប្រហែលជាខ្ញុំមិនបាននៅ។

**ស៖** ក្នុងពេលដែលលោកអវត្តមាននោះគឺថា មេវរសេនាធំហ្នឹងជាអ្នកបញ្ជូនព័ត៌មាននេះទៅឲ្យ សឿង មេវរសេនាតូចនោះ?

**ឆ៖** បាទ ប្រហែលអ៊ីចឹង។

**ស៖** ប្រសិនបើយើងមើលមួយភ្លែតទៅលើចំណារ ចំណារនេះចុះហត្ថលេខាដោយ ខៀវ តើលោកដឹងទេ ឈ្មោះហៅក្រៅដែលថា ខៀវ នេះឈ្មោះអ្នកណាដែរ?

**ឆ៖** បាទ វរសេនាតូចនៅកោះកុងក្រៅអត់មានឈ្មោះ ខៀវ ទេ ក៏ប៉ុន្តែកោះកុងក្រៅខាងកងពួកខ្ញុំនៅ ប៉ុន្តែឈ្មោះ ខៀវ គ្មាន។

[១១:០៨:៤៤]

**ស៖** តើលោកនឹកឃើញទេថាមាននរណាគេផ្សេងដែលៗមិននៅកោះកុងទេ នៅកន្លែងផ្សេងទេតែមានឈ្មោះ ខៀវ នេះ?

**ឆ៖** បាទ ដូចជាគ្មានក្នុងវរសេនាធំយើងគ្មានឈ្មោះ ខៀវ។ ហើយពីណាក្រៅមកទៀត ខ្ញុំមិន

បានដឹង។

**ស៖** តើលោកចាំទេ និងនឹកឃើញទេនៅក្នុងជួរកងទ័ព តើមាននរណាម្នាក់ក្នុងជួរកងទ័ពនោះ មានឈ្មោះហៅក្រៅថា ខៀវ ដែរឬទេ?

**ឆ៖** បាទ ដូចជាគ្មាន ហើយម៉្យាងខ្ញុំក៏ស្គាល់គេមិនអស់ដែរ ប៉ុន្តែក្នុងវរសេនាធំទាំងអស់គឺអត់ មានឈ្មោះ ខៀវ ទេ។

[១១:១០:១៦]

**ស៖** តើលោកនឹកឃើញចាំដែរឬទេ ថាតើ សុន សេន នេះប្រើឈ្មោះហៅក្រៅ ហៅឈ្មោះអ្វី ដែរ? តាមអ្វីដែលលោកឆ្លើយពីមុនមក?

**ឆ៖** បាទ ខ្ញុំបញ្ជាក់ថាក្នុងកងៗទ័ពខ្ញុំអត់មានឈ្មោះ ខៀវ ទេ។ តែបើ ខៀវ អគ្គសេនាធិការគឺ សុន សេន លោក សុន សេន នេះឯង។

**ស៖** (គ្មានការបកប្រែ) --

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី លោកស្រីមេធាវី!

[១១:១១:១៣]

**កញ្ញា អង់តា ហ្គីសសេ៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំគ្រាន់តែចង់បញ្ជាក់អំពីកំណត់ហេតុក្នុងការបកប្រែជាភាសាបារាំងនោះ ខ្ញុំគិតថាមានកំហុសនៃការបកប្រែនៃឯកសារ E3/1031 គឺក្នុងឯកសារនោះ ដូចអត់មានឈ្មោះ ខៀវ ទេ។ ដូច្នេះសូមឲ្យ -- ជម្រាបជូនអង្គជំនុំជម្រះថា មានបញ្ហាបកប្រែជាភាសាបារាំងដោយមិនមានឈ្មោះ ខៀវ នៅក្នុងឯកសារដែលសហព្រះរាជអាជ្ញាលើកឡើងនេះទេ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សម្រាប់ប្រតិចារឹក គឺឯកសារ E3/1031។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ប្រសិនបើយើងមើលចំណារនៅខាងឆ្វេងដៃ ហើយតើឲ្យលោកមើលមើល៍ តើលោកនឹកឃើញដែរឬទេ ហេតុការណ៍នៅពេលនោះ? ក្នុងនេះគឺ "ជូនអង្គការជាព័ត៌មាន តាមសមមិត្ត មុត រាយ-ការណ៍ផ្ទាល់មាត់ថា "ម្សិលមិញ យើងចាប់ទូកវាមួយ (១៧០សេះ) នៅកោះកុងក្រៅ ត្រង់ចុងកោះខាង

ត្បូង។ កន្លែងបង ខ្ញុំចតកប៉ាល់ ចាប់ថៃបួន ខ្មែរមួយ។ វាឆ្លើយថាទាក់ទង។ មានក្បួនឫស្សីនៅលើទូក។ កំពុងសួរ"។ ខ្ញុំដឹងថាហេតុការណ៍នេះ គឺកើតឡើងយូរមកហើយ ក៏ប៉ុន្តែក្រោយដែលខ្ញុំអានឡើងវិញនេះ តើលោកនឹកឃើញដែរឬទេនៅក្នុងខែសីហា ឆ្នាំ១៩៧៧ ដែលនៅពេលនោះមានការចាប់បានទូកមួយ ហើយមានការសួរចម្លើយជនជាតិថៃបួននាក់ ខ្មែរម្នាក់។ តើលោកនឹកឃើញទេ?

[១១:១៣:៣៨]

**លោក មាស វឿន៖**

**ឆ៖** បាទ មិនមែនកងខ្ញុំចាប់ទេ។

**ស៖** សូមអរគុណ។ យើងចូលទៅដល់ឯកសារមួយទៀត គឺសារទូរលេខមួយច្បាប់ទេ មកពីខាងកងពលបស្ចិម។ ឯកសារ E3/1001។ ឯកសារនេះ គឺចុះថ្ងៃ៣១ ខែមីនា ឆ្នាំ១៩៧៨។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអនុញ្ញាតពីលោកប្រធានផ្តល់ឯកសារជាក្រដាសជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១១:១៤:៣៨]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** នៅពេលដែលយើងមើលឯកសារនេះ លោក វឿន ឯកសារនេះចុះហត្ថលេខាដោយ សឿង ថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៨ នៅខាងឆ្វេង ខាងលើយើងឃើញដាក់ថា "កងពលបស្ចិម"។ ខ្ញុំគ្រាន់តែចង់ឲ្យលោកមើលខ្លឹមសារនៃសារទូរលេខនេះ។ តើលោកស្គាល់ និងដឹងហេតុការណ៍នេះដែរឬទេ? ចំណុច "ទី១. យប់ថ្ងៃ២៩ មីនា ៧៨ ពេលម៉ោងបីដប់ប្រាំនាទីព្រឹក យើងបានចាប់ -- យើងចាប់បានកាណូតថៃបីគ្រឿងត្រង់មុខកោះយ៉ ៥គ.ម"។ កោះយ៉នេះ គឺកោះយ៉ ដែលលោកបាននិយាយឆ្លើយប្រាប់មុននឹង ពីមុននឹងបន្តិចនោះ ថាគឺជាកោះយ៉ ដែលលោកកាន់កាប់ការពារហ្នឹង តើអ៊ីចឹងដែរទេ?

**ឆ៖** បាទ អ៊ីចឹងមែន ចេញពីអង្គភាពខ្ញុំ។

**ស៖** យើងឃើញថា ចំណុចទី៣ឃើញសរសេរដាក់ថា "ចាប់បានមនុស្សម្នាក់"។ ហេតុការណ៍នេះ គឺលោកចាំទេថា កងវរសេនាធំរបស់លោកហ្នឹង ចាប់បានមនុស្សម្នាក់។ តើលោកនឹកឃើញទេ?

**ឆ៖** បាទ ដូចជាភ្លេច។

[១១:១៦:៤៣]

**ស៖** បាទ មិនជាអ្វីទេ។ ខ្ញុំដឹងថា ហេតុការណ៍នេះកើតយូរមកហើយ ក៏ប៉ុន្តែយើងគ្រាន់តែចង់ដឹងតែប៉ុណ្ណោះ។ តាមរយៈព័ត៌មានដែលហូរចូលមកលោកដែលឲ្យលោកបានដឹងនេះ តើព័ត៌មាននេះគឺកងទ័ពនៅកោះកុង តំបន់កោះកុងនោះជាអ្នកផ្តល់ឲ្យបញ្ជូនទៅ សឿង ហើយបន្ទាប់មក សឿង ជាអ្នករៀបចំសារទូលេខនេះឡើង។ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**ស៖** សូមអរគុណ។ ឯកសារចុងក្រោយមកទៀតដែលខ្ញុំសូមបង្ហាញលោកផងដែរ ពាក់ព័ន្ធទៅនឹងការទាក់ទងគ្នានៅក្នុងជួរយោធា ជួរកងទ័ព ឯកសារ E3/1132។ ជាថ្មីម្តងទៀត ឯកសារ E3/1132 ជារបាយការណ៍មកពីអគ្គសេនាធិការ ឆ្លើយតបទៅនឹងសារទូរលេខ ឆ្នាំ១៩៧៦ ខែធ្នូ។ ខ្ញុំមានឯកសារមួយច្បាប់ជាក្រដាសជូនទៅសាក្សី។

[១១:១៨:២៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ឯកសារជាក្រដាសនេះជូនសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឯកសារនេះ គឺច្រើនទំព័របន្តិច ក៏ប៉ុន្តែខ្ញុំនឹងអាន និងសួរដោយសង្ខេបតែប៉ុណ្ណោះ។ នៅខាងឆ្វេងដាក់ថា "កងទ័ពបដិវត្តន៍កម្ពុជា, មន្ទីរសេនាធិការ, សរុបសភាពការណ៍នៅក្នុងប្រទេស និងព្រំដែនតាមទូរលេខពីថ្ងៃទី ១ធ្នូ ដល់ ៣១ធ្នូ ឆ្នាំ១៩៧៦" បន្ទាប់មកយើងឃើញមានការសេរព័ត៌មានក្នុងហ្វឹងនីមួយៗគឺ ចំណុចទី១ "ខែ១ ដល់ខែ -- ថ្ងៃ១ ដល់ថ្ងៃ៧ ខែធ្នូ ឆ្នាំ៧៦ ទាក់ទងទៅនឹងបញ្ហានៅព្រំដែន"។ ហើយប្រសិនបើយើងមើលចំណុចចុងក្រោយវិញម្តង ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៧៦ វិញម្តង គឺនិយាយថា "នៅម៉ោងដប់បីកងកាណូតរបស់យើង គឺបាញ់តបជាមួយនឹងខាងថៃនៅតាមព្រំដែន"។

[១១:២០:២]

តាមអ្វីដែលលោកចាំ ហើយលោកជម្រាបផងដែរ ប្រសិនបើលោកមិនចាំក៏មិនជាអ្វីដែរ។ តើឯកសារនេះគឺជាការចងក្រងព័ត៌មានដែលទទួលបានអំពីស្ថានភាពកើតឡើងនៅតាមព្រំដែនសមុទ្រថៃនោះ? តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនបានចាំទេ។

[១១:២០:៥៧]

**ស៖** សូមអរគុណ។ ខ្ញុំសូមចូលសួរប្រធានបទមួយទៀត។ ឯកសារនេះគឺការសួររបស់ខ្ញុំ គឺពាក់ព័ន្ធទៅនឹងការប្រតិបត្តិការ ឬដំណើរការមន្ទីរសន្តិសុខនៅទីតាំងដែលលោកកាន់កាប់ធ្វើការងារ។ ចំណុចនេះ គឺបានលើកឡើងនៅក្នុងកំណត់ហេតុលើកទី២ ដែលលោកបានឆ្លើយជូនអ្នកស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេត ឯកសារ E3/80។ សំណួរដែលពាក់ព័ន្ធ សំណួរចម្លើយដែលពាក់ព័ន្ធនោះ គឺចាប់ពីសំណួរចម្លើយទី៤ ដល់សំណួរចម្លើយទី៧។ នៅក្នុងសំណួរចម្លើយទី៤ លោកបានឆ្លើយថា "មានមន្ទីរសន្តិសុខមួយនៅស្រុកព្រៃនប់ ខេត្តកំពង់សោម គឺមន្ទីរសន្តិសុខកោះខ្យង"។ នៅក្នុងសំណួរចម្លើយទី៥ លោកឆ្លើយថា "មន្ទីរសន្តិសុខនេះគឺជារបស់តំបន់ផង របស់ភូមិភាគផង។ ហើយ តាសឿង ជាញឹកញាប់នោះគឺបានទៅមើលមន្ទីរសន្តិសុខកោះខ្យងនោះ ហើយនៅពេលនោះ គឺមានការចាប់សមាជិកម្នាក់មានចាប់កងទ័ពខ្លះនៅក្នុងកងពលលេខ១ បញ្ជូនទៅមន្ទីរសន្តិសុខកោះខ្យង"។ តើលោកចាំទេ អំពីមន្ទីរកោះខ្យងនេះ មន្ទីរសន្តិសុខកោះខ្យងនេះ?

[១១:២៣:០៩]

**ឆ៖** បាទ កន្លែងនោះខ្ញុំមិនដែលបានទៅដល់ទេ ក៏ប៉ុន្តែឮយុទ្ធជនប្រាប់ខ្ញុំថា មានមន្ទីរសន្តិសុខនៅកោះខ្យង។ ពីកន្លែងព្រៃនប់ទៅកោះខ្យងឆ្ងាយដែរ ហើយខ្ញុំក៏មានភារកិច្ចនៅកន្លែងនោះទេ បាទ។

**ស៖** តើលោកដឹងថា តាសឿង ទៅមើលមន្ទីរសន្តិសុខនោះជាញឹកញាប់នោះ ដោយរបៀបណា?

**ឆ៖** បាទ ខ្ញុំមិនដឹងថាគាត់ទៅមើលរបៀបណាទេ ក៏ប៉ុន្តែគាត់បានទៅដល់កន្លែងនោះ បាទ។

**ស៖** តើ តាសឿង គាត់មានការទទួលខុសត្រូវលើមន្ទីរសន្តិសុខកោះខ្យងដែរឬទេ?

**ឆ៖** បាទ កាលពីមុនគាត់អត់បានទទួលខុសត្រូវនៅកន្លែងនោះទេ ប៉ុន្តែមន្ទីរកោះខ្យងហ្នឹងកើតមុនគាត់មកទៅហើយ បានគាត់ទៅលើមើលកន្លែងនោះ បាទ។

**ស៖** ខ្ញុំសួរបកក្រោយបន្តិច តើនៅក្នុងឆ្នាំ៧៦ នោះ មន្ទីរសន្តិសុខកោះខ្យងនោះ មានរួចហើយឬនៅ នៅពេលដែលលោកជាអនុប្រធាន អនុបញ្ជាការនោះ?

[១១:២៥:០៥]

**ឆៈ** បាទមានមុន មុនខ្ញុំទៅទៀត។

**សៈ** នៅក្នុងចម្លើយដដែលនេះ ត្រង់សំណួរចម្លើយទី៦ លោកបានឆ្លើយថា "កូនទាហានត្រូវបានចាប់បញ្ជូនទៅកោះខ្សែង មានដូចជាអ្នកដែលមានឪពុកធ្លាប់ធ្វើជាទាហានពីសម័យមុនជាដើម"។ តើលោកអាចរៀបរាប់ឆ្លើយជូនយើងខ្ញុំដែរឬទេ តើប្រភេទប្រជាជនណាផ្សេងទៀត ដែលត្រូវបានគេបញ្ជូនទៅមន្ទីរសន្តិសុខកោះខ្សែងនោះ?

**ឆៈ** បាទ ចំណែកយុទ្ធជននៅកងពលទី១ ហ្នឹង គឺ តាសឿង គាត់យកទៅកន្លែងនុំងមែន។ ក៏ប៉ុន្តែគាត់មិនមែនចាប់ មិនមែនចងពីកន្លែងនោះមកទេ គឺគាត់ហៅមកជួបជុំនៅកន្លែងគាត់ហើយ មិនដឹងគាត់យកទៅដាក់កោះខ្សែង ឬក៏ដាក់ត្រង់ណា ខ្ញុំមិនបានដឹងច្បាស់។

[១១:២៦:៤២]

**សៈ** សូមអរគុណ។ ដើម្បីសួរលើបញ្ហានេះបន្ថែមបន្តិច នៅក្នុងចម្លើយដែលលោកឆ្លើយឯកសារ E3/80 ត្រង់សំណួរចម្លើយទី១០ លោកបានឆ្លើយថា "រាល់ការសម្រេចចាប់ខ្លួនក្នុងកងពល មានកម្លាំងកងពិសេសរបស់កងពល ជាអ្នកចុះស្រាវជ្រាវ និងពិនិត្យប្រវត្តិរូបរបស់យុទ្ធជនម្នាក់ៗ"។ តើអ្នកដែលចុះទៅស្រាវជ្រាវនេះហើយ ដែលជាអ្នកធ្វើការចាប់ខ្លួន ហើយបញ្ជូនទៅ តាសឿង ហ្នឹង មែនដែរឬទេ?

**ឆៈ** បាទ មែន។

**សៈ** កម្លាំងកងពិសេសនេះ តើនរណាគេជាអ្នកចេញបញ្ជាទៅឲ្យកម្លាំងកងពិសេសនោះ ថាតើត្រូវចាប់នរណាៗខ្លះនោះ?

**ឆៈ** បាទ តាសឿង។

**សៈ** នៅក្នុងកំណត់ហេតុដដែលនេះ លោកបន្តឆ្លើយទៀតថា "ក្នុងករណីមានព្រឹត្តិការណ៍អ្វីមួយកើតឡើង កងពិសេសរបស់កងពលជាអ្នកចុះមកសុំដកយកយុទ្ធជនទាំងនោះទៅក្រោយវិញ។ ចំពោះយុទ្ធជនណាដែលមានប្រវត្តិរូបពាក់ព័ន្ធជាមួយកូន -- របស់ទាហាន ឬមន្ត្រីណាដែលមានបណ្តាស័ក្តិពីសង្គមចាស់"។ ដូច្នេះ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ថាកងពិសេសនេះជាអ្នកពិនិត្យប្រវត្តិរូប ហើយជាអ្នកកំណត់ថាតើនរណាខ្លះដែលជាប់ពាក់ព័ន្ធនឹងនិន្នាការក្នុងរបបចាស់ តើអ៊ីចឹងដែរឬទេ?

[១១:២៩:១៨]

**ឆៈ** បាទ អ៊ីចឹងមែន។

**ស៖** តើលោកដឹងដែរឬទេ ហេតុអ្វីបានជាគេស្វែងរកតែបុគ្គលដែលជាប់ពាក់ព័ន្ធទៅនឹងមនុស្សជាប់និន្នាការសង្គមចាស់ នៅពេលដែលគេពិនិត្យប្រវត្តិរូបនោះ?

**ឆ៖** បាទ ខ្ញុំមិនបានយល់ទេ ក្នុងការគេស្វែងរកបងប្អូនកូនចៅដែលមានជាប់ពីសង្គមចាស់ មិនយល់ថា គេយកទៅយ៉ាងម៉េចទេបាទ។

[១១:៣០:១៩]

**ស៖** យើងត្រឡប់ទៅមើលចម្លើយរបស់លោកនេះដដែល គឺឯកសារ E3/80 ត្រង់សំណួរចម្លើយទី៧វិញម្តង។ លោកបានឆ្លើយ "យុទ្ធជននៅកោះកុង" លោកបានឆ្លើយដូច្នេះថា "យុទ្ធជននៅកោះកុងត្រូវបានបញ្ជូនទៅកន្លែងលត់ដំ ជីកប្រឡាយនៅបន្ទាយលង្វែក។ ការបញ្ជូនទាហានទាំងនោះគឺតាសឿង ប្រធានកងពលជាអ្នកសម្រេច"។ ដូច្នេះ តើខ្ញុំយល់ត្រឹមត្រូវដែរឬទេថា យុទ្ធជនមួយចំនួននៅក្នុងកងវរសេនាធំរបស់លោកនោះ ត្រូវបានគេដកចេញ ហើយបញ្ជូនទៅកន្លែងលត់ដំ តើអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

[១១:៣១:២០]

**ស៖** តើនរណាគេជាអ្នកដកយកយុទ្ធជននេះចេញដោយផ្ទាល់ទៅនោះ ពីកងវរសេនាធំរបស់លោក?

**ឆ៖** បាទ កងពិសេសរបស់គាត់។

**ស៖** នៅពេលកងពិសេសមកយកយុទ្ធជនទាំងអស់នេះ តើគេមានជូនដំណឹងដល់លោកដែរឬទេថាពួកគេមកដកយកអ្នកទាំងអស់នេះចេញទៅហើយ។

**ឆ៖** បាទ គេប្រាប់ខ្ញុំដែរ ក៏ប៉ុន្តែខ្ញុំមិនហ៊ានតបតនឹងប្រធានកងពល។

**ស៖** ហេតុអ្វីបានជាលោកមិនតវ៉ា មិនឲ្យគេដកយុទ្ធជនរបស់លោកនេះយកចេញទៅ?

**ឆ៖** បាទ ខ្ញុំមិនហ៊ានៗ ដោយសារខ្លាចមានរឿងរ៉ាវដល់ខ្ញុំដែរ។

[១១:៣២:៥៨]

**ស៖** តើមូលហេតុអ្វីបានកងពិសេសមកដកហូត កងយោធាចេញពីកងវរសេនាធំរបស់លោកនោះ?

**ឆ៖** បាទ ក្នុងការដែលគាត់បញ្ជាមកដកនោះ មកពីគាត់បានគ្រប់គ្រងរួមទាំងអស់ក្នុងប៉ុន្មានវរសេនាធំហ្នឹង គាត់គ្រប់គ្រងរួមទាំងអស់។ គាត់ចាត់ចែងបានទាំងអស់។

**សៈ** ខ្ញុំយល់ហើយ គឺថាបញ្ជាចេញមកពីថ្នាក់លើនៃកងពល។ ប៉ុន្តែខ្ញុំចង់សួរថាហេតុអ្វី ថាបាន ជាគេដកហូតនូវកងទ័ពយោធាទាំងអស់នេះដោយកងពិសេសនោះ?

**ផៈ** ខ្ញុំអត់យល់ពីសំណួរហ្នឹងបន្តិច។

**សៈ** បាទ ថាតើហេតុអ្វីបានជាកងពលពិសេសមកដកកងយោធា ឬក៏ដកយុទ្ធជនចេញពីកង វរសេនាធំរបស់លោកនោះ?

**ផៈ** មិនមែនកងពលពិសេសនេះ គឺវរសេនាធំពិសេសរបស់កងពលដែលគាត់គ្រប់គ្រងផ្ទាល់ គាត់បញ្ជាមកដកយកទៅក្រោយ។

[១១:៣៥:០២]

**សៈ** តើការដកហូតហ្នឹងដោយសារថា គេកំណត់អត្តសញ្ញាណអ្នកទាំងអស់នោះមានជាប់ខ្សែ ជាគ្រួសារសមាជិករបស់ទាហានចាស់ ឬក៏មន្ត្រីយោធាចាស់បានគេដកហូតអ្នកទាំងហ្នឹង ឬក៏ដោយសារ មូលហេតុអ្វី?

**ផៈ** បាទ ដោយសារឪពុកម្តាយជាប់និន្នាការសង្គមចាស់។

**សៈ** នៅក្នុងចម្លើយទី៣ របស់លោកគឺ E3/73 នៅសំណួរនិងចម្លើយទី២។ លោកបាននិយាយ ថា ទាក់ទងទៅនឹងមនុស្សដែលបោសសម្អាតនៅក្នុងភូមិភាគបស្ចិមនាពេលនោះ លោកនិយាយថាជា ឧទាហរណ៍ នៅពេលដែលពួកចោរព្រៃ និងពួកជនដែលមានបំណងចង់រត់គេចខ្លួនទៅប្រទេសថៃ។ តើ នេះជាមូលហេតុបន្ថែមដែលគេយកចោទ ដើម្បីដកមនុស្សដោយសារពួកទាំងអស់ហ្នឹងគឺមានបំណងចង់ រត់ទៅប្រទេសថៃ ទើបបានគេចាប់។ តើនេះជាមូលហេតុដែរឬទេ?

[១១:៣៦:៤០]

**ផៈ** មូលហេតុអ៊ីចឹងមែន។

**សៈ** យើងបានឃើញពីខាងដើមនៅក្នុងចម្លើយរបស់លោកថា “ពេលខ្លះលោកបានចូលរួមការ ប្រជុំជាមួយ តាសឿង ឬក៏ថាម្តងរៀងរាល់បី ឬបួនខែ”។ នៅក្នុងការប្រជុំទាំងនោះ តើ តាសឿង បាន ពិភាក្សា ឬក៏និយាយអំពីការចាប់ខ្លួន ឬក៏ការដកយោធា ដោយការចាប់ខ្លួនដែរឬទេ?

**ផៈ** បាទ ការដែលគាត់មកពិភាក្សាជាមួយខ្ញុំ គាត់និយាយពីរឿងប្រវត្តិ គាត់និយាយរឿងឲ្យ ក្តាប់ប្រវត្តិរូប ហើយនិងសកម្មភាពល្អ និងអាក្រក់ អ្នកណាដែលធ្វើសកម្មភាពប្រឆាំង ឬក៏ទំនាស់ ហ្នឹង ដក តែបើសិនជាមានប្រវត្តិរូបមិនល្អ នៅតែសកម្មល្អ ក៏គាត់មិនដកដែរបាទ។

**ស៖** ចំពោះប្រវត្តិទាំងអស់នោះ ដែលលោកបានរក្សាទុក តើនេះជាប្រវត្តិរូបដែលកងពិសេសយកមកប្រើដើម្បីកំណត់មុខសញ្ញាថា អ្នកដែលត្រូវចាប់ អ្នកណាដែលត្រូវដកចេញដែរឬទេ?

**ឆ៖** បាទ រឿងប្រវត្តិរូប ពេលអ្នកដែលក្ដាប់ប្រវត្តិរូបរួចហើយ អ្នកដែលក្ដាប់ប្រវត្តិរូបគេយកក្រដាសមកឲ្យ តាសឿង ពិនិត្យមើល។

**ស៖** សូមអរគុណ។ ឥឡូវនេះចូលទៅដល់ប្រធានបទមួយផ្សេងទៀត។ ដោយសារខ្ញុំមានពេលកម្រិតនោះ នៅក្នុងចម្លើយទី២ របស់លោក គឺ E3/80 សំណួរដែលពាក់ព័ន្ធនឹងចម្លើយពាក់ព័ន្ធនោះគឺពីទី១៤ រហូតទៅដល់ ២១។ លោកបានឆ្លើយ និងពិភាក្សាអំពីការប្រជុំ បាទ អំពីកងពលភូមិភាគពាយ័ព្យ អ៊ំ! ភូមិភាគបស្ចិម សូមកែតម្រូវ។ បាទ និយាយពីការចូលរួមសន្និបាតភូមិភាគបស្ចិម។ តាមដែលខ្ញុំយល់ចម្លើយរបស់លោកហ្នឹង គឺថាលោកចាំពីការចូលរួមប្រជុំពីរនៅក្នុងភូមិភាគបស្ចិម ហើយនិងការប្រជុំយោធានៅភូមិភាគបស្ចិមផងដែរ។

**លោក អេនគ្រូ អ៊ីនូហ្វី៖**

សូមអភ័យទោសលោកចៅក្រម។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប។ សូមអញ្ជើញ!

**លោក អេនគ្រូ អ៊ីនូហ្វី៖**

នេះមិនជាការជំទាស់នោះទេ ខ្ញុំគ្រាន់តែឮថាសហព្រះរាជអាជ្ញាគឺបាន គាត់យោងទៅរក គឺយោងទៅរកសំណួរចម្លើយ១៤, ២១ គឺបញ្ហាដែលខ្ញុំលើកពីម្សិលមិញនោះ គឺថាសូមដកនូវផ្នែកមួយគឺថានៅក្នុងឯកសារ E3/80 ហ្នឹងគឺទាក់ទងទៅនឹងសំណើរបស់ខ្ញុំពីម្សិលមិញ។ សូមអនុញ្ញាតឲ្យអង្គជំនុំជម្រះប្រុងប្រយ័ត្នក្នុងការពិនិត្យមើលសំណួររបស់សហព្រះរាជអាជ្ញា ថាតើចម្លើយទាំងអស់នេះផ្អែកទៅលើចម្លើយសារភាពដោយបង្ខំដែរឬទេ ជាពិសេសការសួរដែលចោទទៅសាក្សីទាក់ទងទៅនឹងខ្លឹមសារដែលអាចនឹងចេញមកពីចម្លើយសារភាពដោយអំពើទារុណកម្មនោះ។ សូមអរគុណ។

[១១:៤១:១១]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមអនុញ្ញាតឆ្លើយតបដោយសង្ខេបទៅមេធាវីការពារក្ដីវិញ។ អង្គជំនុំជម្រះបានសម្រេចពីម្សិលមិញថា ចម្លើយនោះគឺថាជាភស្តុតាង។ ដូច្នេះអង្គជំនុំជម្រះក៏បានសម្រេចផងដែរ ចម្លើយសារភាព

នោះ ខ្លឹមសារនៃចម្លើយសារភាពនោះ មិនគប្បីយកមកជាមូលដ្ឋានទេ ពីព្រោះថាវាផ្ទុយទៅនឹងអនុញ្ញាប្រឆាំងនឹងអំពើទារុណកម្ម។ ខ្ញុំមិនយល់ស្របជាមួយនឹងមេធាវីការពារអម្បាញ់មិញនេះទេ ថាអំពើ ឬក៏អ្វីដែលខ្ញុំសួរផ្អែកទៅលើឯកសារនេះ គឺជាឯកសារដែលសាក្សីបានឆ្លើយអំពីអង្គប្រជុំ អំពីសន្និបាតដែលគាត់ចូលរួម ដែលមានការយោងទៅនឹងឯកសារចម្លើយសារភាពដែលលោកមេធាវីនិយាយ។ អានេះគឺគាត់ឆ្លើយមុនពេលនោះទេ។ ផ្អែកនៅលើការចងចាំរបស់គាត់តែប៉ុណ្ណោះ គឺមិនៗបានឆ្លើយយោងទៅរកចម្លើយសារភាពដូចដែលមេធាវីបានលើកឡើងទេ មកដល់ចំណុច សំណួរចម្លើយ១៤នេះ បាទ។

[១១:៤២:១៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ នូវការកត់សម្គាល់របស់លោកមេធាវី ហើយបញ្ហានេះគឺអង្គជំនុំជម្រះបានចងចាំច្បាស់លាស់ណាស់នូវអ្វីដែលលោកបានស្នើសុំ ហើយអង្គជំនុំជម្រះបានសម្រេចរួចហើយកាលពីម្សិលមិញ។ ហើយអង្គជំនុំជម្រះក៏បាននឹងកំពុងតែតាមដានយ៉ាងយកចិត្តទុកដាក់នៅលើការពិភាក្សាដេញដោលនេះ ដើម្បីមានលទ្ធភាពនៅក្នុងការកត់សម្គាល់ ថាគួរដែលដកចេញ ឬក៏ហាមឃាត់មិនឱ្យសួរ ឬយ៉ាងណា។ យ៉ាងណាមិញគឺភាគីក៏មានសិទ្ធិពេញលេញនៅក្នុងការជំទាស់តវ៉ានៅសំណួរជាក់លាក់ណាដែលខ្លួនមានមូលដ្ឋានជាក់ច្បាស់ យល់ថាសំណួរនេះចេញមកពីលទ្ធផលនៃកំណត់ហេតុសួរចម្លើយដោយធ្វើទារុណកម្មផងដែរ។

បញ្ហានេះមិនទាន់បាន អង្គជំនុំជម្រះគិតថាមិនទាន់មានលទ្ធភាព ឬក៏មិនទាន់មានស្ថានភាពចូលដល់ទៅបញ្ហាដែលជាដកស្រង់នូវលទ្ធផលនៃកំណត់ហេតុដែលបានធ្វើទារុណកម្មយកមកតាំងសំណួរនោះឡើយ។

[១១:៤៣:១៧]

សាក្សីអាចឆ្លើយនឹងសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញាចុងក្រោយនេះ ឬក៏មិនចងចាំទេ តំណាងសហព្រះរាជអាជ្ញាអាចតាំងសំណួរជាថ្មីម្តងទៀត។

ទំនងជាមិនចាំទេ។ សូមតំណាងសហព្រះរាជអាជ្ញាតាំងសំណួរ រៀបសំណួរចុងក្រោយអម្បាញ់មិញនេះសាជាថ្មីម្តងទៀត។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** សំណួរខ្ញុំសួរលោកសាក្សីថា តើខ្ញុំយល់ត្រូវដែរឬទេ ចម្លើយរបស់លោកទៅនឹងចម្លើយនេះថាលោកបានចូលរួមការប្រជុំពីរនៅក្នុងភូមិភាគបស្ចិមនាកាលនោះ?

[១១:៤៤:១៦]

**លោក មាស វឿន៖**

**ឆ៖** បាទ ចូលរួមមែន។

**ស៖** សូមអរគុណ។ នៅសំណួរ និងចម្លើយ១៦ សូមលោកជម្រាបខ្ញុំថាតើតាមអ្វីដែលលោកចងចាំតែប៉ុណ្ណោះ លោកបាននិយាយថា "តា នួន ជា ឬ តា ប៉ុល ពត តាមធម្មតាវត្តមាននៅក្នុងការប្រជុំភូមិភាគ"។ ពេលនោះ លោកនិយាយថា "ការប្រជុំសន្និបាតភូមិភាគហ្នឹង គឺមានរយៈពេល១សប្តាហ៍ ហើយនៅក្នុងនោះគឺមានការពិភាក្សាអំពីការរៀនសូត្រ ហើយគេបានបែងចែកទៅជាក្រុមដើម្បីឱ្យមានការប្រជុំស្វ័យទិតៀន នៅពេលថ្ងៃ និងពេលយប់នោះផងដែរ។ តើនេះជាសេចក្តីសង្ខេបត្រឹមត្រូវពីចម្លើយរបស់លោកដែរឬទេ? តើលោកនៅចងចាំថា នួន ជា ឬក៏ ប៉ុល ពត បានចូលរួមនៅសន្និបាតរបស់តំបន់នោះ?

**ឆ៖** បាទ ខ្ញុំឃើញតែ តាប៉ុល ពត, ហើយ ប៉ាល់, ហើយ តាស៊ី ហើយគណៈតំបន់ និងវរសេនាធំខ្លះ ព្រមនឹងលេខាកងពលដែរ។

**ស៖** សូមអរគុណ។ តើលោកដឹងដោយរបៀបណាថា តាមធម្មតា តា នួន ជា ឬ តា ប៉ុល ពត ដែលវត្តមាននៅក្នុងសន្និបាតភូមិភាគនោះ?

[១១:៤៦:៣៤]

**ឆ៖** បាទ វត្តមានដែលមានគឺ ថ្នាក់ដឹកនាំខ្ពស់គឺឃើញ តាប៉ុល ពត, តាប៉ាល់, តាស៊ី, ហើយនិងបន្ទាប់មកខាងក្រោមៗ ឃើញ។ តានួន ជា អត់បានឃើញទេ កាលនោះ។

**ស៖** ខ្ញុំនឹងសួរសំណួរឡើងវិញ ដើម្បីឱ្យខ្ញុំយល់កាន់តែច្បាស់អ្វីដែលលោកបានដឹង។ លោកបាននិយាយថា តា នួន ជា ឬ តា ប៉ុល ពត តាមធម្មតាមានវត្តមាននៅក្នុងសន្និបាតភូមិភាគ--

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមជំទាស់លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី!

[១១:៤៧:៣២]

**លោក អេនឌ្រូ អ៊ីអៀនហ្វ៊ី៖**

សូមអរគុណ។ អ្វីដែលខ្ញុំអាចជម្រាបបានអំពីចម្លើយនេះ សាក្សីនិយាយថា តានួន ជា ឬក៏ តា ប៉ុល ពត តាមធម្មតាវត្តមាន...។ល។ ថាដូចនិយាយនឹងសំណួរ។ ដូច្នេះហើយចម្លើយរបស់គាត់គឺទៅតាមសំណួរដែលស្រង់ចេញពីចម្លើយសារភាពដោយអំពើទារុណកម្មដែលអ្នកស៊ើបអង្កេតបានយកមកសួរដោយនាំមុខ គឺសាក្សីមិនបានឆ្លើយដោយខ្លួនឯងទេ។ អានេះហើយជាជំហររបស់យើងខ្ញុំ នេះជាចំណុចដែលយើងខ្ញុំស្នើលើកពីម្សិលមិញ។ ថ្ងៃនេះក៏ដូច្នេះដែរថា ហើយសាក្សីត្រូវបានរងឥទ្ធិពលពីអ្នកស៊ើបអង្កេត ដើម្បីផ្តល់ចម្លើយនេះ។ ឥឡូវនេះ គឺមិនអាចយកផ្នែកនេះមកសួរបានទៀតទេ។

[១១:៤៨:១៧]

**លោក អាប់ឌុលឡាក់ ថាវីក៖**

ខ្ញុំសូមឆ្លើយតប លោកប្រធាន ហើយមេធាវីការពារក្តីបាននិយាយថា គឺថាពាក្យទាំងអស់នេះមិនមែនចេញពីមាត់របស់អ្នកអង្កេតទេ គឺជាពាក្យរបស់សាក្សី។ មិនមែនស្រង់ចេញពីចម្លើយសារភាពនោះទេ អានេះជាពាក្យរបស់គាត់ របស់សាក្សីនេះ ហើយគាត់បញ្ជាក់ច្បាស់អម្បាញ់មិញនេះថា ជាពាក្យរបស់គាត់ ហើយខ្ញុំសួរគាត់ឲ្យគាត់ផ្តល់តែព័ត៌មានអ្វីដែលគាត់ចាំ អ្វីដែលគាត់ដឹង។ នេះហើយ ខ្ញុំចង់ឲ្យគាត់បំភ្លឺថា តើព័ត៌មាននេះចេញពីការចងចាំរបស់គាត់ឬក៏ផ្អែកលើអ្វីផ្សេង? ហើយនិងខ្ញុំបន្តទៅ។

**លោក អេនឌ្រូ អ៊ីអៀនហ្វ៊ី៖**

*(គ្មានការបកប្រែ)--*

**ប្រធានអង្គជំនុំ៖**

មិនអានុញ្ញាតឲ្យលោកធ្វើសេចក្តីតបទៅនឹងសេចក្តីដូច្នេះទេ យើងបានកំណត់វិធីសាស្ត្រនៅក្នុងការដេញដោលនេះ ពេញមួយកិច្ចដំណើរការសវនាការតាំងពីដើមរហូតដល់ពេលនេះ។

[១១:៤៩:២០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥០:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយសូមតំណាងសហព្រះរាជអាជ្ញា មានការប្រុងប្រយ័ត្នក្នុងការរៀបចំនូវសំណួរ សម្រួល កែសម្រួលនូវសំណួររបស់លោកឲ្យបានមានលក្ខណៈល្អ មានលក្ខណៈកណ្តាល ដើម្បីជាការរំឭក ឬការសួរផ្ទាល់ក្នុងការបញ្ជាក់ការចងចាំរបស់សាក្សី ពីព្រោះនាពេលនេះមានវត្តមាន សាក្សីចំពោះមុខលោកហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាក្សី មាស វឿន ផ្អែកលើការចងចាំរបស់លោក តើត្រឹមត្រូវដែរឬទេថា ប៉ុល ពត ឬ នួន ជា តាមធម្មតា គឺចូលរួមនៅក្នុងសន្និបាតរបស់ភូមិភាគ?

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមជំទាស់លោកប្រធាន។ គឺថាជាផ្នែកដដែលនៃភស្តុតាង បានសួរពីដងហើយសហព្រះរាជអាជ្ញានៅក្នុងចំណុចនេះ។ គាត់និយាយអំពី ប៉ុល ពត ហើយគាត់មិននិយាយអំពី នួន ជា ទេ ប៉ុន្តែនៅក្នុង -- សាក្សីថា ឈ្មោះ នួន ជា នោះដោយសារថាអ្នកអង្កេតផ្តល់ពាក្យហ្នឹងទេ ដែលគាត់ឆ្លើយនោះ។ ដូច្នេះហើយគឺយើងអាចនឹងមើលប្រតិចារឹកឡើងវិញ។ នេះគឺជានៅក្នុងចម្លើយ១៧ ដែលខ្ញុំ អ៊ំ! ១៦ ដែលខ្ញុំបានស្នើតុលាការម្សិលមិញ។ លោកប្រធានបញ្ជាក់ គឺថាបើសិនជា មានវិការៈនីតិវិធី គឺត្រូវដោះស្រាយដោយដីការដំណោះស្រាយ ប៉ុន្តែពេលនេះ យើងឃើញមានកំហុសធ្ងន់នៅក្នុងចម្លើយរបស់សាក្សីតាមកំណត់ហេតុនេះ។ ដូច្នេះបានជាយើងខ្ញុំ ជំទាស់ ហើយនិងលើកសំណើបាទ។

**លោក អាប់ឌុលឡាក់ ថារីក៖**

មេធាវីការពារ ដូចជាលោកយល់ច្រឡំ។ បាទ សូមអភ័យទោស។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥២:៤៤]

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា

មិនមានមូលដ្ឋានត្រឹមត្រូវទេ។ ដូច្នេះ សេចក្តីជំទាស់ហ្នឹង គ្មានប្រសិទ្ធភាព។

សាក្សីឆ្លើយតបទៅនឹងសំណួរ ដែលមានលក្ខណៈទូទៅដែលជាសំណួរបំណងបញ្ជាក់ នូវការចងចាំរបស់សាក្សីផ្ទាល់ទៅលើបញ្ហានេះ។ ប្រសិនបើសាក្សីចងចាំគឺអាចឆ្លើយបាន ហើយបើមិនចងចាំទេ សុំឱ្យលោកតំណាងសហព្រះរាជអាជ្ញា តាំងសំណួរចុងក្រោយអម្បាញ់មិញនេះឡើងវិញ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំសូមអនុញ្ញាតដើម្បីសួរឡើងវិញ។ លោក មាស វឿន ការចងចាំរបស់លោកតើត្រូវដែរឬទេថា ប៉ុល ពត ឬ នួន ជា តែងតែចូលរួមសន្និបាតរបស់ភូមិភាគនោះ?

**លោក មាស វឿន៖**

**ឆ៖** បាទ ក្នុងសំណួរខ្ញុំ ខ្ញុំថា ខ្ញុំចាំមិនច្បាស់ទេ ក៏ប៉ុន្តែក្នុងពេលនោះ ក្នុងពេលប្រជុំភូមិភាគតែងតែមាន ក៏ប៉ុន្តែខ្ញុំមិនបានឃើញលោក នួន ជា ក្រែងអវត្តមាន ឬក៏គាត់រវល់យ៉ាងណានោះ មិនដឹង។

[១១:៥៤:២៩]

**ស៖** សូមអរគុណ។ លោកក៏បាននិយាយផងដែរនៅក្នុងឯកសារ E3/80 នៅក្នុងសំណួរចម្លើយ ១៩ គឺថា នៅក្នុងសន្និបាតទាំងពីរ ដែលលោកបានចូលរួម គឺមានការពិភាក្សា អំពីការបោសសម្អាតខ្មាំងដែលជាខ្មាំងស៊ីរូងផ្ទៃក្នុង ហើយនិងសកម្មភាពរបស់ពួកខ្មាំងវៀតណាម។ តើអ្នកណាជាអ្នកពិភាក្សាអំពីការបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុងនេះ?

**លោក អេនគ្រូ អ៊ីនួហ្ស៊ី៖**

សូមជំទាស់ម្តងទៀតលោកប្រធាន គឺថានេះគឺជា អាចដូចជាផ្លែឈើ យកមកពីដើមឈើដែលពុលដដែលហ្នឹង យកមកហូប។ ដូច្នេះហើយគឺៗ ចម្លើយនេះត្រូវបានដាក់ទៅឱ្យសាក្សី ព្រលយទៅឱ្យសាក្សី ហើយសាក្សីឆ្លើយឥឡូវនេះគឺថា នេះហើយគឺជាភស្តុតាងប្រតិឃាត ដែលថាភស្តុតាងមានភាពប្រឡាក់ប្រឡូកនឹងអំពើទារុណកម្ម។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមអនុញ្ញាតទៅនឹងបន្តទៅទៀត។ ថ្ងៃនេះ យើងខ្ញុំបាត់បង់ពេលវេលាច្រើនណាស់ យើងមានពេលមានកម្រិត។ នេះគឺជាការជំទាស់មិនមានមូលហេតុ មូលដ្ឋានទាល់តែសោះ ហើយបើសិនជាអង្គជំនុំជម្រះអនុញ្ញាតឱ្យទៅមុខ ខ្ញុំនឹងទៅមុខ។

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំនឹងរីករាយនឹងជូនពេលទៅសហព្រះរាជអាជ្ញាបន្ថែម បើសិនជាលោកត្រូវការពេលចាំបាច់ដោយសារការខាតបង់ដោយសារការជំទាស់នេះ។

**ប្រធានអង្គជំនុំ៖**

មិនមែនលោកអ្នកផ្ដល់ពេលវេលាទេ។ ពេលវេលាយើងជាអ្នកសម្រេច ឲ្យ ឬមិនឲ្យខាងអង្គជំនុំជម្រះទេ អ្នកសម្រេច។ មិនមែនលោកមេធាវី មានសិទ្ធិសម្រេចថាឲ្យទៅ -- មេធាវីទៅភាគី ពេលវេលាទៅភាគីម្ខាងទៀតនោះទេ។ ក្រែងលោមេធាវីមានការភ័ន្តច្រឡំតួនាទីរបស់ខ្លួន។

[១១:៥៦:៣៧]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៨:០៤]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់ និងសំអាងហេតុនៃសេចក្ដីជំទាស់របស់មេធាវីអន្តរជាតិការពារក្ដីលោក នួន ជា មិនមានមូលដ្ឋានគ្រប់គ្រាន់តាមផ្លូវច្បាប់ទេ។ ដូច្នេះសេចក្ដីជំទាស់ហ្នឹងមិនមានប្រសិទ្ធភាពទេ។

លោកតំណាងសហព្រះរាជអាជ្ញា អាចបន្តការតាំងសំណួរចំពោះសាក្សីរូបនេះ។ ប៉ុន្តែសហព្រះរាជអាជ្ញាគប្បីប្រើប្រាស់នូវការយល់ដឹងរបស់ខ្លួន ក្នុងការតាំងសំណួរ នូវការយល់ដឹង ឬបទពិសោធន៍ផ្ទាល់របស់សាក្សី ជាការសមស្រប ពីព្រោះកំណត់ហេតុទាំងអស់នេះ គឺបានបញ្ជាក់រួចហើយ ហើយបានដាក់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបន្តសួរទៅសាក្សីរូបនេះ ផ្អែកលើការចងចាំ និងបទពិសោធន៍របស់គាត់។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាក្សី ខ្ញុំនឹងសួរសំណួរចុងក្រោយលើកមុននេះ។ តើអ្នកណាជាអ្នកពិភាក្សាអំពីការបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង ដែលគេប្រជុំនៅក្នុងសន្និបាតភូមិភាគនោះ?

**លោក មាស វឿន៖**

**ឆ៖** មានតា ប៉ុល ពត ហើយនិង តាស៊ី, តាប៉ាល់។

**សះ** នៅក្នុងនេះ នៅក្នុងចម្លើយមួយទៀត គឺឯកសារ E3/73 នៅសំណួរ និងចម្លើយលេខ១១។ លោកបាននិយាយដូចខាងក្រោមនេះ "ខ្ញុំបានចូលរួមសន្និបាតពីរលើក ដែលមានតា នួន ជា ឬតា ប៉ុល ពត ចូលរួមនៅខេត្តកំពង់ស្ពឺ និងនៅបន្ទាយលង្វែកខេត្តកំពង់ឆ្នាំង"។ តើមានមូលហេតុអី ដែលលោកឆ្លើយថា "ដែលមានតា នួន ជា ឬតា ប៉ុល ពត ចូលរួម" តើផ្អែកលើការចងចាំផ្ទាល់របស់លោកដែរឬទេកាលឆ្លើយនោះ?

[១២:០០:២៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញ!

**លោក សុន អរុណ៖**

ខ្ញុំសូមជំទាស់សំណួររបស់ព្រះរាជអាជ្ញា សួរអំមិញត្រង់ថា "ខ្ញុំបានចូលបានចូលរួមប្រជុំសន្និបាតចំនួនពីរលើក ដែលមានតា នួន ជា ឬតា ប៉ុល ពត"។ ពាក្យ "ឬ" មួយម៉ាត់មានន័យថា មិនប្រាកដមិនដឹងជា នួន ជា ក៏មិនដឹង ប៉ុល ពត ទេ។ ម៉្លោះហើយយកជាការអត់បាន ខ្ញុំនឹងបដិសេធនូវសំណួរនេះលោកសួរនៅក្នុងការប៉ាន់ស្មាន ដើម្បីសាក្សីឆ្លើយក្នុងការប៉ាន់ស្មានរបស់ខ្លួន។ សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំគ្រាន់តែសួរសាក្សីនៅក្នុងចម្លើយមួយទៀត ដែលគាត់បានបញ្ជាក់ឈ្មោះ នួន ជា។ ថាហេតុអ្វីបានជាគាត់ឆ្លើយថា ឈ្មោះលោក នួន ជា? ហើយខ្ញុំស្តាប់ចម្លើយរបស់គាត់ផ្អែកលើការចងចាំរបស់គាត់ទេ បើមានការជំទាស់ ដូចជាការជំទាស់នោះមិនត្រឹមត្រូវបាទ។

**ប្រធានអង្គជំនុំ៖**

បាទសេចក្តីបដិសេធរបស់ -- ទៅនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញារបស់មេធាវីជាតិការពារក្តីលោក នួន ជា មិនមានមូលហេតុត្រឹមត្រូវទេ ទាំងទម្រង់ ទាំងខ្លឹមសារ។ អាចជំទាស់បានប៉ុន្តែបដិសេធនូវសំណួរដែលសួរ ដូចជាមិនមានចែងនៅក្នុងវិធានផ្ទៃក្នុង ក៏ដូចជានៅក្នុងច្បាប់នីតិវិធីកម្ពុជាទេ។ ដូច្នេះ សេចក្តីបដិសេធនឹងសំណួរនេះ គឺគ្មានប្រសិទ្ធភាព។

សាក្សីឆ្លើយតបទៅនឹងសំណួរ ដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញា!

[១២:០២:៣៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន ហើយយើងត្រឡប់សំណួរនេះវិញ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ចម្លើយដែលលោកបានឆ្លើយលោក មាស វឿន នៅពេលដែលលោកនិយាយថា “សន្និបាតដែលលោកបានចូលរួមនោះគឺថា មានតា នួន ជា ឬ ប៉ុល ពត វត្តមាន”។ តើហេតុអ្វីបានជាលោកអាចនិយាយបានថា តា នួន ជា ឬ ប៉ុល ពត វត្តមាននោះ?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំឆ្លើយសំអាងខ្ញុំឃើញ។ បើខ្ញុំអត់ឃើញថា នួន ជា គឺអត់ អត់មានការរវល់ តែខ្ញុំឃើញ ដែលខ្ញុំបានឆ្លើយអម្បាញ់មិញនេះ គឺខ្ញុំប្រាប់ថា ខ្ញុំឃើញ ប៉ុល ពត, តាប៉ុល ពត ខ្ញុំឃើញ តាស៊ីខ្ញុំឃើញ តាប៉ាល់។ ហ្នឹងខ្ញុំឆ្លើយថា ខ្ញុំឃើញ។

[១២:០៣:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលត្រូវសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយ សាមសិបនាទីរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាក នៅបន្ទប់រង់ចាំសម្រាប់សាក្សីអ្នកជំនាញដល់សាក្សី និងមេធាវីប្រឹក្សាគាត់ នៅក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងកំណត់អម្បាញ់មិញ គឺម៉ោងមួយ និងសាមសិបនាទីរសៀលនេះ។

សូមអញ្ជើញ!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

អរគុណលោកប្រធាន។ ហើយខ្ញុំមានចំណុចបីសង្ខេប ដើម្បីជម្រាប។ ទី១ គឺទាក់ទងទៅនឹងអ្វីដែលលោកទើបបានពិភាក្សានេះ។ ខ្ញុំត្រូវគោរព ហើយខ្ញុំមិនលើសពីជំហររបស់ខ្ញុំទេ ហើយខ្ញុំទទួលស្គាល់ថា គឺមានការខាតពេលខ្លះនៅក្នុងការជំទាស់ ខ្ញុំគ្រាន់តែព្យាយាមជម្រាបអង្គជំនុំជម្រះឲ្យច្បាស់ថាមេធាវីការពារក្តី គឺយើងមិនជំទាស់ទៅនឹងអ្វី បើសិនជាផ្តល់ពេលឲ្យសហព្រះរាជអាជ្ញាបន្ថែម ហ្នឹងគឺថា

ខ្ញុំអាចផ្តល់ពេល១៥នាទីពីខ្ញុំក៏បានដែរ ហើយខ្ញុំមិនព្យាយាមមិនប្រកាន់យកតួនាទីរបស់លោកប្រធានទេ។

[១២:០៤:៥២]

ចំណុចទី២ ទាក់ទងទៅនឹងសំណើដែលខ្ញុំបានលើកឡើងម្សិលមិញ គឺលទ្ធភាពដែលថា លោក នួន ជា អាចនឹងសុំពេលដើម្បីធ្វើមតិឆ្លើយតបទៅនឹងដីកាដំណោះស្រាយ។ ហើយដោយច្បាស់ទៅ ខ្ញុំមិនយល់ពីសេចក្តីសម្រេចរបស់លោកប្រធានទេ។ ខ្ញុំមើលប្រតិចារឹក ខ្ញុំមើលកម្មវិធីតាមដានការជំនុំជម្រះក្តីនៅកម្ពុជានេះគឺថា ហើយនិយាយថា ការស្តាប់សក្ខីកម្ម TCW-248 ដែលថា បាទគឺថា សាក្សី 428 ដើម្បីឱ្យយើងខ្ញុំច្បាស់ ថាតើដល់ចប់សាក្សី ទើបបានផ្តល់ពេលជូនលោក នួន ជា ឬក៏ពេលណាមួយបាទ? ខ្ញុំឃើញថា ចៅក្រម ខាតវ៉ាយថ៍ ដូចជាបង្ហាញសញ្ញាថាបាន។

[១២:០៥:៤៧]

**ប្រធានអង្គជំនុំ៖**

បាទ ជាភាសាខ្មែរ តាមយើងយល់ ដូចជាច្បាស់លាស់ហើយ នូវការសម្រេចរបស់អង្គជំនុំជម្រះថា សំណើសុំរបស់លោក នួន ជា ដែលចង់ធ្វើសេចក្តីថ្លែងការណ៍តបទៅនឹងបណ្តាកថាខណ្ឌ ដែលក្រឡាបញ្ជីនៃអង្គជំនុំជម្រះសាលាដំបូង បានអានចុងក្រោយដែលយើងកំណត់ថា វគ្គ៣ នៃសវនាការសំណុំរឿង០០២/០១ ហ្នឹងគឺ អង្គជំនុំជម្រះនឹងពិចារណា សម្រេចផ្តល់ឱ្យគាត់ នៅក្រោយពេលចប់នៅការសួរដេញដោលសាក្សី 428។ ហើយយើងជ្រើសរើសយកពេលណាមួយនៃព្រឹកដើមដំបូង ដើម្បីផ្តល់លទ្ធភាពជូនគាត់ ដើម្បីឱ្យគាត់ហ្នឹងមានឱកាសនៅក្នុងការថ្លែងការណ៍តបទៅនឹងវិសាលភាព នៃអង្គហេតុដែលអង្គជំនុំជម្រះបានចាត់តាំងក្រឡាបញ្ជីបីរូប បានអាននូវបណ្តាអង្គហេតុសេសសល់ក្នុងសំណុំរឿង០០២/០១។ យើងគិតថា ភាសាខ្មែរដូចជាអាចស្តាប់បាន សូម្បីតែជនសាមញ្ញជនក៏ស្តាប់បានដែរ ប៉ុណ្ណឹងវាដូចជាមិន -- មិនចាំបាច់មានការពន្យល់អីបន្ថែមទៀតទេ។

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

ខ្ញុំជ្រាប ខ្ញុំយល់ហើយ សូមអរគុណលោកប្រធានបាទ។ ខ្ញុំភ្លេចសំណើចុងក្រោយមួយគឺថា ខ្ញុំទទួលដំណឹងថា លោក នួន ជា គាត់ឈឺក្បាល ឈឺខ្នង ហើយជាទូទៅគឺ គាត់មិនបានចងចាំ -- ផ្តង់អារម្មណ៍ច្បាស់ទេ ហើយគាត់សុំអនុញ្ញាតទៅតាមដានសវនាការល្ងាចនេះ នៅពីបន្ទប់ខាងក្រោមនេះ ហើយខ្ញុំនឹងដាក់លិខិតបោះបង់សិទ្ធិរបស់គាត់ជូនតុលាការតាមនីតិវិធី។ សូមអរគុណ។

[១២:០៧:៥១]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានស្ដាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលធ្វើឡើងតាមរយៈមេធាវីការពារក្ដីរបស់គាត់សុំទៅតាមកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលនេះ ដោយមូលហេតុសុខភាពមិនអាចអង្គុយយូរបាននៅក្នុងបន្ទប់សវនាការ ដោយក្រុមមេធាវីការពារក្ដីរបស់គាត់សន្យាថា នឹងដាក់ពាក្យសុំលះបង់សិទ្ធិមកអង្គជំនុំជម្រះនាពេលឆាប់ៗខាងមុខនេះ។

អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅពីក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយលោក នួន ជា បានលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការក្នុងបន្ទប់សវនាការនេះ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្ដីលោក នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូល មានវត្តមាននៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការរបស់លោក នួន ជា។ ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនា-ការនេះ សម្រាប់រយៈពេលនៃកិច្ចដំណើរការសវនាការពេញមួយរសៀលថ្ងៃនេះ។

[១២:០៩:០៨]

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ខាងក្រោម ហើយនៅរសៀលនេះ ទុកឲ្យលោក នួន ជា ដែលរៀបចំជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ឡើងមកកាន់បន្ទប់សវនាការនេះវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៩ នាទី ដល់ម៉ោង ១៣:៣៣ នាទី)*

[១៣:៣៣:២៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

សូមអញ្ជើញលោកមេធាវី!

**លោក អេនគ្រូ អ៊ីនូហ្សុី៖**

សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម។ អរគុណលោកប្រធាន ហើយខ្ញុំៗមិនចង់ចំណាយពេលច្រើនបន្ទាប់នេះទេ។ ខ្ញុំមានសំណើខ្លីមួយ ទាក់ទងទៅនឹងអ្វីដែលនៅក្នុងកាសែតខាំបូឌាដេលីថ្ងៃនេះ ទាក់ទងទៅនឹងទំព័រមុខនៃអត្ថបទនោះ ចំណងជើងហ្នឹងគឺថា "សាលក្រមលោក ម៉ម សូណង់ដូ គឺជាការតេស្តទៅលើយុត្តិធម៌នៅកម្ពុជា"។ ខ្ញុំមិននិយាយលម្អិតទេ ប៉ុន្តែគួរតែយើងពិចារណាដូចជា លោកស្រីចៅក្រម ខាតវ៉ាយថ៍ លើកឡើងម្សិលមិញនោះ ខ្ញុំនឹងកត់ត្រានៅក្នុងកំណត់ត្រាតុលាការ។

ដូច្នេះគឺថា គេអត្ថបទនេះបញ្ជាក់ថា ជាការបរាជ័យនៃប្រព័ន្ធយុត្តិធម៌របស់កម្ពុជា ជាពិសេសតុលាការក្រុងភ្នំពេញ ហើយនៅអនាគតនេះ យើងនឹងមានពិភាក្សាលើឯកសារ។ ដូច្នេះ ឯកសារនេះ ខ្ញុំស្នើថា នឹងដាក់ជាការពិភាក្សាដែរ នៅក្នុងប្រកាសព័ត៌មានថ្ងៃនេះដែរ។ ហើយយើងខ្ញុំនឹងដាក់ពិភាក្សា ហើយយើងចង់ស្តាប់ចម្លើយនៅថ្ងៃចន្ទ ថាតើយើងគួរដាក់បរិបទនេះ កម្មវិធីនេះក្នុងពិភាក្សាដែរឬអត់ទេ? ខ្ញុំដកស្រង់ចេញពីអត្ថបទព័ត៌មាននេះ ដើម្បីៗថាតើសាធារណជនដឹងដែរឬទេ គេនិយាយថា "ក្រៅពីការកំណត់គំរូដ៏ល្អ គឺសាលាក្តីខ្មែរក្រហម គឺថា ធ្វើការងារផ្ទុយទៅៗ ផ្ទុយទៅវិញទេ"។ នេះជាការសែតស្រាវជ្រាវរបស់ភ្នាក់ងារអាស៊ី។ នេះជាបញ្ហាដែលត្រូវលើកឡើងពិភាក្សាជាសាធារណៈចំពោះមុខអង្គជំនុំជម្រះនេះ ទាក់ទងទៅនឹងកេរដំណែលរបស់តុលាការនេះ។

[១៣:៣៥:៤២]

**ប្រធានអង្គជំនុំ៖**

តាម -- សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាក្សី មាស វឿន។ ឥឡូវនេះ យើងត្រឡប់មកសំណួរដែលខ្ញុំសួរអំពីសន្និបាតភូមិភាគបស្ចិម ដែលយើងបានរៀបរាប់ពីខាងដើម មុនយើងសម្រាកពិសាអាហារថ្ងៃត្រង់នោះ។ ហើយយើងបាននិយាយអំពីសុន្ទរកថា ដែលយោងទៅរកការបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង និងខ្មាំងវៀតណាមនោះ។ អ្វីដែលខ្ញុំចង់សួរលោកបន្តទៅទៀត គឺខ្ញុំនឹងបង្ហាញជូនលោកនូវឯកសារមួយ ដែលមានសរសេរសុន្ទរកថា ដែលបានអាននៅក្នុងការប្រជុំនៅក្នុងខែកក្កដា ឆ្នាំ១៩៧៧ ដើម្បីឲ្យលោកពិនិត្យមើលខ្លឹមសារនៃសុន្ទរកថានោះ តើលោកបានចាំខ្លឹមសារ ឬក៏នឹកឃើញខ្លឹមសារ ដូចដែលសរសេរក្នុងសុន្ទរកថាហ្នឹងដែរឬទេ?

[១៣:៣៧:០៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានឯកសារ E3/193 គឺឯកសារទង់បដិវត្ត ថ្ងៃ -- ខែសីហា ឆ្នាំ១៩៧៧។ បាទ ហើយនិងខ្ញុំសូមអនុញ្ញាតពីតុលាការ ដើម្បីបង្ហាញឯកសារលើក្រដាសជូនសាក្សី និងបង្ហាញលើអេក្រង់កុំព្យូទ័រផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាស ពីតំណាងសហព្រះរាជអាជ្ញាយកជូនសាក្សីពិនិត្យ!

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក មាស វឿន នៅក្នុងទំព័រទី២ នៅក្នុងឯកសារនេះ ដែលមាននិយាយអំពីការរៀបរាប់អំពីតំណាងរបស់អង្គការ ដែលមានការណែនាំមួយចំនួននៅក្នុងការកសាង ការពង្រឹង បាទ ការកសាងដឹកនាំថ្នាក់បក្ស ដូចនៅក្នុងទស្សនាវដ្តីទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៧។ ជាឯកសារវែងមួយ ហើយខ្ញុំមិនអាចសង្ខេបខ្លឹមសារទាំងមូលទេ ប៉ុន្តែត្រង់កន្លែងដកស្រង់នេះ គឺខ្ញុំនឹងអានជូនអំពីផ្នែកខ្លះ នៃទស្សនា-វដ្តីនេះ ដើម្បីឲ្យលោកប្រាប់ខ្ញុំថា លោកចាំដែរឬអត់ខ្លឹមសារនោះ។ ទី១ នៅខ្មែរ ERN គឺ 00062949, បារាំង ERN 00611827, អង់គ្លេស ERN 00399224 ដែលនិយាយថា “ចលនាដែលថា បដិវត្តន៍ -- ធាតុដែលប្រឆាំងនឹងបដិវត្ត ជាធាតុមិនល្អ ជាក្រុមប្រឆាំង។ ដូច្នេះយើងត្រូវ -- បាទសមាសភាពទាំង

អស់នេះត្រូវចលនាមហាជន គឺកម្ទេច"។ ហើយខ្ញុំនឹងអាននូវផ្នែកផ្សេងមួយទៀត ហើយមុននឹងខ្ញុំសួរ សំណួរ នៅខ្មែរ ERN 00062952, បារាំង ERN 00611829 រហូតដល់ 30, អង់គ្លេស 00399226។ នៅនេះគឺយើងមានសុន្ទរកថា ដែលនិយាយអំពីស្ថានភាពនៅក្នុងតំបន់មួយចំនួន ហើយនិងតំបន់៣៧ ដែលជាគោលដៅ ជាតំបន់ដែលលោកបានរស់នៅទីនោះ។

[១៣:៤០:០៨]

សុន្ទរកថានោះនិយាយថា សូមដកស្រង់ "តំបន់៣៧ ក៏ដូចគ្នានេះដែរ ប្រៀបធៀបតំបន់៣៧នេះ នៅមានស្មុគស្មាញជាងតំបន់៣១, ៣២ ពីព្រោះថាមានសមាសភាពថ្មី ហើយវាមានច្រើន។ ហើយជាប្រវត្តិមិនល្អ កោះកុងក៏មានក្បត់ ក្បត់តាំងពីដើមមក។ នៅឆ្នាំ១៩៧៤ បានយើងដោះស្រាយបានហើយ កាន់កាប់បានល្អ"។ ឥឡូវនេះ យើងមើលខ្លឹមសារពីរ ដែលខ្ញុំដកស្រង់អម្បាញ់មិញនេះ តើវាអាចធ្វើឱ្យលោកនឹកឃើញដែរឬទេ ឬក៏លោកនៅចាំដែរឬទេ អំពីសុន្ទរកថា ឬក៏ការដែលគេនិយាយក្នុងអង្គប្រជុំ ដូចដែលខ្លឹមសារខ្ញុំបានអានដោយសង្ខេបនេះ ដកស្រង់នេះ?

[១៣:៤១:០៦]

**ឆ៖** បាទ ក្នុងនោះខ្ញុំ -- ក្នុងជួរកងទ័ពមិនសូវបានឮទេ ព្រោះនៅឆ្ងាយពីតំបន់ស្រែអំបិល។

**ស៖** ខ្ញុំនឹងអានពីរផ្នែកខ្លីៗទៀត ដើម្បីឱ្យលោកពិនិត្យមើលថាតើលោកដឹងដែរឬទេ នៅខ្មែរ គឺ 00069656, បារាំង 006118339 (ស៊ីក), អង់គ្លេស 00399229។ ខ្ញុំដកស្រង់ "យើងបានធ្វើការវាយតម្លៃឱ្យច្បាស់អំពីមាគ៌ាបក្ស។ ដោយសារថាមិនដូចការណែនាំរបស់បក្ស ដោយមិនមានការយល់ដឹងនោះទេ បក្សលើកគោលការណ៍នេះ គឺផ្អែកលើស្ថានភាពជាក់ស្តែង ដើម្បីវិភាគឱ្យបានច្បាស់លាស់"។ នៅខាងក្រោមនោះបន្តិច និយាយបន្តទៀតថា "ឧបមាថា តំបន់៣៧ ដែលខ្ញុំបាននិយាយប្រវត្តិពីមុន ពួកអាចុង កាន់កាប់រហូត ក្រោយមក ពួកអាញឹកកាន់កាប់រហូត។ វាកសាងនូវ -- ទៅជាបក្ខជន ទៅជាកម្មាភិបាល ទៅជាកងទ័ព។ កន្លែងនេះ ដែលត្រូវប្រុងប្រយ័ត្ន ហើយនិងប្រយ័ត្នតាមប្រភពដែលពួកនេះកសាង។ យើងត្រូវយកចិត្តទុកដាក់ប្រយ័ត្នប្រយែង"។ តើខ្លឹមសារនេះ ថាតើនេះជាការនិយាយសំដៅទៅបុគ្គល ដែលលោកបានស្គាល់ដែរឬទេ នៅក្នុងតំបន់៣៧នោះ?

[១៣:៤៣:១២]

**ឆ៖** បាទ ខ្ញុំមិនបានដឹងថា ការនិយាយទៅឈ្មោះអ្នកណា ឬក៏ទៅលើឈ្មោះអ្នកណានោះទេ។ ប៉ុន្តែគ្រាន់តែថា ឮតាមរយៈមិត្តភក្តិដែលនិយាយប្រាប់ ប៉ុន្តែក្នុងនោះ គឺការនិយាយនោះ អ៎! ដំណើរការ

គេប្រជុំនោះ ខ្ញុំមិនបានចូលរួមប្រជុំទេ។

**ស៖** នៅក្នុងសុន្ទរកថាដែលលោកបានឮ ដែលយើងបានពិភាក្សាពីខាងដើមនោះ អំពីការពិភាក្សាអំពីការបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង។ តើសុន្ទរកថាទាំងអស់នោះ ស្រដៀងទៅនឹងខ្លឹមដែលខ្ញុំទើបតែបានអានជូនលោកស្តាប់នេះដែរឬទេ?

**ឆ៖** បាទ មាន។

[១៣:៤៤:២៧]

**ស៖** ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតចូលទៅឯកសារមួយចំនួនទៀត ដើម្បីឲ្យលោកពិនិត្យមើល ថាតើលោកអាចនៅនឹកឃើញ ឬក៏ចាំឈ្មោះនៅក្នុង -- ឈ្មោះមនុស្សនៅក្នុងនោះដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម ឯកសារបន្ទាប់នេះ ខ្ញុំនឹងចង់បង្ហាញជូនសាក្សីគឺឯកសារ E3/1220។ នេះជារបាយការណ៍ ដែលរៀបចំឡើងដោយមន្ទីរ ម-៤០១។ សូមអនុញ្ញាតពីលោកប្រធាន ដើម្បីជូនឯកសារលើក្រដាស ទៅលោកសាក្សីដើម្បីពិនិត្យ បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៣:៤៥:២៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** នៅខាងផ្តើមចុង -- ដើមបំផុតនៃឯកសារនេះ "ជូន ជម្រាបជូនអង្គការជាទីគោរពស្នេហា។ សូមរាយការណ៍ជូនអង្គការបន្ថែមអំពីសកម្មភាពបោសសម្អាតពួកអាក្បត់នៅក្នុងជួរទូទាំងភូមិភាគ"។ យើងមើលទៅខាងក្រោមបន្តិច នៅខ្មែរ ERN 00021511, បារាំង ERN 00532782, អង់គ្លេស 00583934 ជាបញ្ជីរាយឈ្មោះបុគ្គលនៅក្នុងភូមិភាគ តំបន់ -- នៅក្នុងតំបន់៣៧ ដែលត្រូវបោស

សម្អាត។ នៅកន្លែងនេះគ្មានកត់ត្រាឈ្មោះមនុស្ស ឈ្មោះ ទីន ជាសមាជិកតំបន់នៅលេខាស្រុកស្រែអំបិល។ តើលោកស្គាល់បុគ្គលនេះទេ មនុស្សនេះទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ អត់! អត់ស្គាល់ទេ។

**ស៖** ហើយបុគ្គលនៅខាងក្រោម នៅលេខ២ ឈ្មោះ សា វ៉ាត លេខាស្រុកព្រៃនប់ និងស្រុកស្រែអំពិល។ តើលោកស្គាល់គាត់នេះដែរឬទេ?

**ឆ៖** បាទ ស្គាល់។

[១៣:៤៧:២២]

**ស៖** តើនេះជាឈ្មោះមនុស្សម្នាក់ដែលបាត់ខ្លួន ក្នុងពេលដែលលោកធ្វើការនៅភូមិភាគបស្ចិមដែរឬទេ?

**ឆ៖** បាទ តាមឈ្មោះ សាវ៉ាត មិនបាត់ទេ ពីព្រោះគាត់របួស ពីមុនយោធា ដឹកពីរះពោះទៅគាត់ចេញ ហើយគេឲ្យគាត់សម្រាក គាត់មិនបាន -- ហើយក្រោយមកដឹងគាត់ -- គេយកគាត់ទៅខាងណាទៀត ខ្ញុំមិនដឹង ប៉ុន្តែគាត់មិនស្លាប់ទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះយើងពិនិត្យមើលឯកសារមួយផ្សេងទៀត។ ប្រហែលយើងមុនទៅនឹងដល់នោះ ខ្ញុំចង់ឲ្យប្រាកដថា យើងឲ្យបានកត់ត្រាពេញលេញ។ នៅក្នុង១ការសម្ភាស E3/73 នោះ នៅត្រង់សំណួរទី៤ ដែលថា "មន្ទីរ៤០១ គឺជាមន្ទីររបស់ តាស៊ី"។ តើនេះជាការសង្ខេបត្រឹមត្រូវដែរឬទេ ដែលលោកបញ្ជាក់ថា មន្ទីរ ម-៤០៤ (ស៊ីក) គឺជាមន្ទីររបស់ តាស៊ី, ជូ ជេត ហៅ ស៊ី, ៤០១ នោះបាទ?

**ឆ៖** បាទ មន្ទីររបស់គាត់មែន ប៉ុន្តែអត់នរណាហ៊ានចូលបានទេ ខ្ញុំក៏មិនអាចចូលបាន ចូលបានតែ បងសឿង។

[១៣:៤៩:១៨]

**ស៖** សូមអរគុណ។ ឥឡូវនេះយើងទៅឯកសារមួយផ្សេងទៀត គឺយើងមានរបាយការណ៍មួយទៀតដែលចេញមកពី ម-៤០១ គឺឯកសារ E3/1094។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រមខ្ញុំមានឯកសារលើក្រដាស ហើយសូមអនុញ្ញាតដើម្បីបង្ហាញជូនសាក្សី

ពិនិត្យផងដែរ បាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីតំណាងសហព្រះរាជអាជ្ញា យកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៣:៥០:០៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឯកសារនេះផ្ញើជូនអង្គការជាទីគោរព ជាទីស្រឡាញ់ ជារបាយការណ៍ប្រចាំខែជូនអង្គការ។ ផ្នែកមួយដែលខ្ញុំចង់ពិនិត្យមើល គឺទាក់ទងទៅនឹង ទៅតំបន់៣៧។ យើងពិនិត្យមើលខ្មែរ ERN 00143610, បារាំង ERN 00593530 ហើយនិងភាសាអង់គ្លេស 00315374។ ចំណងជើងនៅនេះគឺថា ចំណងជើងលោកសាក្សី មាស វឿន គឺ “តំបន់៣៧” នៅខាងក្រោមនោះ គឺនិយាយអំពី “សភាពការណ៍ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង”។ មានចំណងជើងមួយទៀត គឺថាពីរបីបន្ទាត់ខាងក្រោមនោះ ដែលនិយាយអំពី “ការសម្រិតសម្រាំងសមាសភាពយួន ភ្នាក់ងារ សេ.អ៊ី.អា។ ទី១. កម្ទេចជាតិយួន ទាំងតូចទាំងធំ ទាំងអស់ ទាំងក្មេង អស់ចំនួន១០០នាក់។ ទី២. កម្ទេចពួកអាណា -- ពួកបណ្ដាសក្តិ និងពួកសេ.អ៊ី.អា របស់ចក្រពត្តិអាមេរិកាំងដែលនៅបង្កប់ក្នុងអង្គភាព និងសហករណ៍ អស់ចំនួន ៦០នាក់”។ នេះមានរៀបរាប់អំពីការកម្ទេចជនជាតិវៀតណាមដ៏ចំនួនច្រើននៅក្នុងតំបន់៣៧។ តើលោកបានដឹងអំពីការសម្រិតសម្រាំងៗជនជាតិវៀតណាមទាំងអស់នេះដែរឬទេ លោកសាក្សី?

[១៣:៥២:០៨]

**លោក មាស វឿន៖**

**ឆ៖** បាទ អត់បានដឹងទេ។

**ស៖** នៅពេលនេះគឺថា យើងមានការយោងទៅរក សេ.អ៊ី.អា ជារបស់ចក្រពត្តិអាមេរិក បាទ ហើយនិងពួកមានបណ្ដាសក្តិ។ នៅពេលដែលគេដកមនុស្សចេញពីកងពលលេខ១ ហើយមានអ្នកខ្លះ

គេចោទថាជាភ្នាក់ងារ សេ.អ៊ី.អា ឬក៏ជាអ្នកដែលជាប់ពាក់ព័ន្ធទៅនឹង សេ.អ៊ី.អា?

**ឆ៖** សូមលោកបញ្ជាក់ម្តងទៀត!

**ស៖** បាទ នៅកន្លែងនេះមានសរសេរអំពីការកម្ទេចសម្រិតសម្រាំងពួកភ្នាក់ងារ សេ.អ៊ី.អា។ សំណួររបស់ខ្ញុំ នៅពេលដែលគេដកកងទ័ព ឬក៏ទាហានចេញពីកងពលលេខ១ តើមានអ្នកណាខ្លះដែលគេចោទថាពាក់ព័ន្ធទៅនឹងភ្នាក់ងារ សេ.អ៊ី.អា ដែរឬទេ?

[១៣:៥៣:៣៣]

**ឆ៖** បាទ កាលនោះមាន។ ចំពោះ សេ.អ៊ី.អា ហើយនិងអ្នកដែលជាប់មាននិន្នាការ។

**ប្រធានអង្គជំនុំ៖**

សូម សូមផ្អាកសិនសាក្សី! សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអភ័យទោសលោកសហព្រះរាជអាជ្ញា ដែលបានកាត់ផ្តាច់ ប៉ុន្តែដើម្បីឲ្យមានការភាពច្បាស់លាស់នៅក្នុងជជែកដេញដោលនោះ។ សូមឲ្យលោកបញ្ជាក់ឲ្យបានច្បាស់អំពីកាលបរិច្ឆេទនៃរបាយការណ៍នេះ។ គឺថាតើពាក់ព័ន្ធទៅនឹងការងារដែលនៅក្នុងតំបន់៣៧ ដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកចៅក្រម ឡាវែន៍។

[១៣:៥៤:៤៤]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក មាស វឿន ឯកសារនេះចុះថ្ងៃទី៤ ខែសីហា ឆ្នាំមួយពាន់ប្រាំបួនរយ -- ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៨។ មកដល់កាលបរិច្ឆេទនេះ ខ្ញុំគួរបញ្ជាក់ថានេះជា "របាយការណ៍ប្រចាំខែកក្កដា ឆ្នាំ៧៨ នោះ"។ តើនៅក្នុងឆ្នាំ១៩៧៨ នេះ តើលោកនៅកោះកុងដដែលដែរឬទេ?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំចេញពីកោះកុងមកហើយ។

**ស៖** មុននឹងចូលទៅទីតាំងផ្សេងទៀត ខ្ញុំមានសំណួរមួយចំនួនទៀតអំពីសកម្មភាពនៅក្នុង -- របស់លោកនៅក្នុងកងពលលេខ១។ តើគេធ្លាប់តម្រូវឲ្យលោកទៅចូលរួម -- តើគេណែនាំលោកឲ្យទៅចូលរួមប្រជុំណាមួយនៅទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានចូលរួមប្រជុំកន្លែងណាមួយនៅក្រុងភ្នំពេញនោះទេ។

[១៣:៥៦:២៥]

**ស៖** តើហេតុការណ៍ផ្សេងៗដូចជាពិធីប្រារព្ធខួប? តើលោកធ្លាប់ធ្វើដំណើរមកភ្នំពេញ ដើម្បីចូលរួមក្នុងពិធីបុណ្យខួបអ្វីផ្សេងៗទៀតដែរឬទេ?

**ឆ៖** បាទ អត់បានធ្វើទេ ធ្វើតាមកន្លែងរបស់ខ្លួន។

**ស៖** តើលោកសាក្សី មាស វឿន ត្រូវការសម្រាកឬទេបាទ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសាក្សី ចង់ទៅបន្ទប់ទឹក? សូមអញ្ជើញ!

*(សាក្សីចាកចេញពីបន្ទប់សវនាការ)*

[១៣:៥៧:៣៧]

**លោក អេនត្រូ អ៊ីន្ទូហ្វ៊ី៖**

លោកប្រធាន ខ្ញុំចង់ប្រើពេលនេះដើម្បីថ្លែងជូនតុលាការ។ ជាការគួរឲ្យខ្មាសអៀនដែលសហព្រះរាជអាជ្ញា ហើយគួរឲ្យយើងមានការខ្មាសអៀនដែរ ចំពោះចៅក្រមដែលថាមានការកែប្រែអង្គហេតុ។ ហើយមានហេតុការណ៍កើតមានឡើង គឺថាធ្វើឲ្យយើងមិនសប្បាយចិត្តចំពោះដំណើរការនីតិវិធីដែលអនុវត្តនៅទីនេះ ហើយដោយសមាជិកខ្លះនៃតុលាការនៅទីនេះ។ នៅពេលដែលមានការកាត់មីក្រូហ្វូនរបស់ខ្ញុំអាចមានន័យថា គេមិនចង់ស្តាប់សំឡេងរបស់ខ្ញុំ ដូច្នេះ -- ហើយគេអាចយល់ថាធ្វើឲ្យខ្ញុំជាអ្នករំខានដល់ដំណើរការនីតិវិធី។

[១៣:៥៨:២៤]

ដូច្នេះ យើងចង់បានកេរដំណែលល្អពីតុលាការនេះជាវិជ្ជមានទៅលើប្រព័ន្ធយុត្តិធម៌ជាតិ។ ប្រសិនបើយើងត្រូវប្រឈមមុខ--

**ប្រធានអង្គជំនុំ៖**

យើងយល់ថាលោកមានហេតុផលរបស់លោកក្នុងការប៉ុនប៉ងដាក់ឯកសារថ្មី ចំពោះមុខអង្គជំនុំជម្រះ។ ការដាក់ឯកសារថ្មី អង្គជំនុំជម្រះបានណែនាំរួចហើយ ថាបើមានការដាក់ឯកសារថ្មី ភាគីដែលពាក់ព័ន្ធធ្វើសំណើជាលាយលក្ខណ៍អក្សរ ដោយមានសំអាងហេតុសព្វគ្រប់ដូចមានចែងនៅក្នុងវិធាន ៨៧(៣) និយាយរួមគឺវិធាន៨៧ និង៨៧(៣) មក អង្គជំនុំជម្រះនឹងពិចារណាសម្រេច។ អង្គជំនុំជម្រះ

មិនមែនធ្វើដើម្បីលោកសប្បាយចិត្តទេ គឺធ្វើដើម្បីត្រឹមត្រូវ ដើម្បីភាពជឿនលឿន យុត្តិធម៌ ដើម្បីឲ្យមានប្រសិទ្ធភាព។ មិនមែនចេះតែឲ្យលោកលើកអីក៏បានតាមតែចិត្តនោះទេ ការលើកគឺមានហេតុផលរបស់វានៅក្នុងការលើកបញ្ហា ដោយសារបញ្ហានេះជាបញ្ហាថ្មី ដែលលោកមានបំណង ប៉ុន្តែលោកធ្វើហ្នឹងគឺវាខុសជាមួយនឹងសេចក្តីណែនាំរបស់អង្គជំនុំជម្រះដែលបានធ្វើច្រើនលើក ច្រើនសារួចមកហើយ អំពីការដាក់ឯកសារថ្មីត្រូវធ្វើតាមនីតិវិធីណា។ បើសិនលោកមានបំណងដាក់ឯកសារថ្មីដែលលោកបានលើកឡើងអម្បាញ់អំមិញនេះ សូមលោកគោរពតាមការណែនាំរបស់អង្គជំនុំជម្រះឲ្យសរសេរពាក្យសំណើសុំជាលាយលក្ខណ៍អក្សរ។

អង្គុយចុះ! យើងមិនអនុញ្ញាតឲ្យលោកនិយាយអ្វីទៀតទេ។

**ប្រធានអង្គជំនុំ៖**

ព្រះរាជអាជ្ញាបន្តការងាររបស់លោក!

[១៤:០០:៥៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាក្សី ពីមុននេះយើងបានពិភាក្សាអំពីពេលវេលានៃការចាកចេញរបស់លោកពីកោះកុង។ យើងនឹងពិភាក្សាអំពីពេលវេលាដែលលោកទៅធ្វើការនៅព្រះវិហារវិញ ប៉ុន្តែឥឡូវនេះខ្ញុំចង់និយាយយោងទៅលើចម្លើយតបរបស់លោកមួយទាក់ទងទៅនឹងការកំណត់ពេលវេលា គឺ E3/424 គឺនៅត្រង់សំណួរចម្លើយទី១៩ លោកបានបញ្ជាក់ថា "លោកទៅគ្រប់គ្រងនៅតំបន់ក្នុងព្រះ -- នៅក្នុងខេត្តព្រះវិហារ នៅក្នុងខែសីហា ឆ្នាំ៧៨"។ តើវាអាចធ្វើឲ្យលោកនឹកឃើញទៅពេលវេលាដែលលោកទៅទីនោះដែរឬទេ? តើគឺនៅក្នុងខែសីហា ឆ្នាំ៧៨ ដែលលោកចាកចេញពីខេត្ត -- ចាកចេញពីកោះកុង ឬក៏លោកចាកចេញពីកោះកុងមុនពេលនេះ?

**លោក មាស វឿន៖**

**ឆ៖** បាទ កាលដែលខ្ញុំចាកចេញពីកោះកុងទៅព្រះវិហារនោះ ខែ៦៨ ឆ្នាំ៧៨ គឺខ្ញុំចេញពីកោះកុងទៅព្រះវិហារ បាទ។

**ស៖** ដូច្នេះលោកចាកចេញពីខេត្តកោះកុងនៅខែ៨ ឆ្នាំ១៩៧៨? តើលោកធ្វើដំណើរទៅកោះកុង

ហ្នឹងតាមមធ្យោបាយអ្វីដែរ? តើៗនៅពេលដែលលោកចាកចេញពីកោះកុងទៅហ្នឹង តើលោកធ្វើដំណើរតាមទិសណាដែរ? តើលោកឆ្លងកាត់ទីក្រុងភ្នំពេញមុនទៅដល់ព្រះវិហារ ឬមួយយ៉ាងម៉េចដែរ?

[១៤:០៣:២២]

**ឆ៖** បាទ ខ្ញុំចេញពីកោះកុងមក មកតាមសមុទ្រក្នុងជិះកាណូតមកចុះស្រែអំបិល ហើយចេញពីស្រែអំបិលមក ឡានរបស់កងពលមកយកខ្ញុំពីស្រែអំបិលមកភ្នំពេញ។ ហើយចេញពីភ្នំពេញទៀតបានកងពលជូនទៅដល់សៀមរាប។ ហើយចេញពីសៀមរាបបានខ្ញុំទៅដល់ព្រះវិហារ។

**ស៖** នៅពេលដែលលោកនៅទីក្រុងភ្នំពេញ តើលោកមានការប្រជុំដើម្បីពិភាក្សាអំពីអ្វីដែលលោកត្រូវធ្វើនៅក្នុងតំបន់ព្រះវិហារដែរឬទេ?

**ឆ៖** បាទ ខ្ញុំចេញពីកោះកុងមកភ្នំពេញ មកពីរនាក់ជាមួយនឹងលេខាកងពល ដូចតា សឿង។ មកដល់ភ្នំពេញ ជួបលោក ប៉ុល ពត ឲ្យមកជួបគាត់នៅភ្នំពេញ នៅវត្តឧណ្ណាលោម។

**ស៖** តើលោក -- មានតែលោក និងតាសឿង ទេ ដែលជួបជាមួយ ប៉ុល ពត ឬមួយក៏មានជាមួយមនុស្សដទៃទៀត? តើមានជួបជាមួយមនុស្សដទៃទៀតទេ?

**ឆ៖** បាទ មានជួបជាមួយនឹងកងពលខ្លះ ក៏ប៉ុន្តែខ្ញុំអត់ស្គាល់ថា កងពលណាខ្លះទេ ប្រហែលជា ១២នាក់។ មិនស្គាល់គ្នាទេ។

[១៤:០៥:៣៦]

**ស៖** នៅក្នុងពេលដែលលោកស្នាក់នៅទីក្រុងភ្នំពេញនុ៎ង តើមានពេលណាមួយដែលលោកបានជួប ឬមួយក៏បាននិយាយជាមួយនឹងលោក នួន ជា ឬក៏ ខៀវ សំផន នោះទេ?

**ឆ៖** បាទ ខ្ញុំអត់បានជួបទេ លោក ខៀវ សំផន លោក នួន ជា ជួបជាមួយលោក ប៉ុល ពត។

**ស៖** តើនៅពេលដែលលោកជួបជាមួយ ប៉ុល ពត ហ្នឹង តើពិភាក្សាអំពីអ្វីដែរ?

**ឆ៖** បាទ ជួបជាមួយ ប៉ុល ពត ហ្នឹង គាត់បានបញ្ជាក់ពីរឿងសភាពការណ៍តាមព្រំដែនខាងកើតៗ ពីព្រៃវែង ស្វាយរៀង កំពង់ចាម រតនគិរី មណ្ឌលគិរី។ គាត់និយាយពីរឿងសភាពការណ៍ខ្លាំងយួនវ៉ៃតាមព្រំដែន។

**ស៖** តើ ប៉ុល ពត គឺជាអ្នកកោះហៅលោក ហើយនិងតាសឿង ទៅប្រជុំ ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** បាទ គាត់ហៅតាមរយៈតាសឿង។ តាសឿង ហៅខ្ញុំមកជួបជាមួយ ប៉ុល ពត។

**ស៖** តើលោកមានទទួលការណែនាំណាមួយ នៅក្នុងការប្រជុំហ្នឹង គឺការណែនាំពាក់ព័ន្ធទៅនឹងការផ្ទេរលោកទៅព្រះវិហារដែរឬទេ?

**ឆ៖** បាទ មុននឹងខ្ញុំទៅព្រះវិហារ គាត់បញ្ជាក់ពី ទី១ ពីសភាពការណ៍ព្រំដែនខាងកើត។ ទី២ គាត់បញ្ជាក់ពីសភាពការណ៍ប្រជាជននៅខេត្តព្រះវិហារ ដែលមានការគេចាប់ចង ហើយនិងអត់បាយ។ ទី៣ ប្រជាជននៅសៀមរាប ក៏មានការចាប់ដាក់គុកដែរ។

[១៤:០៨:៤៣]

**ស៖** តើគេដាក់ភារកិច្ចអ្វីឲ្យលោកធ្វើ នៅពេលដែលលោកទៅខេត្តព្រះវិហារនោះ -- ទៅព្រះវិហារនោះ?

**ឆ៖** បាទ ទី១ គាត់ឲ្យបងសឿង នៅសៀមរាប ដើម្បីរៀបចំស្រាវជ្រាវមើលដែលគេចាប់ប្រជាជនដាក់គុកនៅកន្លែងនោះ។ ហើយទី២ ខ្ញុំគាត់ឲ្យទៅព្រះវិហារ ទៅស៊ើបមើលតើគេចាប់ប្រជាជនមែន ឬក៏អត់ ហើយនិងបង្អត់បាយប្រជាជនមែន ឬក៏អត់ ហើយនិងរបស់របរដែលត្រូវដឹកជញ្ជូនយកឲ្យប្រជាជនកន្លែងនោះ តើបានដល់ដៃប្រជាជនដែរឬក៏អត់។

**ស៖** មុននឹងយើងបន្តទៅប្រធានបទថ្មី ខ្ញុំចង់បញ្ជាក់ទៅលើចំណុចមួយ។ នៅក្នុងចម្លើយ E3/424 របស់លោក នៅចម្លើយទី១១ លោកបាននិយាយថា "ក្នុងពេលប្រជុំនៅសៀមរាប គឺមាន ប៉ុល ពត, តាម៉ុក, តាសែ និង តាសឿង ប៉ុន្តែខ្ញុំមិនបានចូលរួមប្រជុំទេ"។ តើការប្រជុំដែលធ្វើនៅសៀមរាបនោះ ជាប្រជុំមួយផ្សេងមួយទៀត ឬមួយក៏យ៉ាងម៉េចដែរ? គឺការប្រជុំដែលចូលរួមដោយ ប៉ុល ពត, តាម៉ុក, តាសែ និង តាសឿង នោះ?

**ឆ៖** បាទ ការប្រជុំនៅសៀមរាបនោះ ខ្ញុំអត់បានចូលរួមប្រជុំទេ ពីព្រោះកិច្ចការរបស់ខ្ញុំតូចជាងយើងមិនបានចូលរួមប្រជុំទេ គាត់ប្រជុំតែគណៈតំបន់នៅកន្លែងនោះ ហើយនិងជាមួយអ្នកដឹកនាំខាងលើរបស់គាត់តែប៉ុណ្ណោះ។

[១៤:១១:១៥]

**ស៖** ចុះ តាសែ គឺជាមនុស្សមួយដែលត្រូវ ដែលជាប់ពាក់ព័ន្ធជាមួយនឹងតំបន់សៀមរាបដែរឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** បាទ ខ្ញុំមិនទាន់ស្គាល់ អត់ស្គាល់គាត់ច្បាស់ទេ ឮតែឈ្មោះ។

**ស៖** នៅពេលដែលលោករៀបរាប់ អំពីសកម្មភាពរបស់លោកនៅឯសៀមរាប ឬក៏ថានៅ

ព្រះវិហារនោះ លោកបាននិយាយដូចតទៅនេះ នៅក្នុងឯកសារ E3/424 គឺឯកសារដែលយើងមើលពីមុននេះ ដែលលោកបានឆ្លើយនៅសំណួរចម្លើយលេខ១៣ លោកបាននិយាយថា "ខ្ញុំរាយការណ៍ទៅ ខៀវ សំផន តាមរយៈតេឡេក្រាម។ ក្នុងនោះ ខ្ញុំសរសេររបាយការណ៍នៅលើក្រដាស ដែលមានដាក់ឈ្មោះរបស់ខ្ញុំ និងតំបន់១០៣ ផ្ញើជូនទៅ ខៀវ សំផន"។ បន្ទាប់មកលោកបាននិយាយថា "នៅពេលសភាពការណ៍មមាញឹក ខ្ញុំរាយការណ៍១សប្ដាហ៍ម្ដង ពេលខ្លះ ១ខែម្ដង ក៏មាន"។ ហើយដើម្បីបញ្ជាក់ឲ្យច្បាស់មុននឹងខ្ញុំសួរសំណួរលោក គឺថានៅក្នុងចម្លើយដដែល គឺសំណួរចម្លើយលេខ១៨ គេសួរថា "មូលហេតុអីបានជាលោកត្រូវរាយការណ៍ទៅ ខៀវ សំផន?" លោកឆ្លើយថា "ពីព្រោះមានសារទូរលេខពី ខៀវ សំផន ផ្ញើមកឲ្យខ្ញុំថា ពេលមានស្ថានភាពការណ៍ -- នៅពេលមានស្ថានការណ៍អ្វីត្រូវរាយការណ៍ជូនគាត់"។ តើខ្ញុំសង្ខេបបែបនេះ គឺជាការសង្ខេបត្រឹមត្រូវចំពោះចម្លើយរបស់លោក ដែលបានផ្ដល់ជូនសហចៅក្រមស៊ើបអង្កេត ដែលលោកបានប្រាប់ថា "ពីព្រោះមានសារទូរលេខពី ខៀវ សំផន ផ្ញើមកជូនលោកនោះ"។ តើត្រឹមត្រូវដែរឬទេ?

[១៤:១៣:៣៩]

**ឆៈ** បាទ ត្រង់សារទូរលេខ គឺគាត់បានបញ្ជាក់មកខ្ញុំមែន។ ហើយខ្ញុំក៏បានរាយពីសភាពការណ៍នៅសៀមរាបពីមនុស្សដែលត្រូវគេចាប់ដាក់គុក ហើយព្រមទាំងខ្ញុំ ហើយនិង តាសឿង បានទៅដោះបងថ្លៃគាត់ពីគុកចេញមកក្រៅ ឲ្យនៅជាមួយនឹងកន្លែងកងពលផងដែរ។

**សៈ** សូមអរគុណ ដែលលោកបានផ្ដល់នូវចម្លើយយ៉ាងលម្អិត។ ឥឡូវនេះ ខ្ញុំសូមនិយាយបន្តទៅទៀត គឺថាសារទូរលេខទី១ ដែល ខៀវ សំផន ផ្ញើមកលោក ដែលថា ឲ្យលោករាយការណ៍ទៅគាត់ហ្នឹង។ តើគេផ្ញើមកលោកនៅពេលណាដែរ សារទូរលេខទី១ របស់ ខៀវ សំផន នោះ?

**ឆៈ** ខ្ញុំមិនបានចាំថ្ងៃទេ គាត់ផ្ញើតែម្ដង ក្នុងពេលដែលសភាពការណ៍ ប្រទេសវាមានការប្រែប្រួលខ្លាំង។ ឃើញសារទូរលេខគាត់ម្ដង ឲ្យបញ្ជាក់ពីរឿងបងប្អូន និងឪពុកក្មេករបស់គាត់ មើលទៅនៅត្រង់ណា អីត្រង់ណា។ គាត់ឲ្យសួររកមើលឲ្យគាត់ផង ប៉ុណ្ណឹង។

[១៤:១៥:១៧]

**សៈ** ដូច្នេះនៅពេលដែលលោកទទួលទូរលេខ ដែលស្នើសុំឲ្យលោករាយការណ៍អំពីទីតាំងរបស់សាច់ញាតិរបស់គាត់ ដូច្នេះលោកក៏ទៅធ្វើការស៊ើបអង្កេត ដើម្បីឲ្យរកឃើញថាតើមានអ្វីកើតឡើងចំពោះសាច់ញាតិគាត់។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំក៏បានទៅដល់ព្រះវិហារ ទៅមើលដល់ឪពុកក្មេក ម្ដាយក្មេកគាត់ ឃើញគាត់ចាស់ជរាហើយ ហើយក៏គាត់គ្មាននរណាថែមើលគាត់ផង ហើយម្យ៉ាងគាត់ចេះតែភ័យខ្លាច នៅទីនោះគេចេះចាប់ប្រជាជន។ ហើយក៏ខ្ញុំបាននាំគាត់មក យកនាំគាត់មកពីព្រះវិហារមកសៀមរាប ក៏ប៉ុន្តែមកដល់សៀមរាប គាត់នៅតែមិនអស់ចិត្ត ថាខ្លាចយកគាត់ទៅដាក់គុក ឬក៏យកគាត់ទៅសម្លាប់។ ហើយក្នុងពេលនោះខ្ញុំក៏ទុកឲ្យទៅ បងសឿង គាត់ទុកនៅសៀមរាបវិញ។ តែដំណើរការរបស់គាត់តទៅទៀត ខ្ញុំមិនបានដឹងថាគាត់ទៅកន្លែងណាវិញ កាលណោះខ្មាំង អំ វៀតណាមវ៉ៃកាន់តែខ្លាំងបន្តិចហើយ។

[១៤:១៦:៤១]

**ស៖** នៅក្នុងទូរលេខដែលលោកទទួលបានពីលោក ខៀវ សំផន នោះ តើគាត់មាននិយាយអ្វីអំពី -- អំពីអ្វីដែលកើតឡើងចំពោះគ្រួសាររបស់គាត់? ថាតើគាត់មាននិយាយអំពីការដែលថា មានការចាប់ខ្លួន ឬក៏មានអ្វីដែរឬទេ ទាក់ទងនៅក្នុងទូរលេខរបស់គាត់នោះ?

**ឆ៖** គាត់បានប្រាប់និយាយតែប៉ុណ្ណឹង គាត់ថាឲ្យមើលៗ ឲ្យគាត់ផង ហើយបើៗ គាត់លំបាកទេ ឲ្យដឹកយកឲ្យគាត់នៅភ្នំពេញ។ ក៏ប៉ុន្តែគាត់មិនបានយកមកដល់ភ្នំពេញទេដឹង បើសភាពការណ៍វាមិនស្រួលអីចឹង។ ខ្ញុំក៏ដាច់គ្នាត្រឹមហ្នឹងទៅ។

**ស៖** ឥឡូវនេះខ្ញុំចង់ដោះស្រាយទៅលើបញ្ហាតូចមួយ លោកបាននិយាយពីមុននេះថា បងថ្លៃស្រីនិងម្ដាយក្មេករបស់ ខៀវ សំផន នៅព្រះវិហារ។ ហើយខ្ញុំចង់អាននៅផ្នែកមួយ គឺឯក -- គឺសំណួរលេខ ១៤ នៃឯកសារ E3/424 លោកបាននិយាយនៅខាងដើមថា "ខ្ញុំរាយការណ៍អំពីបងប្អូនថ្លៃ -- បងថ្លៃរបស់គាត់ឈ្មោះ យៀត ដែលរស់នៅក្នុងម៉ាឡៃ ដែលៗ -- មុនដំបូងខ្ញុំរាយការណ៍អំពីបងថ្លៃស្រីរបស់គាត់ ឈ្មោះយៀត សព្វថ្ងៃរស់នៅម៉ាឡៃ ដែលត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខខេត្តសៀមរាប។ បន្ទាប់ខ្ញុំរាយការណ៍អំពីប្រជាជននៅខេត្តព្រះវិហារមានការអត់បាយច្រើន និងមានការចាប់ប្រជាជនយកទៅដាក់មន្ទីរសន្តិសុខ"។ ដូច្នេះដំបូងខ្ញុំចង់សួរលោកថា តើបងថ្លៃស្រីរបស់ ខៀវ សំផន ហ្នឹង គេឃុំខ្លួននៅឯណាដែរ? នៅខេត្តសៀមរាប ឬមួយក៏នៅព្រះវិហារ?

[១៤:១៩:១២]

**ឆ៖** បាទ នៅសៀមរាប។

**ស៖** តើទីតាំងដែលលោករៀបរាប់ថា មន្ទីរសន្តិសុខហ្នឹង តើមន្ទីរសន្តិសុខហ្នឹងយ៉ាងម៉េចដែរ? តើវាមានមន្ទីរសន្តិសុខរបស់តំបន់សៀមរាប ឬមួយក៏ជាមន្ទីរសន្តិសុខបែបណាដែរ?

**ឆ៖** បាទ មន្ទីរសន្តិសុខគេ កន្លែងគុកចាស់។ គុកពីសង្គម។

**ស៖** តើគុកហ្នឹងវាជាគុកធំ ឬក៏គុកតូច ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** គុកហ្នឹងធំដែរ គុកស៊ីម៉ងត៍ចាស់ពីដើម។

**ស៖** តើមានអ្នកទោសច្រើនដែរឬទេនៅក្នុងគុកនោះ នៅក្នុងមន្ទីរសន្តិសុខនោះ?

**ឆ៖** បាទ ក្នុងហ្នឹង បើខ្ញុំប្រហែលទៅ ប្រហែលជាជិត៧០០នាក់។

**ស៖** នៅពេលដែលលោកទៅទីនោះ តើលោកមានបានជួបអ្នកដែលទទួលខុសត្រូវលើគុកនោះដែរឬទេ? តើលោកធ្វើយ៉ាងដូចម្តេចបានរកឃើញបងថ្លៃស្រីរបស់លោក ខៀវ សំផន?

**ឆ៖** បាទ តាសឿង គាត់ស្រាវជ្រាវរកតាមរយៈ គាត់ស្គាល់ៗទៅ ហើយរកឃើញហើយ ខ្ញុំធ្វើដំណើរទៅព្រះវិហារ។

[១៤:២១:៣១]

**ស៖** តើលោកទៅមន្ទីរសន្តិសុខនៅសៀមរាបហ្នឹងដោយផ្ទាល់? គឺថាលោកទៅទីនោះដោយផ្ទាល់ដើម្បីជួយដល់ការដោះលែងបងថ្លៃស្រីរបស់លោក ខៀវ សំផន ឬមួយក៏អ្នកណា?

**ឆ៖** ខ្ញុំទៅជាមួយ តាសឿង។

**ស៖** នៅពេលដែលលោកទៅទីនោះ តើលោកធ្វើបែបណាដើម្បីអាចឲ្យដោះលែង អាចឲ្យគេដោះលែងបងថ្លៃស្រីរបស់លោក ខៀវ សំផន នេះបាន?

**ឆ៖** បាទ ក្នុងការដោះលែងបាន ខ្ញុំអត់បានទៅពិភាក្សា ឬក៏ទៅទំនាក់ទំនងនឹងអ្នកដឹកនាំកន្លែងនោះទេ។ បងសឿង គាត់ទៅទាក់ទង ទំនាក់ទំនងមុន ហើយបានខ្ញុំចូលទៅជាមួយគាត់ពីក្រោយ។

[១៤:២២:៤៥]

**ស៖** លោកបានបញ្ជាក់ពីដើមអំពីម្តាយក្មេករបស់លោក ខៀវ សំផន តើម្តាយក្មេករបស់ ខៀវ សំផន ហ្នឹងឃុំនៅមន្ទីរសន្តិសុខតែមួយ ដែលជាមួយនឹងបងថ្លៃស្រីរបស់គាត់ដែរ ឬមួយក៏យ៉ាងណាដែរ?

**ឆ៖** បាទ ម្តាយក្មេករបស់លោក ខៀវ សំផន និងឪពុកក្មេក គេអត់ចាប់ទេ។ គាត់នៅផ្ទះ ពីរនាក់ប្តីប្រពន្ធគាត់នៅឯព្រះវិហារនោះទេ មិនបានមកដល់សៀមរាបទេ។

**ស៖** ក្រៅពីបងថ្លៃស្រី ម្តាយក្មេក និងឪពុកក្មេក តើលោកមានបានជួបជាមួយនឹងសាច់ញាតិលោក ខៀវ សំផន ដទៃទៀតដែរឬទេ?

**ឆ៖** បាទ អត់បានស្គាល់អស់ទេ។ ខ្ញុំស្គាល់តែឪពុកម្តាយ, ឡុត ហើយនិង យៀត ដោយសារ

ថាចូលទៅពីនេះទៅឃើញគាត់ ក្រៅពីហ្នឹងមិនបានសួរសាកអីទៀតទេ។

[១៤:២៤:១១]

**ស៖** សូមអរគុណលោក។ តើលោកមានបានផ្ញើទូរលេខ ឬក៏រាយការណ៍អំពីអ្វីដែលលោកបានធ្វើហ្នឹងមកជូនលោក ខៀវ សំផន ដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានរាយការណ៍តែម្ដងហ្នឹង ទាំងឪពុកក្មេក ម្ដាយក្មេក ហើយនិងប្រជាជនដែលអត់បាយ ហើយនិងការរស់នៅស៊ីចុករបស់គាត់ដែលដឹកអីហ្នឹង បានតែម្ដងហ្នឹង ក៏វៀតណាមវ៉ៃចូលស្រុក ក៏រត់តាមផ្លូវមក។

[១៤:២៥:១៦]

**ស៖** នៅពេលដែលយើងនិយាយអំពីការរាយការណ៍ នៅក្នុងចម្លើយទី១ របស់លោក គឺឯកសារ E3/424 ប្រសិនបើយើងមើលទៅឃ្លាខាងដើម គឺសំណួរចម្លើយទី១៣ លោកបានរៀបរាប់ថា "លោករាយការណ៍ទៅ ខៀវ សំផន តាមរយៈតេឡេក្រាម ដែលមានដាក់ឈ្មោះរបស់លោកនៅតំបន់១០៣ ដើម្បីផ្ញើជូនទៅ ខៀវ សំផន។ រួចបន្ទាប់មកលោកបញ្ជាឲ្យមនុស្សម្នាក់វាយឯកសារ ហើយនិងបញ្ជូនទូរលេខនោះ"។ ហើយលោកបញ្ជាក់ថា "ពេលសភាពការណ៍មមាញឹក ខ្ញុំរាយការណ៍មួយសប្ដាហ៍ម្ដង ពេលខ្លះមួយខែម្ដងក៏មាន"។ តើខ្ញុំនិយាយបែបនេះត្រឹមត្រូវដែរឬទេ ដែលថាលោករៀបរាប់ថា "ពេលខ្លះលោករាយការណ៍មួយសប្ដាហ៍ម្ដង ពេលខ្លះមួយខែម្ដង"។ តើវាជាការត្រឹមត្រូវដែរឬទេ?

[១៤:២៦:១៥]

**ឆ៖** បាទ ត្រឹមត្រូវបាទ។

**ស៖** តើលោកយល់ថាលោក ខៀវ សំផន មានតួនាទីអ្វីដែរនៅពេលនោះ?

**ឆ៖** បាទ តាមខ្ញុំដឹងតែតំបន់១០៣ ហ្នឹង គឺគាត់បានទទួលក្នុងតំបន់១០៣ហ្នឹង តាមឮប្រជាជនគាត់ប្រាប់ខ្ញុំថាតំបន់ស្វយ័ត ដោយលោក ខៀវ សំផន កាលហ្នឹងគេហៅថា "អ៊ំ ខៀវ សំផន" ហើយនិង "អ៊ំ នួន ជា"។

**ស៖** តើអ្នកណាជាអ្នកប្រាប់លោកថា តំបន់១០៣ ស្ថិតក្រោមការគ្រប់គ្រងរបស់លោក ខៀវ សំផន នោះ?

**ឆ៖** បាទ គេប្រាប់ ប្រជាជនគាត់ដឹង គាត់ប្រាប់ខ្ញុំ។

**ស៖** តើលោកអាចបញ្ជាក់ឲ្យបានលម្អិតដែរឬទេ ដែលលោកថាប្រជាជនហ្នឹង តើប្រជាជន

ហ្នឹងជានរណាដែរ ជាបក្ខជន ឬមួយក៏ជាមនុស្សបែបណាដែរ? តើអ្នកប្រាប់លោកនោះគាត់មានតួនាទីអ្វីដែរ?

**ឆ៖** បាទ ប្រជាជនធម្មតា ហើយអ្នកខ្លះនៅឈឺក្នុងមន្ទីរពេទ្យ ហើយចួនកាលប្រធានមន្ទីរពេទ្យគាត់ប្រាប់ដែរ។ ប៉ុន្តែខ្ញុំមិនស្គាល់ឈ្មោះទេ ព្រោះខ្ញុំទើបតែទៅថ្មី។

**សៈ** ដូច្នេះ នៅពេលដែលលោកទទួលបានទូរលេខពី ខៀវ សំផន ណែនាំឱ្យលោកធ្វើការរាយការណ៍ ដោយសារតែទូរលេខហ្នឹងហើយទើបជាហេតុផលមួយ ដែលលោកធ្វើការរាយការណ៍។ តើបែបនេះដែរឬទេ?

[១៤:២៩:០០]

**ឆ៖** ស្តាប់អត់បាន។

**សៈ** សូមអរគុណលោក។ លោកបានបញ្ជាក់ពីមុននេះថា គេប្រាប់លោកថា "តំបន់១០៣ ស្ថិតក្រោមការគ្រប់គ្រងរបស់លោក ខៀវ សំផន"។ ដោយសារហេតុផលនេះហើយឬទើបលោកធ្វើការគោរពទៅតាមការណែនាំរបស់គាត់ដោយរាយការណ៍ទៅគាត់ ហើយស្វែងរកសាច់ញាតិឱ្យគាត់ តើដោយសារហេតុផលហ្នឹងមែនទេ?

**ឆ៖** បាទ មែន។

[១៤:៣០:០០]

**សៈ** នៅពេលដែលលោកទៅដោះលែងបងថ្លៃស្រីរបស់លោក ខៀវ សំផន ចេញពីគុកនៅសៀមរាបនោះ តើមានអ្វីកើតឡើងចំពោះអ្នកទោស ប្រហែលជា៧០០នាក់ទៀត ដែលឃុំខ្លួននៅទីនោះ តើមានអ្វីកើតឡើងចំពោះអ្នកដទៃទៀត?

**ឆ៖** បាទ គាត់តាមមើល ខ្ញុំគ្រាន់តែដោះលែងហើយ ខ្ញុំមិនបាននៅហ្នឹងទៀតទេ ក្នុងមួយថ្ងៃដោះរួចមកគឺ ខ្ញុំទៅព្រះវិហារតែម្តង។ ឯការកើតឡើងយ៉ាងណានោះនៅលើ តាសឿង នៅខាងក្រោយនៅកន្លែងនោះ។

**សៈ** នៅពេលដែលលោកទៅដល់ទីនោះ គឺមាន -- ប្រសិនបើខ្ញុំយល់មិនខុសទេ គឺលោកដោះលែងអ្នកទោសតែមួយរូបទេ គឺបងថ្លៃស្រីរបស់លោក ខៀវ សំផន។ ចំណែកអ្នកទោសដទៃទៀត អ្នកទោសប្រហែល៧០០នាក់ទៀត គឺនៅទីនោះដដែល តើខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** តើលោកចាំដែរឬទេ -- បាទ ខ្ញុំសូមសួរលោកម្តងទៀត ថាតើតាស្លួង (ស៊ីក) នៅក្នុងការស៊ើបអង្កេតរបស់គាត់ហ្នឹង -- តាសឿង នៅពេលស៊ើបអង្កេតរបស់គាត់ហ្នឹង ថាតើគាត់រកឃើញថាតើអ្នកណាជាអ្នកបង្គាប់ ឬក៏អ្នកណាជាអ្នកបញ្ជាឲ្យឃុំខ្លួនបងថ្លៃ ខៀវ សំផន នៅក្នុងគុកនោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ ពីព្រោះ ពីព្រះវិហារ អំ ពីសៀមរាប ទៅព្រះវិហារឆ្ងាយពីគ្នា ខ្ញុំមិនបានដឹងថា ខាងសៀមរាប ខាងក្រោយ ក្រោយខ្ញុំទៅព្រះវិហារ មិនដឹងជាយ៉ាងម៉េច ព្រោះកាលហ្នឹងវានៅឆ្ងាយពីគ្នាណាស់ ហើយមធ្យោបាយដើរហើរក៏លំបាកដែរ។

[១៤:៣២:៣៩]

**ស៖** សូមអរគុណ។ នៅក្នុងឯកសារ E3/424 របស់លោក នៅសំណួរចម្លើយទី១១ លោកបានពន្យល់អំពី តាសឿង បានប្រាប់គាត់ថា គាត់ត្រូវបានគេតែងតាំងជាប្រធានភូមិភាគឧត្តរថ្មី។ តើលោកដឹងដែរឬទេ អ្នកណាជាអ្នកតែងតាំងគាត់ ឲ្យទៅធ្វើជាប្រធានភូមិភាគឧត្តរថ្មីនោះ?

**ឆ៖** បាទ តាមខ្ញុំដឹង មានតាម៉ុក ហើយក្រៅពីហ្នឹងទៀត ខ្ញុំអត់បានដឹងទេ ដឹងតែតាម៉ុក ទៅដល់កន្លែងហ្នឹងតែងតាំង តាសឿង។

**ស៖** តើលោកដឹងដែរឬទេ ថាតើអ្នកណាគឺជា ប្រធានភូមិភាគឧត្តរថ្មីមុនពេលដែលតាសឿងគាត់ទៅកាន់ហ្នឹង តើអ្នកណាជាប្រធានចាស់របស់ភូមិភាគឧត្តរថ្មីនោះ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ។

[១៤:៣៤:២៨]

**ស៖** លោកបានបញ្ជាក់ពីមុន គឺនៅត្រង់ឃ្លាមួយដែលលោកនិយាយអំពីពេលប្រជុំនៅសៀម-រាប គឺមានតាប៉ុល ពត តាម៉ុក តាសែ និងតាសឿង បើតាមដែលលោកដឹង ថាតើតាសែ មានការទទួលខុសត្រូវអ្វីនៅតំបន់សៀមរាបទេ មុនពេលតាសឿងមក?

**ឆ៖** បាទ ខ្ញុំដឹងតែៗ តាសឿង, តាម៉ុក ហ្នឹងឃើញ ហើយប៉ុន្តែ តាប៉ុល ពត, តាសែ ខ្ញុំអត់បានឃើញទេ។ គាត់ប្រជុំគ្នាគាត់ដែរក៏មិនដឹង ក៏ប៉ុន្តែនៅប្រជុំអ៊ីចឹង គេមិនសួរឲ្យខ្ញុំដឹងទេ ព្រោះខ្ញុំថ្នាក់ក្រោម។

**ស៖** សូមអរគុណ។ ដោយសារតែយើងមើលទៅម៉ោងទៅ ឃើញមាននៅសល់ ម៉ោងបន្តិចបន្តួច។ ដូច្នេះ ខ្ញុំចង់បង្ហាញឯកសារមួយចំពោះលោក។

[១៤:៣៥:៤២]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន នេះគឺជាចម្លើយ -- កំណត់ហេតុស្តាប់ចម្លើយសាក្សី គឺឯកសារ E3/420 ហើយ វាចម្លើយសារភាពរបស់សាក្សី TCW-548 គឺបុគ្គលរូបនេះ បានពិភាក្សាអំពីសកម្មភាព អំពីការងាររបស់លោក វឿន។ ប្រសិនបើលោកប្រធានអនុញ្ញាត ខ្ញុំសូមបង្ហាញទៅលោក វឿន ដើម្បីឲ្យគាត់ពិនិត្យមើល ហើយនិងដើម្បីឲ្យគាត់បញ្ជាក់ថាគាត់ស្គាល់ ឬក៏អត់។ បន្ទាប់មក ខ្ញុំនឹងសួរសំណួរពីរបីទាក់ទងទៅនឹងចម្លើយរបស់សាក្សីរូបនេះ។ សូមលោកប្រធានមេត្តាអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

ហើយប៉ុន្តែសូមលាក់អត្តសញ្ញាណ លាក់ឈ្មោះសាក្សីរូបនោះ ហើយមន្ត្រីរដ្ឋបាលតុលាការយកទៅជូនសាក្សីពិនិត្យ ហើយសូមមេធាវីប្រឹក្សាសាក្សីសម្រួលនូវការចម្លើយរបស់គាត់ផង ចៀសវាងគាត់បញ្ចេញនូវឈ្មោះអ្នកដែលពាក់ព័ន្ធនៅក្នុងកំណត់ហេតុនោះ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៤:៣៧:១៦]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោក វឿន លោកបានឮការណែនាំរបស់លោកប្រធានរួចទៅហើយ ដូច្នេះ គឺយើងមិនបង្ហាញឈ្មោះរបស់សាក្សីនេះទេ។ ដូច្នេះ សូមឲ្យលោកពិនិត្យមើលឈ្មោះហ្នឹង គឺភាសាខ្មែរមានលេខ 0042773 (ស៊ីក) គឺទំព័រ -- គឺនៅទំព័រ តើលោកអាចមើលឃើញឈ្មោះសាក្សីនោះដែរឬទេ គឺមើលទៅលើទំព័រដែលមានបង្ហាញឈ្មោះសាក្សីនោះ តើលោកឃើញឈ្មោះគាត់ទេ?

**ឆ៖** បាទ ខ្ញុំស្គាល់ ក៏ប៉ុន្តែឈ្មោះគាត់ ខ្ញុំមិនបានសាកសួរគាត់ទេ។

**ស៖** សូមអរគុណលោក។ ដូច្នេះ ដើម្បីឲ្យបញ្ជាក់កំណត់ត្រាច្បាស់លាស់ ខ្ញុំសូមបញ្ជាក់ថា នៅសំណួរចម្លើយទី១៣ បុគ្គលរូបនេះ បាននិយាយថា "នៅពេលដែលលោកមកតំបន់១០៣ គឺមិនមានការចាប់ខ្លួនបន្តទៀតទេ"។ ហើយគាត់បានបញ្ជាក់ទៀតថា "ចំពោះលោក គឺលោកអញ្ជើញទៅតំបន់នោះដើម្បីសម្របសម្រួល ហើយនិងដើម្បីលើកទឹកចិត្តមនុស្សនៅតំបន់នោះ ហើយលោកក៏បានធ្វើការដោះ

លេងអ្នកទោសដែលឃុំខ្លួននៅទីនោះផងដែរ”។ នេះគឺដែលជាអ្វីគាត់បានរៀបរាប់អំពីការងាររបស់លោកនៅព្រះវិហារ។

[១៤:៣៩:៣២]

ហើយក៏នៅក្នុងចម្លើយរបស់គាត់ផងដែរ ខ្ញុំនឹងពិភាក្សាជាមួយលោក ដោយសារតែយើងមានពេលបន្តិចបន្តួចនូវចម្លើយទី៤ គឺគេសួរគាត់ថា “តើលោកស្គាល់បុគ្គលិកតំបន់១០៣ ដែលគេចាប់ខ្លួនទៅមន្ទីរសន្តិសុខសៀមរាប ហើយដែលនៅរស់រានមានជីវិតដែរឬទេ?” ហើយសាក្សីរូបនេះ បានបញ្ជាក់ថា “អ្នកដែលនៅរស់ រួមមាន” គឺយើងមើលចុះក្រោមពីរបីបន្ទាត់គឺមាន បងឈន (ប្រុស) នៅពាណិជ្ជកម្មតំបន់១០៣ ដែលជាបងថ្លៃរបស់តា ខៀវ សំផន ហើយនិង បងយៀត (ស្រី) ប្រធាននារីតំបន់ ជាបងថ្លៃតា ខៀវ សំផន។ សាក្សីរូបនេះគាត់ហាក់ដូចជាចាំមនុស្សម្នាក់ទៀតឈ្មោះ បងឈន តើលោកចាំដែរឬទេ ថា បងឈន ហ្នឹង ត្រូវបានគេឃុំខ្លួននៅមន្ទីរសន្តិសុខសៀមរាបដែរ?

**ឆ៖** ដឹង។ ក៏ប៉ុន្តែជា ត្រូវជាសាច់ថ្លៃរបស់លោក ខៀវ សំផន ខ្ញុំមិនបានដឹងច្បាស់ទេ ប៉ុន្តែគ្រាន់តែដឹង តាឈន ជាប់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណសាក្សី អរគុណតំណាងសហព្រះរាជអាជ្ញា។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីកិច្ចដំណើរការសវនាការ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់សម្រាកនៅបន្ទប់សម្រាកសម្រាប់សាក្សី/អ្នកជំនាញ ដល់សាក្សី និងមេធាវីប្រឹក្សារបស់គាត់នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្ដល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០២ នាទី)*

[១៥:០២:៣២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយអង្គជំនុំជម្រះសូមសួរទៅតំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តី អ៎! និងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងម៉េចទៅ លើពេលវេលាដែរនៅសេសសល់នេះ?

**លោក អាប់ឌុលឡាក់ ថារីក៖**

បាទ លោកប្រធាន យើងបានពិគ្រោះគ្នារួចហើយ គឺថាជំហររបស់យើងគឺថាមេធាវីតំណាងដើម -- នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនោះគឺថា គាត់ផ្អែកលើអ្វីដែលខ្ញុំបានសួរគាត់ ប្រហែលជាត្រូវការពេល១ម៉ោង។

ហើយខ្ញុំនឹងត្រូវការពេលប្រហែលជាកន្លះម៉ោង ឬក៏១ម៉ោងទៀត។ ហើយអាចនឹងធ្វើឲ្យខ្ញុំសួរហួសពេលសម្រាប់ថ្ងៃល្ងាចនេះ។ ប៉ុន្តែតុលាការមានសិទ្ធិក្នុងការសម្រេចបញ្ហានេះ បើសិនជាតុលាការពិចារណា និងអនុញ្ញាត យើងនឹងសុំបន្តកន្លះមួយ ឬ១ម៉ោង។ រីឯមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចបន្តបន្ទាប់ពីខ្ញុំចប់ទៅនៅថ្ងៃចន្ទ អាទិត្យក្រោយបាទ។

[១៥:០៤:០៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ យើងបានពិភាក្សាគ្នារួចហើយ ហើយមេធាវីនាំមុខអាចត្រូវការប្រហែលជា១ម៉ោង ទៅ១ម៉ោង១៥នាទី។ ហើយពេលសវនាការដែលចាប់ផ្តើមសួរដោយខាងសហព្រះរាជអាជ្ញាឃើញថាមានការយឺត។ គាត់ចាប់ផ្តើមនៅម៉ោងពីរប្រាំបីនាទី នៅថ្ងៃម្សិលមិញ ហើយថ្ងៃនេះមានការកាត់ច្រើន។ ដូច្នេះខ្ញុំគិតថាជាការសមស្របដែលគាំទ្រចំពោះការលើកឡើងរបស់ខាងព្រះរាជអាជ្ញា។ សូមអរគុណ។

[១៥:០៥:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០៦:០៤]

**ប្រធានអង្គជំនុំ៖**

បាទ ដោយអង្គជំនុំជម្រះពិចារណាលើសំណើសុំនេះ ហើយនិងភាពពាក់ព័ន្ធនៃសំណួរដែលបានសួរ អង្គជំនុំជម្រះអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញាបន្តការតាំងសំណួរសាក្សីរូបនេះជាបន្តទៀត។ ហើយអង្គជំនុំជម្រះសូមរក្សាសិទ្ធិនៅក្នុងការកាត់ ប្រសិនបើការសំណួរឯណាមិនពាក់ព័ន្ធ ឬក៏មិនមានប្រយោជន៍ក្នុងការរួមចំណែកស្វែងរកការពិត។

**លោក អាប់ឌុលឡាក់ ថារីក៖**

យើងខ្ញុំសូមអរគុណលោកប្រធាន ហើយយើងនឹងព្យាយាមសួរឲ្យបានមានប្រយោជន៍បំផុតតាមដែលយើងអាចធ្វើបាន ហើយសួរដោយសង្ខេបផងដែរ។

[១៥:០៧:០០]

**លោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

ខ្ញុំសូមលើកយោបល់ខ្លី គឺថាយើងព្រួយបារម្ភខ្លាំងណាស់ ហើយយើងមិនបានពិភាក្សាទេ តែហើយមិនមានការជំទាស់អ្វីទេ ចំពោះពេលវេលាដែលអង្គជំនុំជម្រះបានសម្រេចនេះនោះបាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាក្សី មាស វឿន ដូចដែលលោកប្រធានបានណែនាំ ហើយខ្ញុំនឹងសួរសំណួរមួយចំនួនទៀត ហើយសូមអរគុណដែលលោកបានប្រឹងប្រែងស្តាប់ ហើយនិងឆ្លើយសំណួររបស់ខ្ញុំ។ ពេលមុនដែលយើងសម្រាកនោះ យើងបានពិភាក្សាពីបុគ្គលពីររូប អំពីបងប្អូនពីររូបរបស់លោក ខៀវ សំផន ដែលៗសាក្សីម្នាក់ផ្សេងទៀតបានបញ្ជាក់ឈ្មោះដែលយើងបានពិភាក្សានោះ។

[១៥:០៨:២០]

ទី១ ខ្ញុំចង់សួរលោកទាក់ទងទៅនឹង បងយៀត ដែលជាបងថ្លៃស្រីរបស់លោក ខៀវ សំផន ហើយសាក្សីរូបនេះបាននិយាយថា គាត់ជាប្រធាននារីតំបន់ នៅក្នុងចម្លើយទី៤ ដែលលោកបានពិនិត្យពីមុននោះ។ តើលោកយល់ដូចគ្នាហ្នឹងទេ អំពីមុខតំណែងរបស់ បងយៀត ដែលថា គាត់ជាប្រធាននារី

តំបន់នោះ?

**លោក មាស វឿន៖**

**ឆ៖** បាទ ខ្ញុំបានដឹងថា គាត់ទទួលតំណែងអ្វីនោះទេ ពីព្រោះខ្ញុំដឹងថា ឲ្យតែរួចចេញមក ខ្ញុំមិនបានសួរសាកថា គាត់ធ្វើអី ឬទទួលខាងអី ខ្ញុំអត់បានសួរទេ។

**ស៖** ទាក់ទងទៅនឹងបុគ្គលម្នាក់ទៀត ឈ្មោះ បងឈន ចម្លើយរបស់សាក្សីនោះរៀបរាប់ថា "គាត់ធ្វើការនៅក្នុងពាណិជ្ជកម្មតំបន់១០៣ តើលោកនៅនឹកឃើញដែរឬទេជាមុខងារហ្នឹងឬដែលបងឈន ហ្នឹងជាអ្នកកាន់តំណែងហ្នឹង ជាបងប្រុស -- បងថ្លៃប្រុសរបស់លោក ខៀវ សំផន នោះ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងដែរ។

**ស៖** សំណួរមួយទៀតទាក់ទងទៅនឹងបុគ្គលនេះ ខ្ញុំមិនប្រាកដថាលោកបានឆ្លើយត្រូវនឹងសំណួរខ្ញុំទេខាងដើមនេះ។ តើលោកដឹងដែរឬទេថាតើ បងឈន ក៏ជា -- ត្រូវបានជាប់ -- គេចាប់ខ្លួន ហើយឃុំខ្លួននៅសៀមរាបនោះដែរៗឬទេ?

**ឆ៖** បាទ អត់បានដឹងទេ ដឹងតែ បងយៀត មួយទេ។

**ស៖** សូមអរគុណ។ ឥឡូវនេះត្រឡប់មកចម្លើយទី១ របស់លោកនៅក្នុងកំណត់ហេតុ E3/424 នៅសំណួរ និងចម្លើយលេខ១០។ បានរៀបរាប់ថា តំបន់ព្រះវិហារហ្នឹង ហើយលោកបានរៀបរាប់ដូចខាង -- ខ្ញុំអានសំណួរនិងចម្លើយ "មូលហេតុអ្វីបានជាលោកត្រូវផ្លាក់លើផ្លាស់ទៅឲ្យកាន់តំបន់ព្រះវិហារ?" សំណួរ អ៎! សំណួរ។ ចម្លើយ "ដោយសារតំបន់ព្រះវិហារជាតំបន់ស្វយ័ត ដែលគ្រប់គ្រងដោយមជ្ឈិមផ្ទាល់ មាន តា នួន ជា និងតា ខៀវ សំផន គាត់ធ្លាប់ចុះទៅផ្ទាល់នៅតំបន់នោះ"។ តើលោកដឹងរបៀបណាថា លោក នួន ជា បានទៅទស្សនកិច្ច ឬក៏ទៅតំបន់ព្រះវិហារនោះ?

[១៥:១១:៤៨]

**ឆ៖** បាទ ខ្ញុំដឹងតាមប្រជាជនគាត់ប្រាប់ និងតំណាងតំបន់មួយ ដែលឈ្មោះ ដូចខ្ញុំភ្លេចហើយ គាត់បានជាប់ឃុំឃាំងនៅព្រះវិហារដែរ តែគាត់ប្រាប់ខ្ញុំ។ ហើយខ្ញុំទៅក៏ឃើញរូបថតលោក ខៀវ សំផន រូបថតលោក នួន ជា គេទាញរគាត់រតាយចេញពីមន្ទីរកន្លែងរបស់គាត់ មិនជាគាត់បានទៅនៅ ឬមិនបានទៅនៅទេ ក៏ប៉ុន្តែឃើញគេទាញចេញទៅរគាត់រតាយនៅកន្លែងនោះ។

**ស៖** តើលោកអាចរៀបរាប់បានដែរឬទេ តើលោកបានឃើញរូបថតទាំងនេះ នៅកន្លែងណាបាទ?

**ឆ៖** បាទ នៅកន្លែងមន្ទីរ គេហៅថា "មន្ទីរទន្លាប់ៗ"។

**ស៖** តើគោលបំណង នៃមន្ទីរនោះគេ -- មន្ទីរនោះគេធ្វើការងារអ្វី?

**ឆ៖** បាទ មន្ទីរនោះគេដាក់កន្លែងៗសារទូរលេខ អាគេរវៃ ហើយកន្លែងអ្នកការកាន់កាប់គ្រប់គ្រងកន្លែងនោះ ប៉ុន្តែដល់មានពេលកើតហេតុហ្នឹងទៅ ខ្ញុំទៅទាន់តែ ឃើញតែក្មេងៗពីរនាក់ ដែលឈ្មោះ អើយ ហើយនិង -- ឈ្មោះ អើយ មួយ ហើយមួយទៀត ខ្ញុំមិនបានចាំឈ្មោះ។

[១៥:១៣:៥៣]

**ស៖** តើនេះជាមនុស្សដែលលោកបានរៀបរាប់ក្នុងចម្លើយរបស់លោកថា ជាអ្នកវាយធ្វើសារទូរលេខដើម្បីបញ្ជូនទៅលោក ខៀវ សំផន ហ្នឹងឬ? មានមនុស្សពីរនាក់នោះ?

**ឆ៖** បាទ លោកពីរនាក់ នឹកឃើញហើយ ម្នាក់ អើយៗ ហើយនិង អុល ក៏ប៉ុន្តែ អើយ គាត់បានចេញទៅបរទេសហើយ ប៉ុន្តែ អុល មិនដឹងនៅកន្លែងណា ខ្ញុំមិនបានដឹងដែរ តែគាត់នៅរស់ទេសព្វថ្ងៃ។

**ស៖** តើអ្នកទាំងពីរនាក់នេះ ប្រាប់លោកអំពីៗការទៅទស្សនកិច្ចរបស់ នួន ជា និង ខៀវ សំផន ទៅព្រះវិហារដែរឬទេ?

**ឆ៖** បាទ គាត់អត់បាននិយាយប្រាប់ទេ ប៉ុន្តែដឹងថា កន្លែងហ្នឹងជាកន្លែងមន្ទីររបស់លោក ខៀវ សំផន ហើយនិងលោក នួន ជា ក៏ប៉ុន្តែការចេញចូល គាត់ចេញចូលនោះ គាត់អត់បានប្រាប់ខ្ញុំទេ។

**ស៖** សូមអរគុណ។ ខ្ញុំចង់សួរលោកបន្ថែមជាងនេះបន្តិច នៅពេលដែលលោកនិយាយថា មន្ទីរនេះតើជាមន្ទីររបស់តំបន់១០៣ ឬ?

**ឆ៖** បាទ បើតាមខ្ញុំដឹងខ្លះ ប្រហែលជាមន្ទីរតំបន់១០៣។ អំ! មន្ទីរ១០៣ មិនមែនតំបន់ទេបាទ។

**ស៖** សូមអរគុណ។ បុគ្គលទាំងពីរនាក់នេះ តាមដែលចម្លើយរបស់លោកនោះ គេតែងតែវាយសារទូរលេខ រួចបញ្ជូនទៅលោក ខៀវ សំផន តើលោកនៅចាំដែរឬទេ តើពួកគាត់ហ្នឹង គឺមានមុខងារ ឬក៏ការទទួលខុសត្រូវអ្វីនៅមន្ទីរ១០៣ នោះ?

**ឆ៖** បាទ កាលខ្ញុំទៅដល់គេផ្លាស់តំបន់ គឺថាតំបន់មួយហើយ តែមិនដឹងជា អូ! គេៗបាញ់គណៈតំបន់១ ឈ្មោះម៉ាន ហ្នឹងគាត់ស្លាប់ទៅ ហើយមួយទៀតគេចាប់គាត់ដាក់កន្លែង ភូមិស្រុករវៀង ហ្នឹង។ ហើយក្រោយមកទៀត ខ្ញុំទៅទាន់តែតំបន់ អំា! ខ្ញុំទៅទាន់ឈ្មោះតែ តាឃឹម មួយទេគាត់ចេញពីហ្នឹងមកនៅសាលាស្រុករវៀងហ្នឹង សាលារៀនវិទ្យាល័យស្រុករវៀង។

[១៥:១៧:៣០]

**ស៖** នៅក្នុងចម្លើយទី១ គឺថាឯកសារ E3/424 នៅក្នុងសំណួរនិងចម្លើយទី១២ លោកបាននិយាយថា "នៅពេលដែលខ្ញុំសង្កេតមើល នៅពេលនោះពិនិត្យតំបន់ព្រះវិហារនៅពីរខែនោះគឺ តាម៉ុក បានបញ្ជាឱ្យគេដកហូត តាឃឹម ចេញពីតំបន់៣០៣ ដោយប្រើកម្លាំងរបស់គាត់ដើម្បីបញ្ជូនតាឃឹម ពីទីនោះទៅខេត្តព្រះវិហារមក"។ នៅផ្នែកនេះលោកនិយាយថា តាឃឹម ជានៅក្នុងគណៈតំបន់១០៣ ថាតើត្រូវដែរឬទេ ថាតាឃឹម ជាលេខាតំបន់១០៣ មុនដែលលោកទៅនៅព្រះវិហារនោះ?

**ឆ៖** បាទ មែន។

**ស៖** មន្ទីរដែល អើយ និង អុល ៗធ្វើការនៅមន្ទីរ១០៣ នោះតើហ្នឹងជាមន្ទីររបស់ តាឃឹម ឬ?

**ឆ៖** កន្លែងសាលាវិទ្យាល័យរវៀងឯណោះ ហើយមន្ទីរទម្លាប់ហ្នឹង នៅឆ្ងាយពីហ្នឹងទៀត ប្រហែលជាគណៈតំបន់គេមុនគេធ្វើ។ មិនដឹងឈ្មោះអី ខ្ញុំទៅអត់ទាន់។

**ស៖** តើលោកដឹងថា តាឃឹម មានបញ្ហាអ្វីដែរឬទេ នៅពេលដែលកងកម្លាំងរបស់ តាម៉ុក ទៅដកហូតគាត់ចេញពីកន្លែងនោះៗ?

**ឆ៖** បាទ ខ្ញុំទៅទាន់នឹង តាឃឹម នៅនឹងសណ្ដារ ស្រុករវៀងហើយ ប្រជាជនបានប្រាប់ខ្ញុំថា គេចាប់ប្រជាជនច្រើនណាស់ នៅឆែប នៅធ្នា នៅជាំខ្សាន្ត ហើយនិងនៅថាឡាបរិវ៉ាត់ គាត់ប្រាប់អ៊ីចឹង ហើយមិនដឹងថា កិច្ចការចាប់នោះយ៉ាងម៉េចទេ បាទ។

[១៥:២១:១៤]

**ស៖** ខ្ញុំសូមរំឭកនៅខណៈពេលនេះ ដែលថាអ្វីដែលលោកបានឆ្លើយខាងដើមនេះ អំពីការជួបប្រជុំរបស់លោកជាមួយ ប៉ុល ពត។ សូមកែតម្រូវខ្ញុំ ប្រសិនបើខ្ញុំនិយាយទៅមិនត្រូវ ហើយៗ ប៉ុល ពត និយាយថា "មានការចាប់ខ្លួនមនុស្សច្រើនណាស់ នៅក្នុងតំបន់នោះ"។ បាទ តើលោកបាននិយាយបែបហ្នឹង ត្រឹមត្រូវអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ហើយខ្ញុំក៏ចង់ឱ្យច្បាស់ដែលថា ចម្លើយរបស់លោកត្រឹមត្រូវដែរឬអត់ តើថាតើគាត់បានសុំឬក៏គាត់បានណែនាំឱ្យលោកធ្វើការអង្កេតអំពីសភាពការណ៍ អំពីស្ថានការណ៍ នៅក្នុងតំបន់នោះ ទាក់ទងទៅនឹងការចាប់ខ្លួនហ្នឹងដែរឬទេ?

**ឆ៖** បាទ គាត់ប្រាប់ មុននឹងទៅ គាត់ប្រាប់ថា កាលនោះ គេហៅឱ្យ -- គាត់ហៅខ្ញុំថា មិត្តឯងទៅមើលតំបន់ហ្នឹង គឺតំបន់ស្វយ័តរបស់មជ្ឈិម ហើយគេចាប់ប្រជាជនច្រើនណាស់ ព្រមទាំងប៉ះពាល់

ដល់កងការពារជាមួយគាត់ ជាម្ដាយ ឬក៏ជាបងប្អូនផង។ អ៊ីចឹង មិត្តទៅស៊ើបអង្កេតក្នុងរឿងហ្នឹង ហើយឲ្យដឹងច្បាស់ តើមែន ឬមិនមែន បាទ។

[១៥:២៣:១៩]

**ស៖** យើងអាចនឹងមានការច្រឡំ ភ័ន្តច្រឡំគ្នាបន្តិច។ សំណួរខ្ញុំសួរថា តើប៉ុល ពត បានណែនាំលោកឲ្យទៅអង្កេតរឿងការចាប់ខ្លួនមនុស្សនៅខេត្តព្រះវិហារដែរឬទេ?

**ឆ៖** ប្រាប់។

**ស៖** តើគាត់បាននិយាយប្រាប់លោកអំពីអ្វី? ថាតើអ្នកណាជាអ្នកចាប់មនុស្សនៅក្នុងតំបន់ហ្នឹងដែរឬទេ? ឬក៏គាត់ប្រាប់លោកថា ត្រូវស៊ើបអង្កេតលើឈ្មោះណា អ្នកណាដែរឬទេ?

**ឆ៖** បាទ គាត់អត់បានប្រាប់ឈ្មោះទេ។

**ស៖** ខ្ញុំចង់បង្ហាញជូនឯកសារមួយ លោកមើលអំពីបញ្ហាដែលយើងបានពិភាក្សាគ្នានេះ។ ដែលនិយាយអំពីការចាប់ខ្លួនមនុស្សនៅក្នុងតំបន់នោះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម ឯកសារនេះគឺ E3/1077 ជាឯកសារសារទូរលេខដែលយើងបានពិភាក្សាពីខាងដើមនៅតុលាការនេះដែរ ហើយផ្ញើជូនទៅគណៈមន្ទីរ៨៧០។ សូមការអនុញ្ញាត ខ្ញុំនឹងជូនឯកសារនេះទៅសាក្សី ហើយនិងសួរគាត់អំពីសំណួរខ្លីៗទាក់ទងទៅនឹងហេតុការណ៍ ដែលកើតឡើងនៅក្នុងភូមិភាគឧត្តរ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

[១៥:២៥:៥៧]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាក្សី រឿន នេះជាឯកសារវែង ប៉ុន្តែខ្ញុំចង់ឲ្យលោកមើលតែផ្នែកមួយចំនួន ដែលខ្ញុំនឹងជម្រាបលោកតែប៉ុណ្ណោះ។ កថាខណ្ឌទី២ ខ្ញុំសូមជម្រាបថា ឯកសារនេះចុះហត្ថលេខាដោយ សែ ដូចដែលលោករៀបរាប់ខាងដើមថា ម្នាក់នោះឈ្មោះ សែ ដែលបានចូលរួមក្នុងប្រជុំជាមួយនឹង ប៉ុល ពត និង តាម៉ុក។ កថាខណ្ឌទី៣ និយាយដូចខាងក្រោមនេះ៖

"សភាពការណ៍ខ្លាំងនៅក្នុងភ្នំដងរែក គឺថាយើងមានផ្នែកស្រាវជ្រាវ ហើយកម្ទេច ហើយគឺនៅ

ក្នុងក្រុមរបស់ តាំ ដែលស្ថិតនៅក្នុង ដែលនៅឈ្មោះ ហុង បន្ទាប់ពីគឺយើងការចាប់ខ្លួន ហុង មក គឺថាដៃជើងរបស់វានៅជាំក្សាន្ត។ នៅក្នុងក្រុម តាំ នោះ ពួក អ៊ិន តាំ នោះត្រូវអស់បង្អែកហើយ”។

ហើយនៅក្នុងកថាខណ្ឌបន្ទាប់មួយទៀតនៅខាងក្រោម ដែលចាប់ផ្តើមលេខ៣.៣ ដែលនិយាយដូចខាងក្រោម៖

“សភាពការណ៍ខាងក្នុងគ្មាន អ្វីប្រែប្រួលធំដុំអីទេ ស្ថានភាពធម្មតា។ យើងកំពុងបន្តបោសសម្អាតពួកអានៅសេសសល់ជាបន្តបន្ទាប់នៅ។ ដែលប្រឆាំងនឹងបដិវត្តន៍របស់យើង ដោយចំហក្តី ទាំងដោយសម្ងាត់ក្តី”។

[១៥:២៧:៤៩]

ក្នុងការពិភាក្សជាមួយ ប៉ុល ពត ដែលលោកបានចូលរួមនោះ តើគាត់បានប្រាប់លោកថា គាត់បានទទួលរបាយការណ៍ពីភូមិភាគឧត្តរដែរឬទេ អំពីការចាប់ខ្លួនមនុស្សនោះ ដែលគេចាប់ខ្លួនជាបន្តបន្ទាប់នៅក្នុងតំបន់នោះនោះ?

**ឆ៖** បាទ ខ្ញុំអត់បានទទួលទេ សភាពការណ៍នេះប្រហែលជាមុនខ្ញុំទៅ។

**ស៖** សូមអរគុណ។ ខ្ញុំនឹងចូលទៅដល់ប្រធានបទមួយខុសគ្នាបន្តិច គឺចំណុចមួយដែលយើងបានពិភាក្សាខាងនោះ គឺយើងនិយាយអំពីបុគ្គលម្នាក់ឈ្មោះ ជូ ជេត ដែលជាលេខានៃភូមិភាគបស្ចិម។ តើលោកអាចជម្រាបតុលាការបានទេ ថាតើ ជូ ជេត នេះមានបញ្ហាអ្វីទេ? តើគាត់បន្តជាលេខាភូមិភាគបស្ចិមរហូតដល់ចុងនៃរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

[១៥:២៩:១៧]

**ឆ៖** បាទ ក្នុងការគាត់ទទួលលេខាភូមិភាគបស្ចិមនោះ បើតាមខ្ញុំដឹងខ្លះ ឮខ្លះ ថាគាត់មិនបានទទួលចប់ចុងចប់ដើមទេ។

**ស៖** តើគាត់ជួបបញ្ហាអ្វីដែរ?

**ឆ៖** បាទ ខ្ញុំមិនបានដឹងថាគាត់ជួបនឹងមូលហេតុ ឬក៏គាត់ជួបនឹងបញ្ហាអ្វីនោះទេ ព្រោះជារឿងបញ្ហារបស់គាត់ និងមជ្ឈិម។

**ស៖** នៅពេលដែលលោកនិយាយថា ជាបញ្ហារបស់គាត់និងមជ្ឈិមនោះ។ តើលោក -- តើបុគ្គលណាខ្លះដែលនៅមជ្ឈិមនោះ?

**ឆ៖** បាទ សំដៅលើ ប៉ុល ពត និង តាម៉ុក។

**ស៖** ដោយគោរពទៅតាមការណែនាំរបស់អង្គជំនុំជម្រះ ខ្ញុំនឹងបញ្ចប់ការសួររបស់ខ្ញុំ ហើយខ្ញុំមានសំណួរមួយចំនួនទៀតតែពីរបីតែប៉ុណ្ណោះទេ។ នៅពេលដែលយើងពិភាក្សាអំពីការប្រជុំ ដើម្បីរៀបចំការវាយប្រហារភ្នំពេញ យើងមើលចម្លើយឯកសារ E3/424 ហើយសំណួរនិងចម្លើយទី៣ ដែលលោកបានមើលរួចមកហើយ។ ផ្នែកមួយដែលលោកនិយាយថា "មេបញ្ជាយោធាមកពីភូមិភាគ បានចូលរួមការប្រជុំជាមួយនឹងអគ្គសេនាធិការ ដែលមានតា សុន សេន និង តា នួន ជា ក៏វត្តមានដែរ"។ ហើយលោកក៏បាននិយាយដែរថា "លោកក៏បានចូលរួមក្នុងការប្រជុំនោះដែរ"។ តើលោកបានដឹងដោយរបៀបណាថា នួន ជា និងសុន សេន នេះបានចូលរួមនៅក្នុងការប្រជុំនេះដែលជាការប្រជុំរបស់មេបញ្ជាការ ហើយប្រជុំរបស់អគ្គសេនាធិការផងបាទ?

[១៥:៣១:៥៩]

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបពីដើមអ៊ីចឹង គឺថាខ្ញុំដឹងតែតាមរយៈប្រធានកងពលមកប្រាប់ខ្ញុំទេ។ តែការទៅប្រជុំផ្ទាល់ អាហ្នឹងអត់បានទៅប្រជុំផ្ទាល់ទេ។ ដូច្នេះ គឺថា តាសឿង ដែលជាបញ្ជាការរបស់លោកនោះបានប្រាប់លោកថា "អគ្គសេនាធិការដូចជាតា សុន សេន និងតា នួន ជា ហ្នឹងបានប្រជុំជាមួយគាត់ ហើយនិងមេកងពលផ្សេងៗ"។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ បើអ៊ីចឹងត្រឹមត្រូវ។

**ស៖** សូមអរគុណ។ ដូច្នេះ ខ្ញុំនៅសល់ពីរបីសំណួរតូចៗទៀត។ ក្នុងពេល-- នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ គឺចាប់ពីឆ្នាំ៧៥ រហូតទៅដល់ឆ្នាំ៧៩។ តើលោកធ្លាប់ចូលរួមប្រជុំ ឬក៏វគ្គរៀនសូត្រណាមួយដែលចូលរួមជាមួយនឹង នួន ជា ដែរឬទេ?

**ឆ៖** បាទ ចាប់ពីឆ្នាំ៧០ មកដល់៧៩ ខ្ញុំអត់បានរួមប្រជុំជាមួយអ៊ំ នួន ជា ទេ -- តានួន ជា ទេ។

[១៥:៣៣:៤៦]

**ស៖** នេះជាសំណួរចុងក្រោយរបស់ខ្ញុំហើយមើលទៅ។ តាមដែលលោកដឹង តាមដែលលោកដឹងនោះ តើគាត់មានកាន់តួនាទីណាមួយពាក់ព័ន្ធទៅនឹងយោធាបន្ទាប់ពីរំដោះភ្នំពេញដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដឹងថាគាត់កាន់តួនាទីរបស់គាត់យ៉ាងណាទេ ពីព្រោះខ្ញុំអត់បានដឹងថាគាត់ទទួលខាងអី ខ្ញុំមិនបានដឹងកិច្ចការងាររបស់ថ្នាក់ដឹកនាំរបស់មជ្ឈិម។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកសាក្សី។ នេះគឺជាសំណួរចុងក្រោយរបស់ខ្ញុំ។ លោកសាក្សី តាងឲ្យព្រះរាជ

អាជ្ញា ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកដែលបានយកចិត្តទុកដាក់ ហើយបានចំណាយពេលវេលាក្នុងការផ្តល់ចម្លើយរបស់ខ្ញុំ។ ហើយខ្ញុំមិនមានសំណួរបន្តទៀតទេ។ សូមអរគុណលោក។

[១៥:៣៥:០៩]

**ប្រធានអង្គជំនុំ៖**

បាទ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល ដើមបណ្តឹងរដ្ឋប្បវេណី និងសូមជម្រាបសួរដល់លោកអ៊ំ មាស វឿន។ បាទ ខ្ញុំបានឈ្មោះ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំនឹងសហការីរបស់ខ្ញុំ អេលីហ្សាបេត ស៊ីម៉ុនណូហ្វត នឹងសួរសំណួរមួយចំនួន។ លោកអ៊ំកន្លងមករហូតដល់ពេលនេះ បានសហការនៅក្នុងការឆ្លើយនូវសំណួរជាច្រើន ហើយសង្ឃឹមថា លោកអ៊ំសហការឆ្លើយសំណួរបន្ថែមទៀត ដើម្បីបំភ្លឺអង្គតុលាការ ក៏ដូចជាសាធារណជនដើម្បីឲ្យមានការយល់ដឹងកាន់តែច្បាស់ថែមទៀត អំពីអ្វីដែលកើតឡើងនៅក្នុងអតីតកាល។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សំណួរជាបឋម គឺចង់សួរពាក់ព័ន្ធទៅនឹងថ្ងៃបង្កើតរបស់កងទ័ពបដិវត្តន៍ ដោយសារអ៊ំជាកងទ័ពយូរឆ្នាំ។ តើកងទ័ពបដិវត្តន៍របស់ខ្មែរក្រហមត្រូវបានបង្កើតនៅពេលណា? ថ្ងៃខែឆ្នាំណា?

[១៥:៣៦:៤៨]

**លោក មាស វឿន៖**

**ឆ៖** បាទ បើតាមចាប់ផ្តើមបង្កើតកងទ័ពកម្ពុជាប្រជាធិបតេយ្យតាំងពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ដែលមានកងទ័ពទាំងបី គឺជើងទឹក, ជើងគោក និងជើងអាកាស។

**ស៖** តើអ៊ំអាចបញ្ជាក់បានទេ នៅមុន១៧ មេសា ឆ្នាំ១៩៧៥ ហ្នឹងថាតើខាងកងទ័ពរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹង ពីមុននឹងមានការទ័ពកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** បាទ ពីមុនកងទ័ព -- ពីមុនឆ្នាំ៧៥ បើគិតតាំងពីឆ្នាំ១៩៦៩ -- ៦៨ មកកងទ័ពអត់មានទេ។

មានតិចណាស់នៅភូមិភាគនិរតីប្រហែលជា ១០០នាក់ប៉ុណ្ណឹងទេ។ ប៉ុន្តែមិនដឹងថ្ងៃខែ ខ្ញុំអត់បានចាំ។

[១៥:៣៨:១៦]

**ស៖** តើអ៊ំមានដែលធ្លាប់ឮអំពីព្រឹត្តិការណ៍អ្វីមួយដែលអាចកើត អ៎! ដែលបានកើតឡើងនៅកន្លែងមួយដែលមានឈ្មោះថា បាយដំរាំ ដែរឬទេ អ៊ំ?

**ឆ៖** បាទ ឮ។ ឮក្នុងការដែលកកើតចលនាតស៊ូហ្នឹង គឺនៅភូមិបាយដំរាំ មួយ និងភ្នំវាយចាបក្នុងឆ្នាំ១៩៧៧ អ៎! ៦៧។ ៦៩ មិនដឹង ខ្ញុំភ្លេចឆ្នាំបាទ។

**ស៖** បាទ មិនអីទេ។ តើអ៊ំអាចបញ្ជាក់បានទេថាតើហេតុអ្វីបានជាអ៊ំមានប្រសាសន៍ថា មានការបង្កើតចលនាតស៊ូពីកន្លែងនោះមក? តើមានព្រឹត្តិការណ៍អ្វីដែលធ្វើឲ្យអ៊ំមានប្រសាសន៍ថា ចលនាតស៊ូមានកំណើតតាំងពីពេលនោះមក?

**ឆ៖** បាទ ដោយការដឹង ដោយសារអ្នកដឹកនាំ ឬកម្មាភិបាលបានបង្ហាត់បង្រៀនខ្ញុំឲ្យដឹង ដូចជា តាម៉ុក ជាដើមដែលគាត់បានប្រាប់ពីរឿងការតស៊ូពេលនោះ ក្នុងពេលដែលបញ្ចប់សង្គ្រាមនៅឥស្សរៈ ហើយ គាត់ប្រាប់ថា ប្រជាជនកម្ពុជារៀបប្រទេសកម្ពុជាយើងមិនទាន់មានឯករាជ្យទេ។ ដូច្នេះបានជាកើតមានចលនាតស៊ូនៅពេលនោះ រហូតដល់ដែលអ្នក -- ដែលបារាំងទៅស្រុកហើយ ក៏អ្នកមានចលនាតស៊ូនៅជនបទមាននៅពេលនោះដែរ។

**ស៖** តើអ៊ំ -- ពាក់ព័ន្ធ -- នេះជាសំណួរចុងក្រោយរបស់ខ្ញុំពាក់ព័ន្ធនឹងចំណុចនេះ តើអ៊ំអាចបញ្ជាក់បានទេ តើអ្នកណាជាអ្នករៀបចំចលនាតស៊ូនៅបាយដំរាំ ដែលអ៊ំបានមានប្រសសាសន៍អម្បាញ់មិញ?

**ឆ៖** បាទ ខ្ញុំអត់បានចាំឈ្មោះទេ ក៏ប៉ុន្តែគ្រាន់តែ តាម៉ុក ប្រាប់ខ្ញុំថា ភូមិបាយដំរាំជាភូមិមានការតស៊ូពីជំនាន់ឥស្សរៈមក។ ដូច្នេះ ប្រជាជនកន្លែងហ្នឹងគឺសកម្ម ហើយលំបាកច្រើនណាស់ដែលក្នុងការតស៊ូជំនាន់ឥស្សរៈ។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ បាទ សូមទោសសំណួរចុងក្រោយមួយទៀត ពាក់ព័ន្ធនឹងចំណុចនេះ ថាតើអ៊ំចាំច្បាស់ទេថា តើថ្ងៃណាជាថ្ងៃបង្កើតចលនាតស៊ូហ្នឹង ដែលក្រោយមកទៀតមានកងទ័ពខ្មែរក្រហមបន្តបន្ទាប់មកទៀតនេះ?

[១៥:៤១:៣០]

**ឆ៖** បាទ ការដែលខ្ញុំដឹង ដែលខ្ញុំបានដឹងពីឆ្នាំ១៩៦៨ ហ្នឹងដែលខ្ញុំបានដឹងការដែលកកើតចលនា

តស៊ូ ក៏ប៉ុន្តែពីមុនទៀត ខ្ញុំមិនបានចាំទេ។ ខ្ញុំដឹងតែត្រឹមខ្ញុំដែរ បានដឹងឆ្នាំ១៩៦៨ មក។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ ក្រុមចលនាតស៊ូហ្នឹង ថាតើចាប់ពីពេលនោះមក តើអ៊ំមានបានចាំទេថា អ៊ំទទួលព័ត៌មានថា ចលនាតស៊ូនោះត្រូវបានគេហៅថា ឈ្មោះជាៗចលនាអ្វី ឬក៏ថាជាអង្គភាពអ្វី? តើអ៊ំអាចបញ្ជាក់បានទេពីឈ្មោះរបស់ចលនា អ៊ំ! ពីឈ្មោះរបស់ក្រុមអ្នកតស៊ូ ដែលជាអ្នកកម្លាំងប្រដាប់អាវុធហ្នឹង?

**ឆ៖** បាទ ខ្ញុំអត់បានចាំទេ។ អត់ -- ដូចគេមិន -- គេមិនប្រាប់ឈ្មោះហើយក៏ខ្ញុំមិនបានចាំ។

**ស៖** តើអ៊ំមានធ្លាប់ឮឈ្មោះមួយ ដែល -- ឮពាក្យមួយដែលគេហៅថា "កងការពារសម្ងាត់" ដែរទេអ៊ំ?

**ឆ៖** បាទ "កងការពារសម្ងាត់" ហ្នឹងគឺមានតែឈ្មោះថា កងការពារកម្មាភិបាល ប៉ុន្តែការពារសម្ងាត់ ក៏ប៉ុន្តែឈ្មោះអ្វីក្រៅពីហ្នឹង មិនមានទេ មិនមានដាក់។

[១៥:៤៣:២៧]

**ស៖** អ៊ំអាចបញ្ជាក់បានទេថា តើ "ក្រុមកងការពារសម្ងាត់" នេះគាត់មានភារកិច្ចធ្វើអ្វីខ្លះនៅពេលទសវត្សរ៍៦០?

**ឆ៖** កងការពារសម្ងាត់មានការ ឧបមាថា មានការខាងក្នុងៗ មាននៅតាមជនបទ អាហ្នឹងគឺថាកុំឱ្យគេដឹង កុំឱ្យគេឮ គឺបានឃោសនាអប់រំពីប្រទេសរបស់ -- ថាប្រទេសកម្ពុជាហ្នឹងមិនទាន់មានឯករាជ្យ ហើយតស៊ូរវាង -- ផ្តួលរំលំរបបនាយទុន សក្តិភូមិ។

**ស៖** ពាក់ព័ន្ធនឹងបញ្ហាតស៊ូ ផ្តួលរំលំនាយទុន ថាតើគាត់តស៊ូដោយធ្វើសកម្មភាពអ្វីខ្លះ សកម្មភាពជាក់ស្តែងរបស់គាត់?

**ឆ៖** បាទ ខ្ញុំមិនបានដឹងច្បាស់អស់ទេ ក៏ប៉ុន្តែនៅតាមជនបទគ្រាន់ថា តាមជនបទ គ្រាន់តែប្រាប់ប្រជាជន ឬក៏ឃោសនាប្រជាជនដោយសម្ងាត់ ប្រាប់ពីប្រទេស ប្រាប់ពីការជិះជាន់ ប្រាប់ពីការរស់នៅ ប្រាប់ពីការសេដ្ឋកិច្ចក្នុងប្រទេសរបស់យើងហ្នឹង។ អាហ្នឹងគេប្រាប់ប្រជាជនតាមស្ងាត់ៗ ដើម្បីកុំឱ្យភ្នាក់ងាររបស់រដ្ឋអំណាចគេដឹងប៉ុណ្ណឹងឯង។

[១៥:៤៥:៣១]

**ស៖** តើនៅក្នុងទសវត្សរ៍៦០ហ្នឹង មានក្រុមណាដែលមានតួនាទីនៅក្នុងការវាយឆ្មក់ទៅលើនគរបាល ឬក៏យោធារបស់ លន់ នល់ ដែរឬទេ នៅក្នុងទសវត្សរ៍៦០ នោះអ៊ំ?

**ឆ៖** បាទ មិនទាន់មានទេ ពីព្រោះគ្មានអាវុធៗ សម្រាប់ធ្វើសកម្មភាព។

**ស៖** បាទ នៅសម្រាប់ជាសំណួរជាទូទៅតែម្តង តើអ៊ំមានធ្លាប់ឮគេនិយាយថា "កងទ័ពគឺជាឧបករណ៍ផ្តាច់ការរបស់បដិវត្តន៍" ដែរឬទេអ៊ំ?

**ឆ៖** បាទ ក្នុងនោះមិនទាន់មានៗពាក្យហ្នឹងនៅឡើយទេ មានដល់ពេលឆ្នាំ១៩៧០, ៧១, ៧២ បានមានពាក្យហ្នឹងឮ។

**ស៖** តើលោកអ៊ំអាចពន្យល់បានទេ ថាតើន័យដែលនិយាយថា "កងទ័ពគឺជាឧបករណ៍ផ្តាច់ការរបស់បដិវត្តន៍" ហ្នឹង មានន័យថាយ៉ាងដូចម្តេច "ឧបករណ៍ផ្តាច់ការ" ហ្នឹង?

**ឆ៖** បាទ "ឧបករណ៍ផ្តាច់ការរបស់បដិវត្តន៍" បានន័យថា ខំបម្រើ ខំធ្វើដោយគ្មានកម្រៃ ឬក៏ដោយហ៊ានការលះបង់ជីវិត ដើម្បីជាតិប៉ុណ្ណឹង។

**ស៖** តើវាអាចមានន័យថា នៅពេលណាដែលទទួលបញ្ជាអ្វីមួយហើយ កងទ័ពហ្នឹងត្រូវតែធ្វើតែម្តង។ តើវាអាចមានន័យយ៉ាងដូច្នេះដែរឬទេ?

**ឆ៖** បាទ នៅពេលនោះ មិនទាន់មានន័យទេ ពីព្រោះយើងអត់សូវមានកម្លាំងច្រើននៅឡើយ។

**ស៖** ចុះនៅពេលក្រោយមក -- ចុះពេលក្រោយមកទៀត នៅពេលដែលមានកម្លាំងច្រើននៅក្នុងទសវត្សរ៍៧០ មានន័យថា ចាប់ពីឆ្នាំ១៩៧០, ៧១ រហូតទៅដល់ឆ្នាំ១៩៧៥ ហ្នឹង ថាតើតួនាទីរបស់គាត់ ដែលនិយាយថា "ជាឧបករណ៍ផ្តាច់ការ" ហ្នឹង គឺគាត់បំពេញតួនាទីអ្វីខ្លះ?

[១៥:៤៨:៣៧]

**ឆ៖** បាទ នៅឆ្នាំ១៩៧០ ក្នុងការរដ្ឋប្រហារ គឺដែលមានសម្តេច សីហនុ ធ្វើរដ្ឋប្រហារទៅគឺថាប្រជាជន និងកងទ័ពឈរនៅខាងសម្តេច សីហនុ ភាគច្រើន។ ដូច្នេះ នាំឲ្យកម្លាំងមានការកើនច្រើនឡើងក្នុងនោះបានពេលដែលយើងរួបរួម ឬក៏រៀបចំកងទ័ពបានធ្វើសកម្មភាពវ៉ៃមកលើរបបសាធារណៈ។

**ស៖** បាទ ខ្ញុំសូមថយក្រោយមួយសំណួរ។ តើលោកអ៊ំធ្លាប់ឮអំពីការវាយបន្ទាយនៅបាយដំរាំហ្នឹងដែរឬទេ? វាយដោយកងទ័ពសម្ងាត់?

**ឆ៖** បាទ ក្នុងពេលនោះ ខ្ញុំមិនបានដឹងថា ភូមិបាយដំរាំ មានបន្ទាយ ឬក៏មានទីតាំងរបស់ទាហានសាធារណរដ្ឋទេ ពីព្រោះការទាក់ទងនៅពេលនោះគ្មានមធ្យោបាយអ្វីទាំងអស់ ដោយដើរទាក់ទងរាប់ខែ តាំងពីៗកំពង់ឆ្នាំង ឬពីកំពង់ស្ពឺ ទៅបាត់ដំបង ដើរកាត់ព្រៃរាប់ខែ មិនដែលបាន -- មិនសូវបានជួបគ្នាផង។ ដូច្នេះ ការដឹងសភាពការណ៍គ្នាទៅវិញទៅមក វាដូចថា វាត្រូវដាច់រយៈឆ្ងាយខែដែរ

យូរខែរដែរ។

**ស៖** បាទ សូមអរគុណលោកអ៊ំ។ តើលោកអ៊ំអាចបញ្ជាក់បានទេ នៅក្នុងអំឡុងពេលក្រោយ ១៧ មេសា ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ០៦មករា ថាតើយោធា ឬក៏កងទ័ពនេះ គាត់មានតួនាទីអ្វីខ្លះនៅក្នុងប្រទេស?

[១៥:៥០:៤៧]

**ឆ៖** បាទ នាទីនិងភារកិច្ចរបស់យោធាបានដែលបានរំដោះចាប់ពីឆ្នាំ១៩៧៥ គឺថាមានមាគ៌ាមួយលើកឡើងថា “ដៃម្ខាងវ៉ៃខ្មាំង ដៃម្ខាងបង្កបង្កើនផល”។

**ស៖** នៅក្នុងការវ៉ៃខ្មាំងហ្នឹង ក្នុងតួនាទីនេះ ថាតើមានភារកិច្ចនៅក្នុងការ -- ក្នុងផ្នែកសន្តិសុខដែរឬទេ តួនាទីខាងយោធានេះ?

**ឆ៖** បាទ ចំណែកយោធា មាននូវភារកិច្ចនៅតាមព្រំដែនទាំងអស់ នៅខាងលិច និងខាងកើត។ អត់មាននៅក្នុងស្រុក មានតែភូមិភាគពិសេសមួយទេ ដែលអាចនៅក្នុងស្រុកបាន។

**ស៖** តើអ៊ំអាចបញ្ជាក់បានទេ មណ្ឌល -- មន្ទីរសន្តិសុខនានាហ្នឹង ថាតើស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងណា នៅក្នុងសម័យ៣ឆ្នាំហ្នឹង?

**ឆ៖** បាទ បើតាមខ្ញុំដឹងខ្លះកិច្ចការងារទាំងអស់នោះ បើមន្ទីរភូមិភាគ គឺភារកិច្ចរបស់ភូមិភាគ។ ហើយនិងមន្ទីរកងពល គឺស្ថិតនៅក្នុងភារកិច្ចរបស់កងពល។ ដូច្នេះ ក្នុងមន្ទីរទាំងអស់នោះ ដែលមានជាមន្ទីរសំខាន់ៗ ហើយភូមិភាគ និងកងពល ទាក់ទងគ្នា រៀបចំយ៉ាងម៉េចនោះ ខ្ញុំមិនបានដឹងច្បាស់លាស់ទេ។

[១៥:៥៣:០៤]

**ស៖** បាទ អ៊ំ អម្បាញ់មិញអ៊ំមានប្រសាសន៍ផងដែរ ថាកងទ័ពមានដៃម្ខាងកាន់កាំភ្លើង ដៃម្ខាងបង្កបង្កើតផល។ តើអ៊ំមានធ្លាប់ឮអំពីពាក្យមួយដែលគេនិយាយអំពី “ធ្វើស្រែឲ្យបានបីតោនក្នុងមួយហិកតា” ដែរទេអ៊ំ?

**ឆ៖** បាទ ខ្ញុំឮ ព្រោះខ្ញុំនៅកោះកុង។ ខ្ញុំការពារផង ខ្ញុំធ្វើស្រូវបាន ចិញ្ចឹមកងទ័ពបានខ្លះ ក៏ប៉ុន្តែមកខាងក្រោយ ខ្ញុំឮថា បីតោន ពីរបីតោន ឮ។

**ស៖** តើអ៊ំអាចបញ្ជាក់បានទេ ថាតើពាក្យនេះ ចេញពីមកប្រភពណា? ហើយជាការតម្រូវឲ្យបង្កបង្កើនផលឲ្យបានបីតោនក្នុងមួយហិកតាអីចឹងមែន ឬក៏ថាយ៉ាងម៉េច?

[១៥:៥៤:២៥]

**ឆ៖** បាទ ចេញមកពីតាមអ្នកដឹកនាំលេខា ភូមិភាគ ហ្នឹងទៅ ហើយនិងអ្នកដឹកនាំតាមកងពល បានបញ្ជាក់ប្រាប់អ៊ីចឹង ធ្វើម៉េចឲ្យបានពីរតោន បីតោន ក្នុងមួយហិកតា ដើម្បីចិញ្ចឹមខ្លួនយើងផង និងឧបត្ថម្ភដល់រដ្ឋផង។

**សៈ** បាទ តើពីខាងថ្នាក់លើលេខាភូមិភាគ ហើយនិងតំបន់ហ្នឹង គាត់ជាអ្នកសម្រេចខ្លួនឯងដំបូងអំពីការកំណត់យ៉ាងដូច្នេះ ឬក៏មានអ្នកផ្សេងជាអ្នកសម្រេចអំពី ការកំណត់ថាត្រូវធ្វើឲ្យបានបីតោននេះ?

**ឆ៖** បាទ ការសម្រេចនេះគឺមកពីលេខាតំបន់ និងភូមិភាគផងដែរ ទាំងពីរនេះដែលគេកំណត់ថាធ្វើឲ្យបានបីតោនក្នុងមួយហិកតា។

**សៈ** ខ្ញុំក្តាប់អត់ទាន់បាន អ៊ំមានប្រសាសន៍ថា "ផងដែរ" អ៊ីចឹងមានន័យថា ត្រឹមគាត់ដែលជាថ្នាក់ភូមិភាគជាអ្នកសម្រេច ឬក៏ថាអាចមានពីលើភូមិភាគទៀតជាអ្នកសម្រេចអំពីគោលនយោបាយនេះ?

[១៥:៥៦:០៩]

**ឆ៖** បាទ បើតាមខ្ញុំដឹងច្បាស់ពីលេខាតំបន់ ភូមិភាគ ក៏ប៉ុន្តែភូមិភាគនឹងទទួលផែនការពីមជ្ឈិមយ៉ាងណានោះ បានគេយកមកផ្សាយដល់តំបន់ និងភូមិភាគ។ ដូច្នេះ គេសំដៅទៅលើផែនការថ្នាក់ដឹកនាំប្រទេស គឺសំដៅសំខាន់ទៅលើ ប៉ុល ពត។

**សៈ** បាទសូមអរគុណ។ លោកអ៊ំមានប្រសាសន៍ថា អាចទទួលអំពីមជ្ឈិមយ៉ាងណានោះ អ៊ីចឹងអ៊ំអាច -- អ៊ំដឹងទេថានៅថ្នាក់មជ្ឈិម តើមាននរណាខ្លះដែលនៅថ្នាក់មជ្ឈិមអ៊ំ?

**ឆ៖** បាទ បើតាមតែថ្នាក់មជ្ឈិមមាន តា ប៉ុល ពត, មានតា នួន ជា, មាន តាម៉ុក ដែលជាសំខាន់។

**សៈ** តើអាចមានអ្នកផ្សេងពីហ្នឹងទៀតទេ ពីព្រោះអ៊ំអម្បាញ់មិញនិយាយថា "ដែលជាសំខាន់" ហើយអ៊ីចឹងមានន័យថា មិនច្បាស់លាស់ទេ។ អ៊ីចឹងអ៊ំអាចមានប្រសាសន៍ថា -- អាចមានជម្រាបផងទេថា អ៎! ជម្រាបបានទេថា តើក្រៅពីអ្នកដែលអ៊ំដែលបានរាយឈ្មោះហ្នឹង អាចមាននរណាគេផ្សេងទៀតនៅក្នុងមជ្ឈិមហ្នឹងដែរឬទេ?

[១៥:៥៧:៥៥]

**ឆ៖** បាទ ខ្ញុំមិនដែលស្គាល់ ស្គាល់ប៉ុណ្ណឹង។

**សៈ** បាទ សូមអរគុណលោកអ៊ំ។ ឥឡូវខ្ញុំចង់សួរចូលទៅដល់រចនាសម្ព័ន្ធ ដោយសារអ៊ំជាយោធា អ៊ំអាចបំភ្លឺពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ។ ហើយនៅក្នុងរចនាសម្ព័ន្ធខាងយោធា អ៊ំបានមានប្រសាសន៍អម្បាញ់មិញហើយ អំពីការបែងចែកជាបីនៃផ្នែកយោធានោះ។ តើអ៊ំអាច -- ជាបីហ្នឹង ថាតើពីលើពីថ្នាក់តំបន់ ពីលើថ្នាក់ -- ថ្នាក់តំបន់ចុះមកក្រោម ថាតើខាងយោធាហ្នឹងគេបែងចែកយ៉ាងម៉េចនៅកន្លែងអ៊ំផ្ទាល់ នៅតំបន់អ៊ំផ្ទាល់? ឬភូមិភាគអ៊ំផ្ទាល់ ដែលអ៊ំជាយោធានៅទីនោះ គេបែងចែកយ៉ាងម៉េចរចនាសម្ព័ន្ធ?

**ឆ៖** បាទ រចនាសម្ព័ន្ធនៅក្នុងភូមិភាគ មានភូមិភាគ មានយោធាភូមិភាគ ហើយមានយោធាតំបន់ ហើយមានយោធាស្រុក។ បាទ មានប៉ុណ្ណឹង។

[១៥:៥៩:១៥]

**សៈ** នៅក្នុងយោធាភូមិភាគហ្នឹង ថាតើមានបែងចែកជាប៉ុន្មានតំបន់អ៊ីចឹងដែរឬទេ? ហើយនៅក្នុងតំបន់ហ្នឹងមានបែងចែកចេញជាយោធា -- ក្រុមយោធាតំបន់ហ្នឹង បែងចែកជាស្អីខ្លះ? ជាវរៈ ឬក៏ថាអនុសេនាធំ? អ៊ំអាចនិយាយលម្អិតពីបញ្ហាហ្នឹងបានដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមលើកពីរចនាសម្ព័ន្ធយោធាដើម្បីច្បាស់។ ឧទាហរណ៍ យោធាភូមិភាគ, យោធាភូមិភាគមានចាប់ពីក្រុម ដល់វរសេនាតូច ដល់វរសេនាធំ រៀបចំរហូតដល់កងពល។ នេះខាងយោធាភូមិ ហើយយោធាតំបន់ ខ្ញុំមិនបានដឹងគេរៀបចំរបៀបម៉េចទេ ដឹងតែយោធាតំបន់។ ក៏ប៉ុន្តែវាដូចតែគ្នាទេ បើតាមខ្ញុំគិតមើលទៅដូចតែគ្នាទេបាទ។

**សៈ** អម្បាញ់មិញអ៊ំបានប្រសាសន៍ពាក់ព័ន្ធទៅនឹងអនុសេនាធំ ហើយអ៊ំឈានទៅដល់តំបន់តែម្តង។ តើនៅលើអនុសេនាធំហ្នឹងគេមានថ្នាក់អ្វីនៅលើអនុសេនាធំ ហើយនៅលើអាហ្នឹងមានបន្ត មានអ្វីទៀតដែលនៅលើអាហ្នឹងតទៀត?

**ឆ៖** បាទ ក្នុងមួយ -- ខ្ញុំក្នុងនិយាយជាមួយវរសេនាតូច គឺមានបីអនុសេនាធំ។ អាហ្នឹងរចនាសម្ព័ន្ធក្រោម។ ហើយវាបីៗអនុសេនាធំ វាមានមួយវរសេនាធំ។ ដូច្នេះ បីវរសេនាធំ វាត្រូវបានមួយកងពលតូច។ ខ្ញុំដឹងប៉ុណ្ណឹង។

[១៦:០១:២៧]

**សៈ** បាទ អរគុណលោកអ៊ំ។ លោកអ៊ំអាចបញ្ជាក់បានទេអម្បាញ់មិញ លោកអ៊ំបានមាន

ប្រសាសន៍ពីការបែងចែកជាបីនៃកងទ័ព កងទ័ពភូមិភាគ, កងទ័ពស្រុច ហើយនិងកងទ័ពឈ្លបហ្នឹង ថាតើកងទ័ពប្រភេទនីមួយៗហ្នឹង តើមានតួនាទីធ្វើអ្វីខ្លះ?

**ឆ៖** បាទ កងទ័ពរបស់យោធាភូមិភាគតួនាទីទៅព្រំដែនខាងក្រៅ ហើយកងទ័ពតំបន់ គេការពារក្នុងតំបន់របស់គេ។ ហើយកងទ័ពរបស់ស្រុក គេការពារតាមស្រុករបស់គេបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណណាស់ អរគុណសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ។ កិច្ចដំណើរការសវនាការនៅថ្ងៃនេះដល់ពេលត្រូវសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី០៨ ខែតុលា ឆ្នាំ២០១២ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយនេះ អង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មសាក្សី មាស វឿន ដែលនឹងសួរដេញដោលដោយក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បន្តនិងក្រុមមេធាវីការពារក្តី។ សូមភាគីនិងសាធារណជនជ្រាប។

លោក មាស វឿន ការស្តាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នូវឡើយទេ។ សវនាការត្រូវបន្តធ្វើនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយទៀត។ ដូច្នេះអង្គជំនុំជម្រះសូមបន្តលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃចន្ទ ដើមសប្តាហ៍ក្រោយទៀត ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។

[១៦:០៣:១៥]

ហើយមេធាវីប្រឹក្សាសាក្សី សូមអញ្ជើញមកដូចគ្នានឹងសាក្សីដែរ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីនេះវិលត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ។ ហើយនឹងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃចន្ទ ទី០៨ តុលា ឆ្នាំ២០១២ នៅវេលាម៉ោងប្រាំបួនព្រឹក។

មន្ត្រីអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ ហើយនឹងឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការវិញនៅព្រឹកថ្ងៃចន្ទ សប្តាហ៍ក្រោយឲ្យបានមុនម៉ោងប្រាំបួន។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*